សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិល្បកម្មក្រមាខ្មែរ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សុវេត ម៉ុនណាត**

កញ្ញា **ថៃ គីមលៀង**

ណែនាំដោយ

សាស្ត្រាចារ្យរងបណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី០៧

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេររបាយការណ៍ ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ / នាងខ្ញុំ ឈ្មោះ**សុខេត ម៉ុនឆាត** និង **ថៃ គីមលៀង** ជានិស្សិតថ្នាក់D4A2 ឆ្នាំទី៤ ជំនាន់ទី៧ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ក្រុមរបស់ខ្ញុំបានជ្រើសរើសយកប្រធានបទ “ **សិប្បកម្មក្រមាខ្មែរ** ” មកចងក្រងជារបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ តាមរយៈការណែនាំ និងផ្តល់ជាយោបល់យ៉ាងច្រើន របាយការណ៍ពួកយើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។ សូមថ្លែងនូវសេចក្តីគោរព និងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ៖

- សូមលំអោនកាយគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ លោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានឱប្រព្រឹត្តខ្លួនទៅតាមគន្លងធម៌ ដើម្បីរស់ នៅក្នុងសង្គម ព្រមទាំងទំនុកបំរុងថវិការ ចាប់តាំងពីកំរិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ ឧត្តមសិក្សា។ កូនសូមក្រាបប្រតិបត្តិ និងសម្តែងនូវកតញ្ញូធម៌ យ៉ាងជ្រាលជ្រៅបំផុតចំពោះឧបករៈគុណរបស់លោកទាំងទ្វេរដែលមានមកលើកូន។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកគ្រូ និងអ្នកគ្រូសាស្ត្រាចារ្យ បណ្ណារក្ស ព្រមទាំងបុគ្គលិកគ្រប់ការិយាល័យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានចំណាយពេលដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ខិតខំពន្យល់ បង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹង និងគំនិតថ្មីៗគ្រប់បែបយ៉ាងដល់រូបយើង ខ្ញុំ។
- សូមថ្លែងអំណរគុណជាពិសេសដល់ លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ដែល បានខិតខំផ្តល់ជាមតិយោបល់ ពន្យល់ និងព្រមទាំងចំណាយពេលសម្រាប់ការកែតម្រូវ និង បញ្ចេញគំនិតចំពោះការច្នៃប្រឌិតបន្ថែមទៀត ដើម្បីធ្វើឲ្យការស្រាវជ្រាវរបស់ពួកយើងខ្ញុំ កាន់តែប្រសើររហូតដល់បញ្ចប់របាយការណ៍ និងទទួលបានជាលទ្ធផលដ៏ល្អគាប់គួន។
- សូមថ្លែងអំណរគុណដល់ លោកអ៊ុំ **គីម ស៊ុន** មេភូមិ និងប្រជាជននៅភូមិជ្រោយអំពិល ស្រុកកៀនស្វាយ ដែលបានអនុញ្ញាតឲ្យពួកយើងទាំងពីរចុះកម្មសិក្សា ស្រាវជ្រាវ និង ផ្តល់ឱកាសចូលរួមកិច្ចសម្ភាសន៍ ព្រមទាំងសហការណ៍ក្នុងការផ្តល់ព័ត៌មាន និងទិន្នន័យ ជាច្រើនអនេកដល់ពួកយើងទាំងពីរនាក់។

ជាចុងបញ្ចប់នេះយើងខ្ញុំទាំងពីរ ជានិស្សិតសូមបួងសួងអោយវត្ថុស័ក្តិសិទ្ធិក្នុងលោកទាំងអស់ តាមថែរក្សាការពារ និងប្រសិទ្ធិពរជ័យ សិរី មង្គល វិបុលសុខគ្រប់ប្រការចូលកើតមានដល់លោកអ្នកទាំងអស់គ្នាឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាដំបូងខ្ញុំបាទឈ្មោះ **សុខេត ម៉ុនឆាត** និងនាងខ្ញុំ ឈ្មោះ **ថៃ គីមលៀង** សូមគោរព និងជម្រាបសួរទៅដល់សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍ដល់មិត្តសិស្សានុសិស្ស និស្សិត អ្នកស្រាវជ្រាវទាំងអស់ជាទី ស្រឡាញ់រាប់អាន។ ឆ្លងតាមការសិក្សារយៈពេល៤ឆ្នាំកន្លងមកនេះ នៃការសិក្សាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ បានផ្តល់ ឲ្យយើងខ្ញុំនូវចំណេះដឹងផ្សេងៗកាន់តែទូលំទូលាយពាក់ព័ន្ធនឹងមុខជំនាញនេះ។ ដោយមានចំណេះដឹងខ្លះៗ និងបទពិសោធន៍បន្តិចបន្តួចពួកយើងក៏មាន គោល បំណង ចង់ចែករំលែកនូវចំណេះដឹងបទពិសោធន៍ដែលយើងមាននៅក្នុងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នេះ ទៅដល់និស្សិតប្អូនៗជំនាន់ក្រោយ។ ជាពិសេសយកជំនាញ និងសមត្ថភាពដែលយើងមានពេលនេះទៅជួយអភិវឌ្ឍ ដល់ប្រទេសកម្ពុជាយើងថែមទៀតផង។ ជាឱកាសពិសេសដែល យើងមានឱកាសក្នុងការធ្វើសារណាដើម្បីបញ្ចប់ការ សិក្សានៃជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នេះ វាពិតជារឿងដែលអស្ចារ្យ និងមោទកភាពសម្រាប់យើងទាំងពីរនាក់។ យ៉ាងណាមិញ ការស្រាវជ្រាវមួយនេះទៀតសោត ក៏បានជួបនៅផលវិបាកមួយចំនួនក្នុងអំឡុងពេលស្រាវជ្រាវ ព្រោះយើងខ្ញុំទាំងពីរ ត្រូវបែងចែកពេលវេលាធ្វើការផង និងសិក្សាស្រាវជ្រាវផងដែលធ្វើអោយកិច្ចការស្រាវជ្រាវនេះកាន់តែមានភាពពិសេសសម្រាប់ពួកយើង និងជាវេលាដែលត្រូវចង់ចាំមិនអាចបំភ្លេចបាន។

សារណាបញ្ចប់ការសិក្សានេះក្រោមប្រធានបទ៖ **សិប្បកម្មក្រមាខ្មែរ**។ ឯកសារចងក្រង នេះផ្តោតសំខាន់ទៅលើ ការសិក្សាស៊ីជម្រៅពីក្រមារបស់ប្រជាជនកម្ពុជា ដែលជាវត្ថុសម្គាល់ថាជាជនជាតិខ្មែរ។ ក្រមា គឺជារបស់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរតាំងពីបុរាណកាលមកម្លេះ។ ក្រមាត្រូវបានត្បាញឡើងដោយអំបោះថ្មៃរលេចជាពណ៌ និងក្រឡាត្រង់ៗ ឆ្លាស់ពណ៌លាយគ្នាដើម្បីជាការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់។ ពីបុរាណមកការត្បាញក្រមា គឺជាសិប្បកម្មលក្ខណៈប្រពៃណី ដែលធ្វើដោយដៃ ក៏ប៉ុន្តែមកដល់បច្ចុប្បន្នការងារបែបហត្ថកម្មមួយនេះត្រូវបានផ្លាស់ប្តូរមកជាការត្បាញដោយម៉ាស៊ីន ដោយសារវាមានភាពងាយស្រួល និងមានភាពឆាប់រហ័សដើម្បីអាចតម្រូវការទីផ្សារបាន។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរអរគុណដ៏ជ្រាលជ្រៅចំពោះ សាស្តាចារ្យ លោកគ្រូ អ្នកគ្រូដែលបានខិតខំបង្រៀនពួកខ្ញុំដោយមិនគិតពីភាពនឿយហត់ ក្នុងគោលបំណងផ្ទេរចំណេះដឹង ឲសិស្សានុសិស្សដើម្បីយកទៅប្រើប្រាស់ក្នុងជីវភាពជាក់ស្តែង។ យើងខ្ញុំសូមជូនពរលោកគ្រូ អ្នកគ្រូ អោយមានសំណាងល្អ មានសុខភាពល្អ មានកម្លាំងមាំមួន និងអាចសម្រេចរាល់គ្រប់កិច្ចការ តាមបំណងប្រាថ្នា។

# មាតិកា

**ទំព័រ**

អក្សរកាត់........................................................................................................v
បញ្ជីតារាង ......................................................................................................vi
បញ្ជីរូប...........................................................................................................vii


## ជំពូកទី១៖ សេចក្តីផ្តើម

១.១. លំនាំបញ្ហា ........................................................................................ ១
១.២. ចំណោទបញ្ហា....................................................................................... ១
១.៣. គោលបំណងក្នុងការស្រាវជ្រាវ ................................................................... ២
១.៤. ទំហំ និងដែនកំណត់ក្នុងការស្រាវជ្រាវ......................................................... ៣
១.៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ ....................................................................... ៣
១.៦. សារៈសំខាន់នៃការស្រាវជ្រាវ.......................................................................៤
១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ ...............................................................................៤


## ជំពូកទី២៖ រំលឹកទ្រឹស្តី

២.១. និយមន័យ ............................................................................................៦
២.១.១. សិប្បកម្ម.............................................................................................៦
២.១.២. និយមន័យការគ្រប់គ្រងអាជីវកម្មខ្នាតតូចលក្ខណៈគ្រួសារ ..................................៦
២.១.២.១. ការកំណត់និយមន័យ បែងចែកតាមវិស័យសំខាន់ៗ .....................................៨
២.១.២.២. និយមន័យសហគ្រាសខ្នាតតូចនិងមធ្យម(SME) របស់សហរដ្ឋអាមេរិក........................១០
២.១.២.៣. និយមន័យ សហគ្រាសខ្នាតតូចនិងមធ្យម(SME) របស់កាណាដា ..............................១០
២.១.២.៤. តួនាទីរបស់អាជីវកម្មចជាលក្ខណៈគ្រួសារ .................................................. ១១
២.១.២.៥. លក្ខណៈនៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ........................................ ១១
២.១.៣. ពន្យល់ពាក្រកន្លឹះ .................................................................................១៣
២.១.៤. អំពីក្រមា.............................................................................................១៣
២.២. ទ្រឹស្តី.................................................................................................. ១៤
២.២.១. សិប្បកម្ម.............................................................................................១៤

២.២.២. ក្រមាផ្សាភ្ជាប់ជាមួយក្បាច់គុនល្បុក្កតោ ..... ១៥
២.៣. ប្រវត្តិនៃក្រមា និងប្រវត្តិនៃការតម្បាញ ..... ១៦
២.៣.១. ប្រវត្តិនៃក្រមាខ្មែរ ..... ១៦
២.៣.២. ក្រមា - និមិត្តសញ្ញាជាតិខ្មែរ ..... ១៧
២.៣.៣. ក្រមាជានិមិត្តរូបនៃកម្លាំងរបស់កម្ពុជា ..... ១៨
២.៣.៤. ប្រវត្តិនៃការត្បាញក្រមា ..... ១៨
២.៤. ការវិវត្តន៍នៃការតម្បាញក្រមា ..... ១៩
២.៤.១. ការវិវត្តន៍នៃរបៀបតម្បាញពីមួយសម័យកាលទៅមួយសម័យកាល ..... ២០
២.៤.១.១. ការត្បាញតាមបែបប្រពៃណី (កីបុរាណ) ..... ២០
២.៤.១.២. ការត្បាញតាមបែបទំនើប (កីស្វ័យប្រវត្តិ) ..... ២១
២.៤.២. ការវិវត្តន៍នូវរបៀបប្រើប្រាស់របស់មនុស្ស ..... ២៣
២.៤.២.១. ការប្រើប្រាស់របស់មនុស្សសម័យដើម ..... ២៣
២.៤.២.២. ការប្រើប្រាស់ក្រមារបស់ខ្មែរបច្ចុប្បន្ន ..... ២៤

**ជំពូកទី៣៖ ស្ថានភាពទូទៅនៃសិប្បកម្មក្រមានៅភូមិជ្រោយអំពិល**

៣.១. ទីតាំងភូមិសាស្ត្រនៃសិប្បកម្មផលិតក្រមា ..... ២៦
៣.២. ករណីសិក្សាស្រាវជ្រាវភូមិជ្រោយអំពិល ..... ២៦
៣.២.១. ប្រវត្តិទីតាំងភូមិសាស្ត្រ ..... ២៦
៣.២.២. ប្រជាជន ..... ២៨
៣.២.៣. ស្ថានភាពគ្រួសារប្រកបរបរសិប្បកម្មតម្បាញក្រមា ..... ២៨
៣.២.៣.១. ទិន្នន័យ និងស្ថានភាពគ្រួសារសិប្បករ ..... ២៩
៣.២.៣.២. ស្ថានភាពគ្រួសារសិប្បករមួយចំនួន ..... ៣០
ក. គ្រួសារអ្នកស្រី ផៃ ផាន់នី ..... ៣០
ខ. គ្រួសារអ្នកស្រី ផៃ ចាន់ធី ..... ៣១
គ. អ្នកស្រី បាន សុផល ..... ៣១
ឃ. លោក សៀម ហេង ..... ៣២

៣.២.៤. ប្រភេទ និងទំហំ ក្រមាក្នុងភូមិជ្រោយអំពិល ..........៣៣
៣.២.៤.១. ក្រមាវិញជាយខ្នាតតូច .......... ៣៤
៣.២.៤.២. ក្រមាវិញជាយខ្នាតធំ .......... ៣៤
៣.២.៤.៣. ក្រមាអំបោះឆៅ .......... ៣៥
៣.២.៤.៤. ក្រមាអំបោះហុង.......... ៣៥
៣.២.៥. ស្ថានភាពទីផ្សារ.......... ៣៥
៣.២.៦. ករណីទីផ្សារក្រមាក្នុងភូមិជ្រោយអំពិល .......... ៣៦
៣.២.៧. តម្លៃទីផ្សារក្រមា..........៣៧
៣.២.៨. ទីផ្សារក្នុងសម័យកាល COVID-19..........៣៧

## ជំពូកទី៤៖ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៤.១. គុណសម្បត្តិលើវិស័យសិប្បកម្មក្រមាខ្មែរ .......... ៣៩
៤.១.១. ផ្តល់ឱកាសការងារដល់ប្រជាជន (ករណីភូមិជ្រោយអំពិល).......... ៣៩
៤.១.២. អភិវឌ្ឍន៍ក្នុងតំបន់ (ករណីភូមិជ្រោយអំពិល)..........៤១
៤.១.២.១. កាត់បន្ថយភាពក្រីក្រ ..........៤១
៤.១.២.២. ការអភិវឌ្ឍមូលដ្ឋាន ..........៤២
៤.២. បញ្ហាប្រឈមនៃវិស័យសិប្បកម្មក្រមា .......... ៤២
៤.២.១. កត្តាបញ្ហាគ្មានទីផ្សារ ..........៤២
៤.២.១.១. កំឡុងឆ្នាំដែលទីផ្សារធ្លាក់ចុះខ្លាំង .......... ៤៣
ក. ឆ្នាំ២០១០ និង២០១១ .......... ៤៣
ខ. ឆ្នាំ២០២០ ដល់២០២២ ..........៤៤
៤.២.២. កត្តាវត្ថុធាតុដើម..........៤៥
៤.២.២.១. បញ្ហាអំបោះ..........៤៥
៤.៣. ដំណោះស្រាយ ..........៤៦
៤.៣.១. ដំណោះស្រាយមួយចំនួនរបស់រដ្ឋាភិបាល ..........៤៦
៤.៣.២. គំនិតឆ្នៃប្រឌិតរបស់ប្រជាពលរដ្ឋផ្ទាល់ ..........៤៧

## ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

៥.១. សេចក្ដីសន្និដ្ឋាន ........................................................................................................ ៤៨

៥.២. ការផ្ដល់អនុសាសន៍ ........................................................................................................ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

ពាក្យកាត់

| | |
|---|---|
| SMEs | : Small and Medium-sized Enterprises សហគ្រាសធុនតូច និងមធ្យម |
| MSMEs | : Micro Small and Medium Enterprises មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| NAICS | : North American Industry Classification System |
| SBA | : Small Business Administration |
| COVID-19 | : Coronavirus disease of 2019 |
| WHO | : World Health Organization |

# បញ្ជីតារាង

**ទំព័រ**

តារាងទី១៖ និយមន័យ MSME នៅកម្ពុជា ........................................................................................៨
តារាងទី២៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់វិស័យកសិកម្ម ..............................៨
តារាងទី៣៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់សម្រាប់វិស័យឧស្សាហកម្ម .............៩
តារាងទី៤៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ..........................................................................................................................................៩
តារាងទី៥៖ តារាងក្រាហ្វិចចំនួនគ្រួសារប្រជាជនដែលប្រកបរបរក្រមាក្នុងភូមិជ្រោយអំពិល .....................២៨
តារាងទី៦៖ តារាងទិន្នន័យនៃស្ថានភាពគ្រួសាទាំង២០គ្រួសារ .........................................................២៩
តារាងទី៧៖ តារាងទិន្នន័យតម្លៃក្រមាក្នុងភូមិជ្រោយអំពិល ..............................................................៣៧

# បញ្ជីរូប

**ទំព័រ**


រូបភាពទី១ ៖ ការត្បាញក្រមាជាមួយកីបុរាណ ........................................................................២១

រូបភាពទី២ ៖ ការត្បាញក្រមាជាមួយកីស្វ័យប្រវត្តិ ....................................................................២២

រូបភាពទី៣ ៖ ក្រមាដែលជាកាដូរសម្រាប់ជូនដល់ភ្ញៀវកិត្តិយស ចូលរួមក្នុងកម្មពិធីអាពាហ៍ពិពាហ៍...........២៥

រូបភាពទី៤៖ ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ផាន់នី.........................................................................៣០

រូបភាពទី៥៖ ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ចាន់ធី.........................................................................៣១

រូបភាពទី៦ ៖ ការចុះសម្ភាសន៍ជាមួយលោក សៀម ហេង...................................................................៣៣

រូបភាពទី៧៖ ក្រមាវិញជាយខ្នាតតូច។ មានទំហំបណ្តោប្រវែង ១.៦០ម៉ែត្រ និងទទឹងប្រវែង ០.៤០ម៉ែត្រ.......៣៤

រូបភាពទី៨ ៖ ក្រមាវិញជាយខ្នាតធំ។ មានទំហំបណ្តោយប្រវែង ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៧០ម៉ែត្រ.....៣៤

រូបភាពទី៩ ៖ ក្រមាអំបោះឆៅ។ មានទំហំបណ្តោយប្រវែង  ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៨៥ម៉ែត្រ...........៣៥

រូបភាពទី១០ ៖ ក្រមាអំបោះហុង។ មានទំហំបណ្តោយប្រវែង  ១.៧០ម៉ែត្រ និងទទឹងប្រវែង ០.៨០ម៉ែត្រ.......៣៥

រូបភាពទី១១៖ ការចុះសម្ភាសន៍ជាមួយ លោក លី កំសាន្ត ...............................................................៣៨

រូបភាពទី១២៖ ការចុះសម្ភាសន៍ជាមួយ លោកមេភូមិ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ.......................៣៩

# ជំពូកទី១៖ សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហា

ក្នុងពេលបច្ចុប្បន្ននេះ ក្រមាគឺជាផ្នែកមួយនៃការជម្រុញកំណើនសេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋ ហើយក៏ជាផ្នែកមួយក្នុងការជម្រុញកំណើនសេដ្ឋកិច្ចជាតិទាំងមូល។ ដោយប្រទេសមានការអភិវឌ្ឍ ទីផ្សារក្រមាខ្មែរក៏មានភាពរីកចម្រើនដោយមានការទិញដូរទាំងក្នុងនឹងក្រៅប្រទេស។ ប្រជាជនខ្មែរគ្រប់ៗរូបសុទ្ធសឹងតែបានដឹង និងស្គាល់ពីក្រមាខ្មែរ និងអត្ថប្រយោជន៍របស់វា។ ក្រមាជាវត្ថុដែលជាតម្រូវការប្រើប្រាស់ចាំចាច់មួយផ្នែកក្នុងការរស់នៅរបស់ប្រជាជនខ្មែរ ដែលយើងតែងតែឃើញមានដាក់ជាប់ខ្លួន និងយកជាប់ជាមួយស្ទើរតែគ្រប់ទីកន្លែង ហើយឥរិយាបទបែបនេះ មានតាំងពីសម័យដើមរហូត មកដល់បច្ចុប្បន្ននេះ។

ក្រមា ក៏ជាកត្តាមួយដែលបាន ដើរតួនាទីយ៉ាងសំខាន់ក្នុង ការជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ ដោយបានជួយកាត់បន្ថយនូវភាព ក្រីក្ររបស់ប្រជាពលរដ្ឋ និងកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេស ឬបរទេស តាមរយៈការបង្កើនការងារដល់ប្រជាពលរដ្ឋក្នុងស្រុក។ ប្រជាពលរដ្ឋខ្មែរ អាចទទួលបានការងារពីវិស័យសិប្បកម្មក្រមានេះតាមរយៈការស៊ីឈ្នួលត្បាញ ការត្បាញលក់ដោយខ្លួនឯង ការដូរញដូរក្រមា (ឈ្មួញកណ្តាល) អ្នកលក់បោះដុំ លក់រាយ និងជាងតម្លើង, ជួសជុលកី។

លើសពីនេះ ជីវភាពក្នុងការរស់នៅ របស់ប្រជាពលរដ្ឋខ្មែរជាច្រើនដែលបានប្រកបមុខរបរដែលទាក់ទងទៅនឹងវិស័យសប្បកម្មក្រមានេះ កាន់តែមានភាពប្រសើរឡើងពីមួយសម័យកាលទៅមួយសម័យកាល។ ប៉ុន្តែ ដោយសម័យកាលមានការរីកចម្រើននៃបច្ចេកវិទ្យា ក៏បានធ្វើអោយបរិបទក្នុងការរស់នៅរបស់មនុស្សបច្ចុប្បន្ន មានការផ្លាស់ប្តូរ ក៏បានជះឥទ្ធិពលអវិជ្ជាមានមួយចំនួនធំដល់វិស័យសប្បកម្មក្រមាផងដែរ។

ចំពោះការរៀបរាប់ខាងលើបានបង្ហាញថា វិស័យសប្បកម្មតម្បាញក្រមា ពិតជាមានសារៈប្រយោជន៍ចំពោះជីវភាព របស់ប្រជាពលរដ្ឋ ព្រមទាំងជំរុញអោយសេដ្ឋកិច្ចមានភាពរីកចម្រើន។ ដូចនេះក្រុមយើងខ្ញុំបានជ្រើសរើសប្រធានបទ សិប្បកម្មក្រមាខ្មែរ និងចុះកម្មសិក្សានៅភូមិជ្រោយអំពិលជាភូមិដែរមានប្រជាជនរស់ពឹងផ្អែកលើសិប្បកម្មតម្បាញក្រមា។

## ១.២. ចំណោទបញ្ហា

ប្រទេសកម្ពុជាយើងសព្វថ្ងៃកំពុងមានការអភិវឌ្ឍន៍ជឿនលឿនលើគ្រប់វិស័យ ក្នុងនោះវិស័យសិប្បកម្មក្រមាក៏ជា វិស័យមួយដែលកំពុងមានការរីកចម្រើន គួរអោយកត់សម្គាល់ ប៉ុន្តែក្នុងនោះវា ក៏ជាវិស័យមួយដែលមានបញ្ហាប្រឈមច្រើនដែរ ពិសេសវិស័យសិប្បកម្មក្រមាខ្មែរនេះ។ សិប្បកម្មតម្បាញក្រមាខ្មែរ ពិតជាមានការរីកចម្រើនខ្លាំង ដោយយើងបានសង្កេតឃើញថាវិស័យនេះមានការអភិវឌ្ឍលើគ្រប់ទម្រង់ទាំងឧបករណ៍សម្រាប់តម្បាញ វិធីសាស្ត្រក្នុងការតម្បាញ និងទីផ្សារផង ពិសេសវិធីសាស្ត្រក្នុងការប្រើប្រាស់តែម្តង។

នៅក្នុងភាពជោគជ័យនៃការ រីកចម្រើនទាំងនេះ វិស័យសិប្បកម្មក្រមា ក៏មានបញ្ហាចោទជាច្រើន ដែលសិប្បករតម្បាញក្រមាស្ទើរតែទាំងអស់ កំពុងជួបប្រទះដូចជា បញ្ហាទីផ្សារនេះតែម្តង ដែលជាបញ្ហាធំសម្រាប់វិស័យសិប្បកម្មក្រមាខ្មែរនេះតែម្តង។ បញ្ហាទីផ្សារដែល សិប្បករកំពុងជួបប្រទះ គឺប្រជាពលរដ្ឋនាសម័យបច្ចុប្បន្ននេះ បើទោះបីជាការប្រើនៅមានការនិយមមកធ្វើជាសម្លៀកបំពាក់ តែក៏នៅតែមិនដូចមុនឡើយ ស្ទើរតែបោះបង់ការប្រើប្រាស់ ក្រមាដោយជ្រើសរើសការប្រើប្រាស់ ផលិតផលនាំចូលជំនួសវិញដូចជា ប្រភេទកន្សែងនាំចូលពីប្រទេសក្រៅមកប្រើប្រាស់ជាប្រចាំថ្ងៃនៅតែច្រើនជាងការប្រើប្រាស់ក្រមា ហើយការនាំចេញក៏មានកម្រិត ទើបបានធ្វើអោយវិស័យសិប្បកម្មក្រមាមានពុំសូវមានសន្ទុះ និងមិនមានលំនឹងទីផ្សារដែលជាហេតុផលធ្វើអោយប៉ះពាល់ដល់ជីវភាពប្រជាជន។

ដូចនេះទើបធ្វើអោយយើងសម្រេចលើកសំណួរដូចខាងក្រោម៖

១. តើសិប្បកម្មតម្បាញក្រមាមានដំណើរការវិវត្តយ៉ាងដូចម្តេច?

២. តើវិស័យសិប្បកម្មក្រមាខ្មែរមានឥទ្ធិពលយ៉ាងដូចម្តេចមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា?

៣. តើមានយុទ្ធសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយចំពោះបញ្ហាទីផ្សារក្រមាខ្មែរ?

## ១.៣. គោលបំណងក្នុងការស្រាវជ្រាវ

មូលហេតុដែលក្រុមយើងខ្ញុំជ្រើសយកករណីការស្រាវជ្រាវ លើប្រធានបទនេះព្រោះក្រុមយើងខ្ញុំពិតជាបានសម្លឹងឃើញចំណុចចំបងមួយចំនួន ដែលពួកយើងចង់ស្វែងយល់ បន្ថែមអោយបានកាន់តែស៊ីជម្រៅ និងច្បាស់លាស់ ហើយចង់កែលំអនៅចំណុចមួយចំនួនដែលជាបញ្ហាចោទនាំអោយវិស័យសិប្បកម្មក្រមានេះរងនូវផលប៉ះពាល់ជាច្រើន។

ដូចនេះក្រុមយើងខ្ញុំមានបំណងចង់ស្វែងយល់ និងស្វែងរកដំណោះស្រាយ ពិសេសយើងបានសម្លឹងឃើញថាវិស័យសិប្បកម្មតម្បាញក្រមានេះមានការថយចុះ និងពុំសូវមានទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងក្រមានេះគ្រប់គ្រាន់សម្រាប់មនុស្សជំនាន់ក្រោយស្វែងយល់ដូចជាក្រុមនិសិត្សដែរចង់ស្រាវជ្រាវតែគ្មានទិន្នន័យ ជាហេតុដែលធ្វើអោយក្រុមពួកយើងចង់ថែរក្សា និងអភិរក្សនូវសិប្បកម្មក្រមានេះដោយការស្រាវជ្រាវមកចង់ក្រងទុកជាទិន្នន័យមិនអោយបាត់បង់ និងរក្សាទុកសម្រាប់មនុស្សជំនាន់ក្រោយបានយល់ដឹងបន្តទៀត។

គោលបំណងចម្បងសំខាន់ៗរបស់ក្រុមយើងខ្ញុំមានដូចជា៖

១. មានចំណងក្នុងការអភិរក្ស និងផ្សព្វផ្សាយអំពីក្រមាខ្មែរ

២. សិក្សាពីស្វែងយល់ពីដំណើរការវិវត្តនៃក្រមាខ្មែរ

៣. ស្វែងយល់ពីផលហេតុនៃការរាំងស្ទះទីផ្សារ

៤. វិភាគនិងស្វែងរកដំណោះស្រាយលើបញ្ហាទីផ្សារ

## ១.៤. ទំហំ និងដែនកំណត់ក្នុងការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវលើប្រធានបទសិប្បកម្មក្រមាខ្មែរនេះ ក្រុមយើងខ្ញុំបានផ្តោតលើការរីកចម្រើន និងការអភិវឌ្ឍនៃការផលិតក្រមាខ្មែរ សិក្សាលើជីវភាពប្រជាពលរដ្ឋដែលប្រកបរបរតម្បាញក្រមានេះ។ ជាពិសេសយើងសិក្សាទៅលើបញ្ហាប្រឈមដែលសិប្បករកំពុងជួបប្រទះសព្វថ្ងៃ រួចពិភាក្សារកដំណោះស្រាយ និងផ្តល់ជាអនុសាសន៍ទៅលើ បញ្ហាប្រឈមនេះ។ ករណីសិក្សាចំពោះប្រធានបទនេះ គឺយើងបានជ្រើសរើសយកតំបន់សិប្បកម្មមួយកន្លែងដែលជាតំបន់ដែលសម្បូរដោយអ្នកផលិតក្រមាតាំងពី សម័យដើមមក គឺស្ថិតនៅក្នុង ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

## ១.៥. វិធីសាស្រ្តក្នុងការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ របស់ពួកយើង យើងនឹងធ្វើការប្រមូលទិន្នន័យមួយចំនួនតូចពី INTERNET និងសៀវភៅ រួចយើងក៏នឹងប្រមូលទិន្នន័យដោយការសាកសួរផ្ទាល់ពីសិប្បករតម្បាញ ឈ្មួញអាជីវកម្ម និងអ្នកគ្រប់គ្រងតំបន់ (ប្រធានភូមិ ឃុំ សង្កាត់) ដើម្បីទទួលបានទិន្នន័យជាក់លាក់។ បន្ទាប់មកយើងនិងប្រមូលរៀបចំទិន្នន័យទាំងនេះមកវិភាគ និងបកស្រាយ ហើយផ្តល់នូវអនុសាសន៍ទៅតាមចំណោទបញ្ហាខាងលើង រួចយើងនិងសន្និដ្ឋានពីលទ្ធផល។

នៅក្នុងការស្រាវជ្រាវអំពីប្រធានបទសិប្បកម្មក្រមាខ្មែរនេះ ក្រុមយើងខ្ញុំបាន ជ្រើសរើសប្រើប្រាស់វិធីសាស្រ្តស្រាវជ្រាវចំនួនពីរប្រភេទគឺ ទិន្នន័យបឋម (primary date) និងទិន្នន័យបន្ទាប់បន្សំ (secondary date) ដែលធ្វើឡើងតាមរបៀបពិពណ៌នាពន្យល់៖

- ❖ ទិន្នន័យបឋម (primary data) ៖
  - ក្រុមយើងខ្ញុំបានបង្កើតកម្រងសំណួរដើម្បីជំនួយដល់ការប្រមូលទិន្នន័យអោយកាន់តែមានភាពងាយស្រួល និងចំណាយពេលតិច។
  - យើងក៏បានធ្វើការជួបសម្ភាសន៍ ដោយផ្ទាល់ជាមួយលោក គឹម ស៊ុន ដែលជាប្រធានភូមិជ្រោយអំពិល។
  - មានការចុះជួបដោយផ្ទាលជាមួយសិប្បករ ដែលជា ម្ចាស់សិប្បកម្ម ដែលប្រកបរបរតម្បាញក្រមាក្នុងភូមិនោះដើម្បីសួរព័ត៌មានអំពីកម្រិតជីវភាព និងបញ្ហាប្រឈមផ្សេងៗ កំឡុងពេលប្រកបរបរតម្បាញក្រមានេះ។
  - ទទួលបានការណែនាំបន្ថែមពីសាស្រ្តចារ្យបណ្ឌិត ឈុន ពហុ ជាសាស្រ្តចារ្យដឹក កែតម្រូវ និងផ្តល់ជាមតិយោបលក្នុងការច្នៃប្រឌិតបន្ថែម។

❖ ទិន្នន័យបន្ទាប់បន្សំ(secondary data)

ទិន្នន័យបន្ទាប់បន្សំ គឺជាប្រភេទទិន្នន័យដែលប្រមូលបានតាមរយៈសៀវភៅឯកសារផ្សេងៗជាច្រើនដូចជា៖

- ឯកសារបណ្ណាល័យ និងឯកសារដែលទាញយកពីអ៊ីនធឺណេត។
- សៀវភៅសារណា របាយការណ៍បញ្ចប់ការសិក្សា ក្នុងសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវលើប្រធានបទសិប្បកម្មក្រមានេះបានផ្តល់សារៈសំខាន់ជាច្រើនមកដល់ក្រុមយើងខ្ញុំដែលបានធ្វើកម្មសិក្សាលើប្រធានបទនេះ៖

- ផ្តល់នូវបទចំណេះដឹង និងបទពិសោទន៍លើការស្វែងយល់ពីការអភិវឌ្ឍក្នុងតំបន់
- ទទួលបានចំណេះដឹងថ្មី ពីការពន្យល់ណែនាំពីសាស្ត្រាចារ្យពីរបៀបប្រមូល មកចងក្រង និងចេះវិភាគអំពីទិន្នន័យដែលត្រូវសិក្សា
- ទទួលបាននូវបទពិសោធន៍ជាច្រើន លើការគ្រប់គ្រងជីវភាព និងរបៀបដោះស្រាយនូវគ្រប់បញ្ហាដែលប្រជាជនបានជួបប្រទះក្នុងកំឡុងពេលដែលបានប្រកបរបរតម្បាញក្រមានេះ
- ទទួលបានចំណេះនិងជំនាញ លើការប្រកបអាជីវកម្មលក្ខណៈគ្រួសារ
- លិទ្ធិផលនៃការស្រាវជ្រាវនេះនិងត្រូវរក្សាទុកជាឯកសាសម្រាប់ ជំនួយស្មារតីដល់និសិត្សជំនាន់ក្រោយបានសិក្សាស្វែងយល់បន្ថែមអំពីការអភិវឌ្ឍនៃវិស័យសិប្បកម្មក្រមាខ្មែរ។
- របាយការណ៍ដែលពួកយើងបានសិក្សាស្រាវជ្រាវនេះ ក៏អាចផ្សព្វផ្សាយអំពីក្រមាខ្មែរ និងសិប្បកម្មក្រមាខ្មែររបស់ប្រជាពលរដ្ឋក្នុងភូមិជ្រោយអំពិល អោយមានអ្នកស្គាល់កាន់តែច្រើន ដែលជាផលល្អដោយជួយបង្កើនការលក់របស់ប្រជាពលរដ្ឋ។

## ១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ប្លង់នៃការសិក្សាស្រាវជ្រាវនេះចែកចេញជា ៥ជំពូករួមមាន៖

- **ជំពូកទី១៖ សេចក្តីផ្តើម**
    - លំនាំដើម
    - ចំណោទបញ្ហា
    - គោលបំណងនៃការស្រាវជ្រាវ
    - ទំហំ និងដែនកំណត់
    - វិធីសាស្ត្រក្នុងការស្រាវជ្រាវ

- សារៈសំខាន់នៃការស្រាវជ្រាវ
- រចនាសម្ព័ន្ធស្រាវជ្រាវ

• **ជំពូកទី២៖ រំលឹកទ្រឹស្តី**

- និយមន័យ
- ទ្រឹស្តី
- ប្រវត្តិនៃក្រមា និងប្រវត្តិនៃការតម្បាញ
- ការវិវត្តន៍នៃការតម្បាញក្រមា

• **ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ**

គឺជាការបង្ហាញលទ្ធផលដែលទទួលបានពីការចុះកម្មសិក្សានៅ ក្នុងតំបន់សិប្បកម្មផ្ទាល់តែម្តង ។

- ទីតាំងភូមិសាស្ត្រនៃសិប្បកម្មផលិតក្រមា
- ករណីសិក្សាស្រាវជ្រាវភូមិជ្រោយអំពិល

• **ជំពូកទី៤៖ ការពិភាក្សាលើលទ្ធផលទទួលបាន**

ការពិភាក្សាអំពីរបាយការណ៍ស្រាវជ្រាវដែលទទួលបាន និងផ្តោតលើការពិភាក្សាអំពីបញ្ហាទីផ្សារ។

- គុណសម្បត្តិលើវិស័យសិប្បកម្មក្រមាខ្មែរ
- បញ្ហាប្រឈមនៃវិស័យសិប្បកម្មក្រមា
- ដំណោះស្រាយ

• **ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

- សេចក្តីសន្និដ្ឋាន ធ្វើការសន្និដ្ឋានដោយផ្អែកទៅតាមការវិភាគទិន្នន័យ និងការវិភាគលើលទ្ធផលដែលទទួលបាន។
- អនុសាសន៍ ធ្វើការបញ្ចេញមតិយោបលរបស់ក្រុមយើងខ្ញុំ ក្នុងការចូលរួមអភិរក្ស និងផ្សព្វផ្សាយបង្កើនទីផ្សារ ដើម្បីទទួលបានប្រសិទ្ធភាពបន្ថែមទៀតលើទីផ្សារ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១. និយមន័យ

### ២.១.១. សិប្បកម្ម

សិប្បកម្ម គឺជាសិល្បៈនិងបច្ចេកទេសនៃការធ្វើវត្ថុឬផលិតផលដោយដៃដោយមិនមានអន្តរាគមន៍ពីម៉ាស៊ីនតិចតួចឬគ្មានហើយយោងតាមវិធីសាស្ត្រ ប្រពៃណី។ ក្នុងន័យនេះសិប្បកម្មគឺការងារធ្វើដោយដៃជាមួយវត្ថុធាតុដើមជាទូទៅមកពីតំបន់ ដែលសិប្បកររស់នៅដោយប្រើវិធី និងបច្ចេកទេស ដែលជាមរតកអរូបិយនៃសហគមន៍វប្បធម៌ជាក់លាក់របស់ពួកគេ។

សិប្បកម្ម គឺជាការប្រើប្រាស់កំលាំង មនុស្សតិចគ្មានម៉ាស៊ីន ឬម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ ដែលនាំអោយផលិតផលទទួលបានតិចតួច ហើយជាការងារ ឬសកម្មភាពដែលត្រូវការជំនាញ និងបទពិសោធន៍ច្បាស់លាស់។

### ២.១.២. និយមន័យការគ្រប់គ្រងអាជីវកម្មខ្នាតតូចលក្ខណៈគ្រួសារ

សហគ្រាសធុនតូច និងមធ្យម ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាទៅតាម បរិបទប្រទេសនីមួយៗ។ ជាទូទៅ ការកំណត់និយមន័យរបស់សហគ្រាស ធុនតូច និងមធ្យម គឺធ្វើឡើងដោយផ្អែកលើចំនួននិយោជិត (និយោជិតដែល ធ្វើការពេញម៉ោង) និងផលរបរប្រចាំឆ្នាំ ឬទំហំទ្រព្យសកម្មរបស់ស្ថាប័ន។ យោងតាមលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៣៦សជណ.ហធ ស្តីពី ករណីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយលើកស្ទួយ សហគ្រាសធុនតូច និងមធ្យម លើកទី២ រាជរដ្ឋាភិបាលបានសម្រេចកំណត់ និយមន័យ «សហគ្រាសធុនតូច និងមធ្យម» ដោយបែងចែកជា ៣ វិស័យ រួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យសេវាកម្ម និងពាណិជ្ជកម្ម។ វិស័យនីមួយៗត្រូវភ្ជាប់នូវលក្ខខណ្ឌតម្រូវ ២ គឺ៖ ១). ចំនួនបុគ្គលិក និង២). ទំហំផលរបរប្រចាំឆ្នាំ ឬ ទំហំទ្រព្យសកម្ម។ សម្រាប់លក្ខខណ្ឌទី២ ក្រសួង ស្ថាប័នពាក់ព័ន្ធអាចប្រើប្រាស់លក្ខខណ្ឌណាមួយក៏បាន ប៉ុន្តែករណីផលរបរ ប្រចាំឆ្នាំ និងទ្រព្យសកម្មមិនមានសង្គតិភាពក្នុងការកំណត់សហគ្រាសជា SMEs ត្រូវយកលក្ខខណ្ឌដែលមានកម្រិតខ្ពស់ជាងគេ។

និយមន័យរបស់ MSMEs អាចមានការបម្រែបម្រួលពីប្រទេសមួយទៅប្រទេសមួយទៀត អាស្រ័យលើវិស័យដែលពាក់ព័ន្ធ និងមិនមានលក្ខណៈជាសកលទេ វាប្រែប្រួលទៅតាមប្រទេស និងវិស័យដែលគេត្រូវសិក្សា។ ប្រទេសខ្លះបែងចែក តាមចំនួននិយោជិត ទ្រព្យរបស់ក្រុមហ៊ុន ហើយខ្លះទៀតផ្អែកទៅលើទំហំនៃផលចំណូលសរុបប្រចាំឆ្នាំ។ សម្រាប់ លក្ខណៈវិនិច្ឆ័យចុងក្រោយ ប្រទេសភាគច្រើនប្រើរូបិយប័ណ្ណក្នុងស្រុក។ ក្នុង

ករណីដែលតម្លៃប៉ិយប័ណ្ណត្រូវបានគិតចំពោះទ្រព្យសម្បត្តិ ឬផលចំណូល អតិផរណាអាចជាមូលហេតុនាំឱ្យមានបញ្ហាសម្រាប់និយមន័យរបស់ MSMEs។[1]

សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) តែងត្រូវបានចាត់ទុកថាជាក្បាលម៉ាស៊ីននៃកំណើននៅក្នុងបណ្តា ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ដោយសារការរួមចំណែករបស់វានៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង បង្កើតការងារក្នុងប្រទេស។ នៅប្រទេសកម្ពុជា សហគ្រាសធុនមីក្រូ តូច និងមធ្យម តំណាងឱ្យ ៧០% នៃការងារសរុប ៩៩,៨% នៃចំនួនក្រុមហ៊ុនសរុប និងរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបចំនួន ៥៨%។ របៀបកំណត់និយមន័យសហគ្រាសធុនមីក្រូ តូច និងមធ្យមមានសារៈសំខាន់ចំពោះ លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងកម្មវិធីជំនួយគាំទ្ររបស់កម្ពុជាដែលផ្តោតជាពិសេសលើសហគ្រាស។

សហគ្រាសធុនតូច និងមធ្យម(SMEs) គឺជាផ្នែកមួយដែលសំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាដែលរួម ចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដែល បង្កើតឡើងដោយអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យមនៃគណៈកម្មាធិការដឹកនាំវិស័យឯកជនចាត់ថ្នាក់សហគ្រាសធុនតូច និងមធ្យមទៅតាមចំនួនបុគ្គលិក និងទំហំទ្រព្យសម្បត្តិ។

ប្រទេសកម្ពុជាមាននិយមន័យផ្លូវការនៃសហគ្រាសធុនតូច និងមធ្យម ដែលត្រូវបានរៀបរៀងឡើងក្រោមក្របខណ្ឌ អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០០៥។ និយមន័យនេះបែងចែកសហគ្រាសតាម ទំហំ និងរួមបញ្ចូល លក្ខណៈវិនិច្ឆ័យសម្រាប់ទាំងចំនួនការងារ និងចំណូល។ យោងតាមលទ្ធផលនៃកិច្ច ប្រជុំគណៈកម្មាធិការ សកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (SMEPC) លើកទី២ នៅទីស្តីការ គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ សហគ្រាសធុនតូច និងមធ្យមត្រូវបាន ចែកចេញជា ៣ វិស័យ គឺ (១) កសិកម្ម (២) ឧស្សាហកម្ម និង (៣) សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសធុនតូច និងមធ្យមត្រូវបំពេញតាមលក្ខខណ្ឌពីរ៖ (ក) ចំនួនបុគ្គលិក (ខ)ផលរបរប្រចាំឆ្នាំ ឬទ្រព្យសកម្ម។[2]

- សហគ្រាសធុនតូច សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀលដល់៧០០លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូចស្របតាមច្បាប់និងបញ្ញត្តិស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ពី១០ទៅ៥០នាក់។
- សហគ្រាសធុនមធ្យម សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៧០០ លានរៀលដល់៤០០០លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ

[1] https://www.unescap.org/sites/default/files/7 - SMEs IN ASIA AND THE PACIFIC.pdf. Retrieved on 06-09-2018.

[2] គេហទំព័រ KhmerSME. *សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យឧស្សាហកម្ម*. khmersme.gov.kh/sme-in-industry/

ជាអ្នកជាប់ពន្ធតូចស្របតាមច្បាប់និងបញ្ញត្តិស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ ពី៥១ ទៅ ១០០ នាក់។[3]

ជាសរុបមក គិតមកត្រឹមដំណាច់ឆ្នាំ២០១៨នេះ យើងបាននិយមន័យ MSMEs នៅកម្ពុជាដូចក្នុងតារាងខាងក្រោមនេះ៖

តារាងទី១៖ និយមន័យ MSME នៅកម្ពុជា

| ចំណាត់ថ្នាក់ | បុគ្គលិក (នាក់) | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដីនិងប្រាក់លានរៀល) | ចំណូលប្រចាំឆ្នាំ (លានរៀល) |
|---|---|---|---|
| មីក្រូសហគ្រាស | < ១០ | < ២០០ | < ២៥០ |
| សហគ្រាសធុនតូច | ១០-៥០ | ចាប់ពី ២០០- តិចជាង ២៥០ | ចាប់ពី ២៥០-តិចជាង៧០០ |
| សហគ្រាសធុនមធ្យម | ៥១-១០០ | ចាប់ពី ២៥០-២០០០ | ចាប់ពី ៧០០-តិចជាង ២០០០ |
| សហគ្រាសធុនធំ | > ១០០ | > ២០០០ | > ២០០០ |

(ប្រភព៖ បូកសរុបដោយ បណ្ឌិត ព្រុំ ទេវី)

#### ២.១.២.១. ការកំណត់និយមន័យ បែងចែកតាមវិស័យសំខាន់ៗ

#### ក. សម្រាប់វិស័យកសិកម្ម

សហគ្រាសធុនតូចត្រូវបានកំណត់សម្រាប់ស្ថាប័ន ដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ ជាមួយនិងផលរបរប្រចាំឆ្នាំ ចាប់ពី ៦២ ២៥០ ដុល្លារទៅ ២៥០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់ សហគ្រាសធុនតូចត្រូវបានកំណត់ពី ៥០ ០០០ ទៅ ២៥០ ០០០ ដុល្លារ។ សហគ្រាសធុនមធ្យមត្រូវបានកំណត់ថាជាស្ថាប័នដែលមានបុគ្គលិក ចន្លោះពី ៥០ ទៅ ១៩៩នាក់ ដែលមានផលរបរប្រចាំឆ្នាំពី ២៥០ ០០១ ទៅ ១ ០០០ ០០០ ដុល្លារ។ ទំហំទ្រព្យសម្បត្តិសម្រាប់សហគ្រាសធុនមធ្យម ត្រូវបានកំណត់ពី ២៥០ ០០១ ទៅ ៥០០ ០០០ ដុល្លារ។

| ការពិពណ៌នា | បុគ្គលិក(នាក់) | ទំហំទ្រព្យសម្បត្តិ(គិតជាដុល្លា) | ផលរបរប្រចាំឆ្នាំ(គិតជាដុល្លា) |
|---|---|---|---|
| សហគ្រាសធុនតូច | ៥ ទៅ ៤៩ | ៥០,០០០ ទៅ ២៥០,០០០ | ៦២,២៥០ ទៅ ២៥០,០០០ |
| សហគ្រាសធុនមធ្យម | ៥០ ទៅ ១៩៩ | ២៥០,០០១ ទៅ ៥០០,០០០ | ២៥០,០០១ ទៅ ១,០០០,០០០ |

តារាងទី២៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់វិស័យកសិកម្ម

[3] សរសេរដោយ: បណ្ឌិត ព្រុំ ទេវី. (ខែមករា ឆ្នាំ២០១៩). *ទស្សនទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម នៅប្រទេសកម្ពុជា*. Retrieved from http://rac.gov.kh/royal-academy/research/attachments/original/21.pdf?1546423309

**ខ. សម្រាប់វិស័យឧស្សាហកម្ម**

សហគ្រាសធុនតូចត្រូវបានកំណត់ជាស្ថាប័ន ដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ និងមានផលរបរប្រចាំឆ្នាំចាប់ពី ៦២ ៥០០ ទៅ ៤០០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់សហគ្រាស ខ្នាតតូចត្រូវបានកំណត់ពី៥០០០០ ទៅ ៥០០០០០ដុល្លារ។សហគ្រាស ធុនមធ្យមត្រូវបានកំណត់សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥០ ទៅ ១៩៩នាក់ដែលមានផលរបរប្រចាំឆ្នាំពី ៤០ ០០០១ ទៅ ២ ០០០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់សហគ្រាសមធ្យមត្រូវបានកំណត់ពី ៥០០ ០០១ ទៅ ១ ០០០ ០០០ ដុល្លារ។

| ការពិពណ៌នា | បុគ្គលិក(នាក់) | ទំហំទ្រព្យសម្បត្តិ(គិតជាដុល្លា) | ផលរបរប្រចាំឆ្នាំ(គិតជាដុល្លា) |
|---|---|---|---|
| សហគ្រាសធុនតូច | ៥ ទៅ ៤៩ | ៥០,០០០ ទៅ ៥០០,០០០ | ៦២,៥០០ ទៅ ៤០០,០០០ |
| សហគ្រាសធុនមធ្យម | ៥០ ទៅ ១៩៩ | ៥០០,០០១ ទៅ ១,០០០,០០០ | ៤០០,០០១ ទៅ ២,០០០,០០០ |

តារាងទី៣៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់សម្រាប់វិស័យឧស្សាហកម្ម

**គ. សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម**

សហគ្រាសធុនតូចត្រូវបានកំណត់ សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ ដែលមានផល របរប្រចាំឆ្នាំចាប់ពី ៦២ ៥០០ ទៅ ២៥០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្ម សម្រាប់សហគ្រាសខ្នាតតូចត្រូវបានកំណត់ពី ៥០ ០០០ ទៅ ២៥០ ០០០ ដុល្លារ។ ខណៈដែលសហគ្រាសធុនមធ្យមត្រូវបានកំណត់សម្រាប់ស្ថាប័ន ដែលមានបុគ្គលិកចន្លោះពី ៥០ ទៅ ៩៩ នាក់ ដែលមានផលរបរប្រចាំឆ្នាំ ពី ២៥០ ០០១ ទៅ ១ ៥០០ ០០០ ដុល្លារ។ ទំហំទ្រព្យសម្បត្តិសម្រាប់ សហគ្រាសមធ្យមត្រូវបានកំណត់ពី ២៥០ ០០១ ទៅ ៥០០ ០០០ ដុល្លារ។

| ការពិពណ៌នា | បុគ្គលិក(នាក់) | ទំហំទ្រព្យសម្បត្តិ(គិតជាដុល្លា) | ផលរបរប្រចាំឆ្នាំ(គិតជាដុល្លា) |
|---|---|---|---|
| សហគ្រាសធុនតូច | ៥ ទៅ ៤៩ | ៥០,០០០ ទៅ ២៥០,០០០ | ៦២,៥០០ ទៅ ២៥០,០០០ |
| សហគ្រាសធុនមធ្យម | ៥០ ទៅ ៩៩ | ២៥០,០០១ ទៅ ៥០០,០០០ | ២៥០,០០១ ទៅ ១,៥០០,០០០ |

តារាងទី៤៖ សហគ្រាសធុនតូច និងមធ្យមដែលត្រូវបានកំណត់សម្រាប់សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម

**ឃ. អត្ថប្រយោជន៍សហគ្រាសធុនតូច និងមធ្យម**

សហគ្រាសធុនតូច និងមធ្យមបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ច និងសង្គមដូចជា៖

- ជំរុញកំណើនសេដ្ឋកិច្ច ដោយបានបង្កើនឱកាសការងារ និងបន្ថែម ចំណូលពន្ធ
- កាត់បន្ថយវិសមភាពប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ

- ជំរុញផលិតភាពជាតិដោយបានបង្កើនផលិតផល និងសេវាកម្មដែល អាចតម្រូវទីផ្សារក្នុងស្រុក និងអន្តរជាតិ
- ជំរុញសហគ្រិនភាពក្នុងប្រទេស
- ជំរុញនវានុវត្តន៍ដែលអាចបង្កើតជាគំនិតល្អៗ ក្នុងការដោះស្រាយបញ្ហា នានានៅក្នុងសង្គម។[4]

### ២.១.២.២. និយមន័យសហគ្រាសខ្នាតតូចនិងមធ្យម(SME) របស់សហរដ្ឋអាមេរិក

នៅសហរដ្ឋអាមេរិចនិយមន័យនៃសហគ្រាសធុនតូចនិងមធ្យមមានលក្ខណៈប្រែប្រួលតាមឧស្សាហកម្មដោយផ្អែកលើប្រព័ន្ធចំណាត់ថ្នាក់ឧស្សាហកម្មអាមេរិកខាងជើង (NAICS) ។ NAICS គឺជាប្រព័ន្ធមួយដែលបង្កើតឡើងដោយសហរដ្ឋអាមេរិកកាណាដានិងម៉ិកស៊ិកដើម្បីស្តារនិងសម្របសម្រួលការប្រមូលនិងវិភាគស្ថិតិអាជីវកម្ម។

រដ្ឋបាលធុរកិច្ចខ្នាតតូចរបស់សហរដ្ឋអាមេរិក (SBA) ផ្តល់ជូននូវតារាងនៃ ស្តង់ដារធុរកិច្ចខ្នាតតូចដែលត្រូវគ្នានឹងលេខកូដ NAICS ។ ដើម្បីត្រូវបានចាត់ទុកថាជាអាជីវកម្មខ្នាតតូចនិងមានសិទ្ធិដាក់ពាក្យសុំកិច្ចសន្យារបស់រដ្ឋាភិបាលនិងការផ្តល់មូលនិធិគោលដៅអាជីវកម្មមួយត្រូវតែស្ថិតនៅក្នុងដែនកំណត់ដែលបានកំណត់ទាក់ទងនឹងចំនួនបុគ្គលិកឬប្រាក់ចំណូល។

ក្នុងការផលិត ឧទាហរណ៍សហគ្រាសធុនតូចនិងមធ្យមត្រូវបានកំណត់ថាមានបុគ្គលិក 500 នាក់ឬតិចជាងនេះ ចំណែកឯនៅក្នុងការលក់ដុំវិញវាមានបុគ្គលិក 100 នាក់ឬតិចជាង។ ជួរនៅក្នុងវិស័យអាចប្រែប្រួលបន្តិច។ ឧទាហរណ៍នៅក្នុងវិស័យ ការជីកយករ៉ែ ការជីកយករ៉ែ និងការស្រង់ចេញប្រេង និងឧស្ម័នអាជីវកម្មមួយដែលពាក់ព័ន្ធនឹងរ៉ែស្ពាន់និងរ៉ែដែកនីកែលអាចមានបុគ្គលិកដល់ទៅ 1,500 នាក់ហើយនៅតែត្រូវបានគេចាត់ទុកថាជាសហគ្រាសធុនតូចនិងមធ្យម ដល់ 250 នាក់។

### ២.១.២.៣. និយមន័យ សហគ្រាសខ្នាតតូចនិងមធ្យម(SME) របស់កាណាដា

ឧស្សាហកម្មកាណាដាប្រើពាក្យសហគ្រាសខ្នាតតូចនិងមធ្យមដើម្បីសំដៅទៅលើអាជីវកម្មដែលមានបុគ្គលិកតិចជាង 500 នាក់ខណៈដែលចាត់ចំណាត់ថ្នាក់ក្រុមហ៊ុនដែលមាន 500 នាក់ឬច្រើនជាងនេះគឺជាអាជីវកម្មធំ។

ការទម្លាក់ចោលនិយមន័យសហគ្រាសធុនតូចនិងមធ្យមសហគ្រាសកាណាដាកំណត់អាជីវកម្មខ្នាតតូចមួយដែលមាននិយោជិកតិចជាង 100 នាក់ (ប្រសិនបើអាជីវកម្មគឺជាអាជីវកម្មផលិតទំនិញ) ឬបុគ្គលិកតិចជាង

[4] គេហទំព័រ មជ្ឈមណ្ឌលកម្ពុជា ៤.០. អ្វីទៅជាសហគ្រាសធុនតូច និងមធ្យម? តើសហគ្រាសធុនតូច និងមធ្យមមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ? https://cambodia4point0.org/kh/tech-for-sme.html

50 នាក់ (ប្រសិនបើអាជីវកម្មគឺជាអាជីវកម្មដែលមានមូលដ្ឋានលើសេវាកម្ម) ។ ក្រុមហ៊ុនដែលមានបុគ្គលិកច្រើនជាងការកាត់បន្ថយបុគ្គលិកទាំងនេះប៉ុន្តែបុគ្គលិកតិចជាង 500 នាក់ត្រូវបានចាត់ថ្នាក់ជាធុរកិច្ចមធ្យម។[5]

### ២.១.២.៤. តួនាទីរបស់អាជីវកម្មជាលក្ខណៈគ្រួសារ

អាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារមានតួនាទីក្នុងសេដ្ឋកិច្ចកម្ពុជាមួយចំនួនដូចជា៖

- ជួយអោយគ្រួសារប្រកបអាជីវកម្មខ្នាតតូច មានជីវភាពសមរម្យ។
- បង្កើនផលិតកម្មក្នុងស្រុក កាត់បន្ថយការនាំចូលមកពីបរទេស។
- ទំនិញ និងសេវាមានគុណភាព ទំនើប និងមានតម្លៃសមរម្យ។
- ជួយឲ្យជញ្ជីងពាណិជ្ជកម្មមានលំនឹង ព្រោះកាត់បន្ថយការនាំចូល រួចបង្កើនការនាំចេញ។
- កាត់បន្ថយហានិភ័យអតិផរណា ទំនិញ និងសេវាមិនងាយឡើងថ្លៃ។
- ផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងប្រទេសកាត់បន្ថយភាពគ្មានការងារធ្វើ។
- សេដ្ឋកិច្ចរបស់ប្រទេសមានស្ថេរភាព និងរីកចម្រើនប្រកបដោយចីរភាព។
- ប្រទេសមានការអភិវឌ្ឍច្រើនជាងពីមុន។

### ២.១.២.៥. លក្ខណៈនៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ

តាមនិយមន័យសិក្សានៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ មួយចំនួនអាចត្រូវបានរកឃើញ ពីអាជីវកម្មខ្នាតតូចអាចត្រូវបានសម្គាល់យ៉ាងងាយស្រួលគឺ សហគ្រាសធុនតូច និងមធ្យម។

ខាងក្រោមនេះ ជាលក្ខណៈមួយចំនួនរបស់អាជីវកម្មជាលក្ខណៈគ្រួសារ៖

- ដើមទុនទាប ៖ ដើមទុនទាប គឺជាលក្ខណៈពិសេសមួយនៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ។ ដើមទុននៃ អាជីវកម្មនេះមានកម្រិតតិចជាងសហគ្រាសធុនមធ្យម និងធំ។
- ផែនការក្នុងរយៈពេលខ្លី៖ លក្ខណៈពិសេសនៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ អាចត្រូវបានគេសង្កេត ឃើញនៅក្នុងការធ្វើផែនការ។ ផែនការអាជីវកម្មស្ទើរតែទាំងអស់គឺមានរយៈពេលខ្លី ដោយសារពួកគ ជាសហគ្រាសខ្នាតតូច និងត្រូវបានបង្កើតឡើងដើម្បីសម្រេចបាននូវគោលដៅរយៈពេលខ្លីតែប៉ុណ្ណោះ។

---

[5] Susan Ward. *និន្នាការសហគ្រាសធុនតូចនិងមធ្យម (សហគ្រាសធុនតូចនិងមធ្យម).* Retrieved from https://km.unitinal.com/%E1%9E%93%E1%9E%B7%E1%9E%93%E1%9F%92%E1%9E%93%E1%9E%B6%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%9F%E1%9E%A0%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F%E1%9E%92%E1%9E%BB%E1%9E%93%E1%9E%8F%E1%9E%BC%E1%9E%85/

- ភាពងាយស្រួលក្នុងការគ្រប់គ្រង៖ អាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ នេះងាយស្រួលគ្រប់គ្រងជាងអាជីវកម្មផ្សេងទៀត។ ដោយសារចំនួនកម្មករត្រូវបានកំណត់ត្រឹមអតិបរមា ៥០ ហើយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ម្ចាស់ ហើយកន្លែងខ្វះខាតណាមួយត្រូវបានរកឃើញយ៉ាងងាយស្រួល។ សរុបជារួមការងារត្រួតពិនិត្យមានភាពងាយ ស្រួល។
- ការគ្រប់គ្រងដោយឯករាជ្យ៖ វាជាលក្ខណៈមួយនៃអាជីវកម្មនេះ គឺទទួលបានសេរីភាពយ៉ាងច្រើនក្នុងការគ្រប់គ្រង។ ក្នុងនាមជាម្ចាស់ផ្ទាល់ ក្នុងការគ្រប់គ្រងអាជីវកម្មនេះ ឥទ្ធិពលនៃរសជាតិ ចំណូលចិត្ត អាកប្បកិរិយា ជាដើម អាចត្រូវបានគេសង្កេតឃើញមាននៅក្នុងការគ្រប់គ្រងរបស់ម្ចាស់អាជីវកម្មផ្សេងៗគ្នា។
- មុខងារពឹងផ្អែកលើតំបន់៖ អាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារត្រូវបានប្រមូលផ្តុំជាចម្បងនៅក្នុងតំបន់ជាក់លាក់មួយ។ គោលបំណងសំខាន់នៃអាជីវកម្មជាលក្ខណៈគ្រួសារ គឺដើម្បី ចូលរួម ក្នុងការបំពេញតម្រូវការ និងការចង់បានរបស់ប្រជាជនក្នុងតំបន់។
- ចំនួនបុគ្គលិកតិចតួច៖ លក្ខណៈមួយទៀតនៃអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារគឺចំនួនកម្មករមានចំនួនតិច ។ ចំនួនកម្មករដែលធ្វើអាជីវកម្មជាលក្ខណៈគ្រួសារមានតិចជាង ៥០នាក់។
- ការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក៖ វត្ថុធាតុដើមផលិតក្នុងស្រុកត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មនេះ។ អាជីវកម្មខ្នាតតូចជាធម្មតាត្រូវបានបង្កើតឡើងអាស្រ័យលើវត្ថុធាតុដើមក្នុងស្រុក។ ប៉ុន្តែជួនកាលវត្ថុធាតុដើមក៏ត្រូវបាននាំចូលពីខាងក្រៅផងដែរបើចាំបាច់ទោះបីជាវាតិចក៏ដោយ។
- កង្វះបច្ចេកវិទ្យាទំនើប៖ ស្ទើរតែគ្រប់ទីកន្លែងក្នុងពិភពលោក អាជីវកម្មជាលក្ខណៈគ្រួសារខ្វះបច្ចេកវិទ្យាទំនើប។ នាពេលបច្ចុប្បន្ន ការប្រើប្រាស់បច្ចេកវិទ្យាទំនើបអាចត្រូវបានគេសង្កេតឃើញនៅក្នុងអាជីវកម្មជាលក្ខណៈគ្រួសារមួយចំនួន ប៉ុន្តែក្នុងករណីភាគច្រើនមិនគេអាចប្រើប្រាស់វាបានយ៉ាងទូលំទូលាយដោយសារតែខ្វះដើមទុន។
- ទម្រង់ច្បាប់មានលក្ខណៈទាប៖ រាល់ទម្រង់ច្បាប់ដែលត្រូវអនុវត្តតាមក្នុងការបង្កើត បទប្បញ្ញត្តិ ការគ្រប់គ្រង ការ ពង្រីកការគ្រប់គ្រង និងការរំលាយអាជីវកម្មជាលក្ខណៈគ្រួសារ គឺតិចជាងសហគ្រាសធំៗ។ ដូច្នេះអាច និយាយបានថាមិនសូវមានទិដ្ឋភាពច្បាប់ដែលត្រូវអនុវត្តក្នុងករណីអាជីវកម្មជាលក្ខណៈគ្រួសារនោះទេ។

- ទំហំអាជីវកម្មជាលក្ខណៈគ្រួសារ៖ ទំហំនៃអាជីវកម្មជាលក្ខណៈគ្រួសារមានទំហំតូចជាងអាជីវកម្មខ្នាតមធ្យម និងធំ។ កត្តាមួយចំនួនដូចជា ដើមទុនទាប បុគ្គលិកតិចតួច ការប្រើប្រាស់គ្រឿងចក្រខ្នាតតូចដើម្បីសម្រួល និងកាត់បន្ថយទំហំការចំណាយក្នុងអាជីវកម្ម។

បន្ទាប់ពីការពិភាក្សាខាងលើយើងអាចនិយាយបានថាមានលក្ខណៈ មួយចំនួននៅក្នុងអាជីវកម្មជា លក្ខណៈ គ្រួសារដែលមិនត្រូវបានគេមើលឃើញនៅក្នុងអាជីវកម្មផ្សេងទៀតទេ។ មិនត្រឹមតែប៉ុណ្ណោះ លក្ខណៈទាំងនេះ បានបែងចែកអាជីវកម្មជាលក្ខណៈគ្រួសារពីអាជីវកម្មខ្នាតមធ្យម និងខ្នាតធំ។

### ២.១.៣. ពន្យល់ពាក្យគន្លឹះ

ក្រមា គឺមកពីពាក្យ "ម៉ា" ដែលមានន័យថាជាសំពត់ត្បាញដោយអំបោះ មានក្រឡាខ្វែងសម្រាប់ផ្លាស់ងូតទឹក ឬប្រើប្រាស់ជាប្រចាំថ្ងៃ។

ក្រមា គឺជាការផលិតដែលបានមកពីរការត្បាញរវៃ កែច្នៃចេញពីវត្ថុធាតុដើមផ្សេងៗមានដូចជាកម្បាសសូត្រ និងល័ក្តសម្រាប់ជ្រលក់ពណ៌អាចំ។[6]

### ២.១.៤. អំពីក្រមា

តាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួនណាត ក្រមាគឺជាក្រណាត់សំពត់សម្រាប់ងូតទឹក។

ក្រមាគឺជា សំពត់ត្បាញដោយអំបោះ មានក្រឡាខ្វែងជាច្រើនពណ៌ចម្រុះគ្នា ហើយវាជាសម្ភារប្រើប្រាស់ដ៏ពេញនិយមមួយសម្រាប់ប្រជាពលរដ្ឋខ្មែរ ហើយ វាក៏ជាវប្បធម៌ដ៏ សាមញ្ញ និងយូរយារតាំងពីដើមមករបស់ខ្មែរ។

ក្រមាវាជាឈ្មោះដែលខ្មែរបានដាក់សម្រាប់ក្រមាបុរាណ ដែលមនុស្សបានស្គាល់ និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃជាយូរយារណាស់មកហើយ។ វាជាក្រណាត់ដែលធ្វើពីកប្បាស ឬសូត្រ។ តាមការស្រាវជ្រាវគេបានរកឃើញតម្បាញ និងអំបោះ ដែលមានអាយុ ២០០ ឆ្នាំ មុន គ.ស នៅខេត្ត ព្រះវិហារភាគខាងជើងប្រទេសកម្ពុជា។ ដូច្នេះវាត្រូវបាន បង្ហាញថាក្រមាមួយត្រូវបាន បង្កើតឡើងយ៉ាងហោចណាស់ 2200 ឆ្នាំ។ក្រមាខ្មែរ ជាក្រមាបុរាណ ដែលមានការប្រើប្រាស់ច្រើន រួមបញ្ចូលទាំង សម្រាប់គ្របក្បាល និងគ្របមុខដើម្បីការពារពីខ្យល់ និងព្យុះធូលី។ វាក៏អាចត្រូវបានប្រើសម្រាប់ការតុបតែងផងដែរដូចជាខ្សែក្រវាត់នៅពេលដែលវាត្រូវបានរុំជុំវិញចង្កេះ។ ស្ត្រីជាច្រើនអាចពាក់វានៅលើក្បាលរបស់ពួកគេ ជាពិសេសនៅពេលដែលពួកគេដាក់របស់នៅលើក្បាលរបស់ពួកគេ។

ការប្រើប្រាស់ជាមូលដ្ឋាន៖

- ក្រមាសម្រាប់ពាក់ក

[6] From Wikipedia, the free encyclopedia. *Krama*. Retrieved from https://en.wikipedia.org/wiki/Krama

- សម្រាប់ពាក់នៅលើក្បាលៈ
  - គម្របក្បាល
  - រុំក្បាល ឬថ្វាស់
  - មួកសម្រាប់ពាក់ក្បាល
- ម៉ាស់
- សម្រាប់បង់ក ឬជាកន្សែង
- ខ្សែក្រវ៉ាត់។

វាមិនមែនត្រឹមតែជាក្រមាដើម្បីការពារប្រជាជនខ្មែរពីខ្យល់ ឬធូលីនោះទេ ប្រជាជនកម្ពុជាក៏ប្រើក្រមាធ្វើជាអង្រឹងបណ្តោះអាសន្ន សម្រាប់ផ្ទុកទារក ឬពាក់ក្បាលដើម្បីការពារពីព្រះអាទិត្យផងដែរ។ ពួកគេអាចប្រើវាជាកន្សែង ឬរុំបន្ទាប់ពីងូតទឹក ឬជាភួយសម្រាប់ដណ្តប់ពេលយប់។

ដូចនេះពិតជាក្រមាមានអត្ថប្រយោជន៍ច្រើន យ៉ាងណាស់ក្នុងការ ប្រើប្រាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នក ដែលរស់នៅតាមស្រុក ស្រែចម្ការ។ ក្រមាជាសម្ភារប្រើប្រាស់ ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរតាំងពីបុរាណកាលមកម្លេះ។

## ២.២. ទ្រឹស្តី

### ២.២.១. សិប្បកម្ម

ទ្រឹស្តីនៃសិប្បកម្ម លោក *Howard Risatti* ពិនិត្យមើលបញ្ហាទាំងនេះដោយប្រៀបធៀបសេរ៉ាមិចធ្វើដោយដៃ កញ្ចក់ ដែក ត្បាញ និងគ្រឿងសង្ហារឹមទៅនឹងគំនូរ ចម្លាក់ ការថតរូប និងការរចនាដែលផលិតដោយម៉ាស៊ីនពី *Bauhaus* ទៅ *Memphis Group* ។ គាត់ពណ៌នាអំពីសិប្បកម្មថាជាមុខងាររួមបញ្ចូលគ្នាដ៏ពិសេសជាមួយនឹងការបង្ហាញកាន់តែស៊ីជម្រៅនៃតម្លៃរបស់មនុស្សដែលលើសពីវប្បធម៌ ពេលវេលា និងលំហ។ *Risatti* និយាយថាសិប្បកម្មត្រូវតែបង្ហាញតួនាទីសម្រាប់ខ្លួនវានៅក្នុងសង្គមសហសម័យ។ បើមិនដូច្នេះទេ វានឹងត្រូវបានស្រូបយកដោយសិល្បៈ ឬការរចនាដ៏ល្អ ហើយវិធីសាស្រ្តឯកវចនៈរបស់វាក្នុងការយល់ដឹងអំពីពិភពលោកនឹងត្រូវបាត់បង់។

ការលើកឡើងនិងស្វែងយល់ពីរនិយមន័យ និងទ្រឹស្តីរបស់សិប្បកម្មក្រមា គឺជាការសរសេររំលឹកនូវទ្រឹស្តីដែលបានសិក្សាទាក់ទងទៅនឹងប្រធានបទដើម្បីជាគំនិតក្នុងការស្វែងយល់ផ្សេងៗ វាស់វែងនិងប្រៀបធៀប។

បើតាមលោក *Gillian Green* ឈ្មោះក្រមាខ្មែរច្បាស់លាស់គឺមិនមែន "ក្រមា" ទេ ប៉ុន្តែជា "ផាក្រមា" ។ ឬ "ក្រមាក្រណាត់", គេបានសន្និតថាពាក្យ "ក្រមា" បានមកពីពាក្យ "*kamar*" របស់ចក្រភពពែរ្សកណ្តាល, មានន័យថាខ្សែក្រវាត់ឬក្រវ៉ាត់ - ដូចជា "*kamar-band*" ( លោក Green ១៩៩៧, ៩០ ) ។ ពាក្យមួយទៀតដែលគេ

ប្រើក្នុងប្រទេសកម្ពុជាគឺ "កន្សែង", ដែលកំណត់ថាពីមុនពាក់ដោយស្ត្រី, កន្សែងបងក, កន្សែងរុំក្បាល ឬកន្សែងសម្រាប់ជូតខ្លួន ( លោក *Jenner* ១៩៨២, ៣៧៨ )។[7]

### ២.២.២. ក្រមាផ្សារភ្ជាប់ជាមួយក្បាច់គុនល្បុក្កតោ

ក្បាច់គុនល្បុក្កតោដែលជាទម្រង់ក្បាច់ចំណាស់បំផុតមួយនៅអាស៊ីអាគ្នេយ៍គឺប្រើប្រាស់ក្រមា។ អ្នកប្រយុទ្ធនឹងរុំក្រមានៅជុំវិញចង្កេះ ក្បាល និងកណ្តាប់ដៃ។ ពណ៌ក្រមាតំណាងឱ្យកម្រិត និងជំនាញនៃសមត្ថភាពក្បាច់គុន និងការហ្វឹកហាត់របស់អ្នកប្រយុទ្ធ។ ក្រមាពណ៌ស គឺសម្រាប់អ្នកប្រយុទ្ធល្បុក្កតោកម្រិតទាបបំផុត និងពណ៌ខ្មៅសម្រាប់អ្នកប្រយុទ្ធកម្រិតជំនាញ។

មុខងារផ្សេងទៀតរបស់ក្រមាដែលមានលក្ខណៈចម្រុះ ក្រមាក៏អាចដំណើរការសម្រាប់/ជា៖

- ឧបករណ៍-ខ្សែក្រវ៉ាត់សម្រាប់ធានាឧបករណ៍កាន់ដៃ ឬសម្រប់យួរដៃ
- ប្រើសម្រាប់បក់រុយ និងមូស
- សម្រាប់ផ្ទុករបស់ធំ និងច្រើនដោយមិនចាំបាច់ប្រើដៃ
- ខ្នើយសម្រាប់គេង
- អង្រឹងទារក ឬសត្វចិញ្ចឹម (ជុំវិញស្មា ឬរវាងដើមឈើពីរ)
- ប្រើសម្រាប់ឯកជនភាព
    - សម្រាប់បាំងពេលចូលបន្ទប់ទឹកដែលចំហ
    - ស្ត្រីគ្របខ្លួនដោយផ្នែកខាងលើ និងខាងក្រោម ចំណែកបុរសអាចរុំវាជុំវិញក្រលៀនជាក្រណាត់ចង្កេះ
    - ឈុតហែលទឹក ឬងូតទឹកនៅទីសាធារណៈ
- ក្បាច់គុនខ្មែរ (ល្បុក្កតោ)៖ អ្នកប្រយុទ្ធរុំក្រមាជុំវិញចង្កេះ ក្បាល និងកណ្តាប់ដៃ។ ដូចជាសិល្បៈក្បាច់គុនអាស៊ីបូព៌ា ពណ៌តំណាង ឱ្យកម្រិតជំនាញ (ចាប់ពីពណ៌ស សម្រាប់អ្នកចាប់ផ្តើមដំបូង និងខ្មៅសម្រាប់អ្នកជំនាញ)
- បាល់សម្រាប់ក្មេងលេង។[8]

---

[7] David & Sue Richardson. (2022, February 21). *Cambodian Krama*. Retrieved from http://www.asiantextilestudies.com/krama.html#x

[8] Lifestyle & More, Magazine. (2020, November 18). *THE KRAMA – WORLD'S MOST VERSATILE GARMENT*. Retrieved from https://heritage-line.com/magazine/krama-the-worlds-most-versatile-garment/

## ២.៣. ប្រវត្តិនៃក្រមា និងប្រវត្តិនៃការតម្បាញ

### ២.៣.១. ប្រវត្តិនៃក្រមាខ្មែរ

ដើមកំណើតនៃក្រមាក្រឡានៅមិនទាន់ច្បាស់នៅឡើយទេ។ អ្នកខ្លះបានលើកឡើងថា វាអាចនឹងនាំចូលមកកម្ពុជាពីឥណ្ឌា ខាងត្បូងតាមរយៈ ម៉ាឡេស៊ី និងថៃ។ មតិមួយទៀតគឺថាក្រមាអាចត្រូវបាននាំចូលជាទម្រង់នៃកន្សែងពីរដ្ឋ *Amaravati* បុរាណនៅភាគខាងត្បូងប្រទេសឥណ្ឌា បន្ទាប់ពីអាពាហ៍ពិពាហ៍រវាងខ្សែរាជវង្ស។

បើតាមលោក ហាប់ ទូច ប្រធានសារមន្ទីជាតិកម្ពុជា, ក្រមាមានអាយុកាលយ៉ាងហោចនៅសម័យមុនអង្គរ នគរភ្នំដែលមាន អាយុកាលតាំងពីសតវត្សទី ១ ដល់សតវត្សទី ៥ នៃគ.ស។ រូបសំណាកជាច្រើនរបស់ ព្រះសិវៈ និងព្រះហិណ្ឌូដទៃទៀត ដែលមានអាយុកាលតាំងពីសម័យនោះ ត្រូវបានរកឃើញពីអង្គរបុរី ឃើញពាក់ក្រមាធំមួយជាក្បិន, ជាកន្សែងរុំចង្កេះ។ រូបសំណាកមួយថែមទាំងបង្ហាញបុរសម្នាក់ពាក់ក្រមាជាកន្សែងរុំក្បាល។

នៅពេលដែលបេសកជនចិន *Zhou Daguan* បានចំណាយពេល ១១ ខែនៅអង្គរធំក្នុងឆ្នាំ ១២៩៦-១២៩៧ គាត់បាន បន្សល់ទុកអោយយើងនូវដំណើររឿងលម្អិតអំពីជីវិតប្រចាំថ្ងៃនៅពេលនោះ (១៩០២)។ គាត់មិនបាននិយាយអំពីកន្សែង បង់ក្បាលទេ ប៉ុន្តែបានកត់ត្រាថា មនុស្សគ្រប់លំដាប់ថ្នាក់ តាំងពីស្តេច រហូតដល់មនុស្សសាមញ្ញ បានដើរជើងទទេ បួងសក់ មានស្មាទទេ ហើយគ្រាន់តែរុំកន្សែងតូចមួយនៅចង្កេះ។ ស្ត្រីគឺ ដោះសុដន់ទទេ។ នៅពេលពួកគេចេញទៅក្រៅ គេរុំកន្សែងធំ មួយពីលើកន្សែងតូចដែលពួកគេស្លៀកស្រាប់។ ក្រណាត់មានគុណភាពជាច្រើន ដែលខ្លះផលិតក្នុងស្រុក ខ្លះទៀតនាំចូល ពីប្រទេសចំប៉ា និងសៀម ប៉ុន្តែក្រណាត់ប្រណិតបំផុតគឺពីនាំមកពីសមុទ្រខាងលិច។

ជនជាតិខ្មែរមិនបានចិញ្ចឹមដង្កូវនាងទេនៅពេលនោះ ហើយប្រពន្ធរបស់ពួកគេក៏មិនចេះដេរដែរ ពួកគេគ្រាន់តែដឹងពីរបៀប ត្បាញក្រណាត់កប្បាសពីគរ។ ពួកគេក៏មិនមានតម្បាញដែរ។ ពួកគេគ្រាន់តែចងចុងម្ខាងនៃបណ្តាញទៅនឹងខ្សែក្រវាត់មួយ ហើយខណៈពេលដែលធ្វើការនៅចុងម្ខាងទៀតដោយប្រើប្រដាប់ឫស្សី។ មានន័យថា សំពត់សាមញ្ញរបស់ពួកគេត្រូវបាន ត្បាញពីកប្បាស ហើយមានទំហំប្រហាក់ប្រហែលនឹងក្រមាធំៗដែរ។

នាពេលថ្មីៗនេះ ក្រមាបានលេចចេញជារូបភាពដំបូងបំផុតជាសំលៀកបំពាក់ខ្មែរដែលមានរូបថតនៅចុងសតវត្សទី១៩។ អ្នកថតរូប និងជាអ្នករុករកជនជាតិបារាំងវ័យក្មេងម្នាក់ឈ្មោះ *André Salles* គឺជាអ្នកដំបូងគេដែលបានរក្សាទុកនូវទិដ្ឋភាព នៃជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាជាទម្រង់រូបថតក្នុងឆ្នាំ ១៨៩៦ ។

ចំពោះខ្មែរយើងមិនពិបាកយល់ឡើងអំពីអ្វីជា ក្រមា ព្រោះរបស់នេះកើតមានឡើង និងរស់នៅជាមួយប្រជាជនខ្មែរយើងតាំងពីសម័យដើមមកម្លេះ។ ក៏ប៉ុន្តែបើនិយាយអំពីប្រវត្តិខ្លឹមសារស៊ីជម្រៅ និងរបៀបតម្បាញក្រមា គឺជារឿងមួយដោយឡែក និងស្មុកស្មាញ ពិតជាតម្រូវអោយមានការសិក្សាស្រាវជ្រាវអោយបានវែងឆ្ងាយបន្តិច។

ប្រជាជនកម្ពុជាមានទម្លាប់ស្លៀកពាក់ប្រពៃណីជាមួយនឹងកន្សែងរុំដែលត្បាញចេញពីអំបោះមានក្រឡាខ្វែង ហៅថា "ក្រមា"។

ក្រមា បានក្លាយ ជាអត្តសញ្ញាណនៃសម្លៀកបំពាក់ខ្មែរចាប់តាំងពីសតវត្សរ៍ទីមួយនៃរជ្ជកាលព្រះបាតហ៊ុនទៀន (*Hun Tean*) តែទោះបីជាយ៉ាងណាក៏ដោយ គេពុំ បានដឹងច្បាស់ពីពេលវេលាជាក់លាក់ដែល ក្រមាចាប់ផ្ដើមមាន ប្រជាប្រិយភាពនៅគ្រប់កន្លែងនោះទេ។ វាមានសណ្ឋានត្រឹមជាសំពត់មួយផ្ទាំងប៉ុណ្ណោះតែវាបានភ្ជាប់នូវតម្លៃ ខ្លឹមសារអត្តសញ្ញាណ និងទិដ្ឋភាពវប្បធម៌ ក្នុងនោះជានិច្ច។ សង្គមខ្មែរយើងបានចាត់ទុកក្រមាជារបស់សំខាន់ស្ទើរខ្វះពុំបានក្នុងសកម្មភាព និងការរស់នៅប្រចាំថ្ងៃ។ ក្រមាពិតមានតម្លៃសម្រាប់ប្រជាកសិករ, កម្មករ និងប្រជាពលរដ្ឋប្រើប្រាស់ បានស្ទើរគ្រប់សណ្ឋាន ពិសេសស្ត្រីខ្មែរ តែងតែនិយមប្រើប្រាស់ក្រមាពាក់ពីក្រោមមួកស្លឹងដែលមានរាងជាសាជី ដើម្បីការពារកំដៅព្រះអាទិត្យនៅពេល ធ្វើស្រែចំការ។

"ក្រមា" គឺអត្តសញ្ញាណមួយដែលធ្វើឲ្យ ជនជាតិខ្មែរមានលក្ខណៈ ខុសប្លែកពី ជនជាតិថៃ វៀតណាម និងឡាវ ដែលជាប្រទេសជិតខាង ផងដែរ។ តាំងពីរសម័យដើមមក កន្សែងរុំដែលត្បាញចេញពីអំបោះមានក្រឡាខ្វែងនេះ ត្រូវបានប្រើប្រាស់ ក្នុងគោលបំណងផ្សេងៗរួមមានដូចជា ស្លៀកដណ្ដប់ វេចខ្ចប់ ក្រាល ទទូល និងសម្រាប់លក់ដូរដើម្បីដោះស្រាយជីវភាព។ នៅក្នុងបរិបទប្រពៃណីទំនៀមទម្លាប់ និងវប្បធម៌ក្រមាជាផ្ទាំងសំពត់ដ៏វិសាលប្រើជាហូរហែរក្នុងពិធីអាពាពិពាហ៍ ពិធីបុណ្យ សម្រាប់ច្នៃលេងក្នុងល្បែងប្រជាប្រិយ និងជាអត្តសញ្ញាណជាតិដែលយើងពុំអាចនឹងបំផ្លេចបាន។ ក្រមាខ្មែរយើងក៏អាច យកមកបត់ជារាងកូនតុក្កតាសម្រាប់ក្មេងតូចៗលេងផងដែរ។ នៅរបបខ្មែរក្រហម ប្រជានជនកម្ពុជាត្រូវបង្ខំឲ្យប្រើប្រាស់ក្រមាគ្រប់ៗគ្នា។ មកដល់បច្ចុប្បន្ន គេនិយមប្រើប្រាស់ក្រមាជាវត្ថុអនុស្សាវរីយ៍យ៉ាងល្អ និងសមរម្យសម្រាប់ជូនគ្នាជាការដូរទៅវិញទៅមកទុកប្រើជារបស់តាំងលម្អ ឬគេប្រើប្រាស់ក្រនេះមកច្នៃជាសម្លៀលបំពាក់ ឬរបស់ប្រើប្រាស់ផ្សេងៗជាដើម។

### ២.៣.២. ក្រមា - និមិត្តសញ្ញាជាតិខ្មែរ

ក្នុងសម័យប៉ុលពត យុទ្ធជនខ្មែរក្រហមជាច្រើននាក់បានពាក់ក្រមាពណ៌ក្រហម និងស។ នេះបានក្លាយជានិមិត្តរូបនៃរបបខ្មែរក្រហមដ៏ឃោរឃៅ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញរាប់ពាន់នាក់បានចេញទៅតាមដងផ្លូវដើម្បីអបអរសាទរកងទ័ពខ្មែរក្រហមដែលបានទទួលជ័យជម្នះនៅពេលពួកគេចូលទីក្រុង។ ការប្រារព្ធពិធីដ៏រីករាយនេះ មិនបានអូសបន្លាយយូរឡើយ ខណៈដែលពួកគេបានឃើញការប្រយុទ្ធដ៏ រឹងម៉ាំ និងការសម្លឹងមើលមុខរបស់ខ្មែរក្រហមដែលបានទទួលជ័យជម្នះ ដែលសុទ្ធតែពាក់ក្រមាក្រហម និងស។ នៅពេលនោះ ប្រជាជនកម្ពុជាមិនសូវបានដឹងពីអ្វីដែលពួកគេត្រូវស៊ូទ្រាំ។ តាមការប៉ាន់ស្មានថា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប្រជាជនកម្ពុជាជាង ២ លាននាក់ត្រូវបានគេធ្វើឃាត សម្លាប់ បង្អត់អាហារ ឬស្លាប់ដោយជំងឺ ក្នុងសម័យ "វាលពិឃាត" ដ៏ល្បីល្បាញនៃនយោបាយកម្ពុជា។

ក្រមា ពណ៌ក្រហម និងស បានក្លាយជានិមិត្តរូបនៃរបបខ្មែរក្រហម។ ឯកសណ្ឋានខ្មែរក្រហមសម្រាប់ទាហាន និងប្រជាពលរដ្ឋទាំងអស់ គឺខោអាវពណ៌ខ្មៅ ស្បែកជើងកៅស៊ូ និងក្រមា ពណ៌ក្រហម និងស។

នេះជាមូលហេតុដែល ក្រមាពណ៌ក្រហម និងស មានអតីតកាលជាប្រវត្តិសាស្ត្រសម្រាប់ប្រជាជនកម្ពុជាជាច្រើន។ សូម្បីតែសព្វថ្ងៃនេះ ប្រជាជនកម្ពុជាមួយចំនួនអាចបដិសេធមិនពាក់ក្រមាពណ៌ក្រហម និងស ហើយអាចជ្រើសរើសពាក់ពណ៌ខៀវ និងស ឬពណ៌ផ្សេងទៀត។ នេះក៏ដោយសារតែកេរដំណែលនៃក្រមាពណ៌ក្រហម និងស សម័យខ្មែរក្រហមនៃនយោបាយកម្ពុជាដ៏ឃោរឃៅនេះ។[9]

### ២.៣.៣. ក្រមាជានិមិត្តរូបនៃកម្លាំងរបស់កម្ពុជា

ថ្វីត្បិតតែមានអតីតកាលដ៏ក្រៀមក្រំក៏ដោយ ក៏ក្រមាខ្មែរលើសពីក្រមា វាជានិមិត្តរូបនៃភាពរឹងមាំ ការរស់រានមានជីវិត និងភាពក្លាហាន របស់ប្រជាជនកម្ពុជា។ ក្រណាត់នេះបាន ដើរតាមជាតិខ្មែរ គ្រប់ពេលវេលាល្អ និងអាក្រក់។ ក្រមាខ្មែរ ជានិមិត្តសញ្ញារបស់កម្ពុជា។ ពេលពាក់ក្រមា អ្នកហាក់កំពុងពាក់និមិត្តរូបខ្មែរនៃកម្លាំង ភាពធន់ និងការរស់រានមានជីវិត។

ដូច្នេះអាចនិយាយបានថាក្រមាខ្មែរនេះក៏មានរឿងរស់នៅ (រឿងនិទាន) របស់ខ្លួនដែរ។ សូម្បីតែនៅកម្ពុជាសព្វថ្ងៃ ក្រមានៅតែជាផ្នែកមួយដ៏សំខាន់នៃជីវិត និងវប្បធម៌ខ្មែរ។

### ២.៣.៤. ប្រវត្តិនៃការត្បាញក្រមា

ក្រមា គឺជាផលិតផលដែលបានមកពីការតម្បាញរវៃ កែឆ្នៃចេញពីវត្ថុធាតុដើមផ្សេងៗមានដូចជាកប្បាស ឬសូត្រ និងល័ក្តសម្រាប់ជ្រលក់ពណ៌ជាអាច៍។ តាំងពីដើមរៀងមក ខ្នារ អំបោះ ក្តាមូល ធ្មេញឈើត្រល់ និងកីជាដើមសុទ្ធសឹងតែជា សម្ភារៈចាំបាច់ បន្ថែមទៀត ដែលត្រូវប្រើ ក្នុងការងារ តម្បាញ។ បើយោងតាមភស្តុតាងប្រវត្តិសាស្ត្រ គេបានរកឃើញ សំណល់ក្បាលត្រល់ និងខ្នារអំបោះនៅស្ថានីយបុរាណវិទ្យា ម្លូរព្រៃ ស្ថិតក្នុងខេត្តព្រះវិហារ មានអាយុកាលប្រមាណ២០០ឆ្នាំមុនគ្រឹស្តសករាជបង្ហាញថា ក្រមាក៏ប្រហែលជាកើតមាន ឡើងតាំងពីមានវត្តមាន មនុស្សរស់នៅ លើទឹកដីកម្ពុជា ហើយអ្នកទាំងនោះ ចេះរវៃត្បាញប្រមាណជា ២២០០ឆ្នាំមុនមកម្លេះ។

នេះបើតាមការសិក្សា របស់ក្រុមកាងារស្រាវជ្រាវបានឲ្យដឹងការសិក្សាឲ្យដឹងទៀតថា បើផ្អែកលើការសិក្សាសិលាចរិក គេឃើញមមានពាក្យពេចន៍មួយចំនួន ដែលគេជឿថាមានទំនាក់ទំនងអាចអោយយើងពិចារណាបានពំពីភស្តុតាងនៃការតម្បាញរវៃក្នុងសម័យប្រវត្តិសាស្ត្រ។ បើតាមរយៈសិលាចរិកវត្តសសរ ១០០ ចារក្នុងសតវត្សទី៩ គេឃើញមានពាក្យ (ក្របាស) ពាក្រនេះសម្រាប់អ្នកស្រាវជ្រាវគេសន្និដ្ឋានថាជាពាក្រពោលសំដៅហៅ

[9] *The Cambodian Krama Scarf, The Story Behind This Iconic Scarf*. Retrieved from https://abusonadustyroad.com/the-cambodian-krama-scarf-the-story-behind-this-iconic-scarf/?expand_article=1

ឈ្មោះ កប្បាស ដែលជារុក្ខជាតិម្យាងសម្រាប់ជាវត្ថុដើមប្រើក្នុងការតម្បាញរវៃជាប្រាកដ ដ្បិតអត្ថន័យជារួមក្នុងសិលាទាំងពីរ និយាយពីការថ្វាយរបស់ផ្សេងៗដល់ប្រាសាទសម្រាប់ប្រើប្រាស់។ មកដល់សតវត្សទី១១ គេឃើញថាមានពាក្យ (តៃថ្ករ) ចារក្នុងសិលាចរិកប្រាសាទស្ទឹងជាងកើត និងសិលាចរិកគោករការមានពាក្យ (រង្វៃ) សិលា ចរឹក ព្រៃមៀនមានពាក្យ (កុ ត្បាញ)។ តាមរយៈពាក្យទាំងនេះគេអាចសន្និដ្ឋានបានថា នៅក្នុងសម័យកាលនោះការតម្បាញរវៃ គឺកើតមានជាប្រាកដក្នុងសង្គមខ្មែរ។

មកដល់សតវត្សទី១៣ បើតាមកំណត់ហេតុលោក ជីវ តាក្វាន់ និយាយអំពីសម្លៀកបំពាក់បានអោយដឹងថា អ្នកស្រុកខ្មែរតាំងពីស្តេចដល់រាស្ត្រទាំងប្រុស្រីសុទ្ធតែលែងខ្លួនទទេ មានតែសំពត់មួយផ្ទាំងតូចរំព័ទ្ធជុំវិញខ្លួនរបៀបចងពុង ហើយបើត្រូវចេញទៅណា គេយកសំពត់មករុំថែមពីលើ។ មិនតែប៉ុណ្ណោះ យោងតាមចម្លាក់នៅប្រាសាទនានា ក៏សុទ្ធសឹងតែឃើញថាខ្មែរមានក្រណាត់ច្នៃជាសម្លៀកបំពាក់ពេញចរិបូរណ៍។ ដូច្នេះវាសបញ្ជាក់អោយឃើញថាការតម្បាញរវៃក្រណាត់ផ្សេងមានតាំងពីសម័យខ្មែរបុរាណមកម្លេះ។

## ២.៤. ការវិវត្តន៍នៃការតម្បាញក្រមា

បើតាមការសិក្សាស្រាវជាពីអត្ថបទ និងការសាកសួរពីប្រជាពលរដ្ឋផ្ទាល់អំពីកីតម្បាញក្រមានេះបានអោយយើងដឹងថា កីតម្បាញមានវត្តមាននៅកម្ពុជា ជាច្រើនទសវត្សរ៍មកហើយ ចាប់តាំងការតម្បាញដោយកីបុរាណរហូតមកដល់បច្ចុប្បន្ន គឺការតម្បាញកីតម្បាញ ដែលប្រើប្រាស់ដោយម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ។ ចំពោះបច្ចេកទេស បែបទំនើបនេះ ទើបតែកើតមានឡើងនៅ រវាងដើមទសវត្សឆ្នាំ១៩៩០នេះប៉ុណ្ណោះ ពីមុនមកគេ ប្រើកីបុរាណហើយក្រោយមកទៀត គេប្រើកីកន្ត្រាក់ធាក់ដោយជើង ដែលមានលក្ខណៈពាក់កណ្តាលស្វ័យប្រវត្តិខ្លះ ប៉ុន្តែមកដល់សព្វថ្ងៃសិប្បករភាគច្រើនលែងប្រើកីបុរាណនិងកីកន្ត្រាក់ទៀតហើយ ស្ទើរតែ ៩៩ភាគរយនៃសិប្បករប្រើប្រាស់កីតម្បាញស្វ័យប្រវត្តិ។

ជាក់ស្តែងយើងពុំទាន់ឃើញមានភស្តុតាងនៅឡើយ អំពីរបៀបត្បាញរវៃនៅសម័យបុរេប្រវត្តិ ឬក្នុងសម័យប្រវត្តិសាស្ត្ររាប់រយឆ្នាំមុនទេ ប៉ុន្តែបើតាមការស្រាវជ្រាវ និងសង្កេតរបៀបនៃការត្បាញរវៃក្នុងសង្គម ខ្មែរសម័យបច្ចុប្បន្ន គឺអាចធ្វើឡើងតាមពីរបបៀប ពោលគឺតាមបែបប្រពៃណី និងតាមបែបសម័យទំនើប។ ការត្បាញតាមបែបទំនើប ពុំសូវមានភាពស្មុគស្មាញឡើយ ទាំងសម្ភារៈនិងវត្ថុធាតុ សម្រាប់ប្រើក្នុងការងារតម្បាញ រួមទាំងអំបោះ និងល័ក្តផង ច្រើនជារបស់នាំចូលស្រាប់ៗពីប្រទេសជិតខាង។

ប៉ុន្តែចំពោះ ការត្បាញតាមបែបប្រពៃណីគឺមានដំណាក់កាលស្មុគ្រស្មាញច្រើន ហើយសម្ភារៈ និងវត្ថុធាតុដើមប្រើសម្រាប់ក្នុងការត្បាញ សុទ្ធតែច្នៃបង្កើតដោយសិប្បករផ្ទាល់។ ការងារនោះហាក់បង្ហាញពី ចំណេះ គំនិតច្នៃប្រឌិត និងការអត់ធ្មត់ខ្ពស់របស់សិប្បករនីមួយៗ ទម្រាំសម្រេចបានក្រមាមួយសម្រាប់ លក់ដូរ ឬ ប្រើប្រាស់។

ហេតុដូច្នេះទើបយើងក៏បានលើកយកបង្ហាញពីរចំណុចនេះគឺ ត្បាញតាមបែបប្រពៃណី និងត្បាញតាមបែបសម័យទំនើប។

### ២.៤.១. ការវិវត្តន៍នៃរបៀបតម្បាញពីមួយសម័យកាលទៅមួយសម័យកាល

#### ២.៤.១.១. ការត្បាញតាមបែបប្រពៃណី (គឺបុរាណ)

ជាទូទៅការត្បាញក្រមាតាមបែបប្រពៃណី ត្រូវឆ្លងកាត់ដំណាក់កាលច្រើន ក្រោយពីបាន បេះកប្បាសបម្រួលពីចម្ការរួច ហើយបើនិយាយរៀបរាប់ក៏សឹងមានពាក្យបច្ចេកទេសច្រើននិង ពិបាកយល់ដែរ។ ប៉ុន្តែយ៉ាងណាក៏ដោយ ដំណាក់កាលទាំងនោះរាប់តាំងពីបោះកប្បាស ថ្លេច មូរសំឡី រវៃអំបោះ កុងអំបោះ ជ្រលក់ល័ក្ខ ឲ្យបាយ អន្ទង ថ្ករ និងត្បាញជាដំណាក់កាលចុងក្រោយដែលនាំឲ្យចេញបានជាក្រមា។ ជាការពិតណាស់ ការតម្បាញបែបប្រពៃណីគឺវត្ថុធាតុទាំងអស់សុទ្ធិសឹងតែធ្វើពីដៃដែលមានជាច្រើនដំណាក់កាលដូចការរៀបរាប់ខាងក្រោម។

ដើម្បីច្នៃបានពីភាពជាសំឡីទៅជាសរសៃអំបោះត្រូវឆ្លងកាត់ដំណាក់កាលៈ

- “បោះកប្បាស” ជាការបោះកប្បាសយកមកហាស ដោយបោះប្រលេះយកគ្រាប់ រួចរក្សា កប្បាសនោះទុកមួយអន្លើ។
- “ថ្លេច” គេយករំពាត់មកវាយកប្បាសនោះឲ្យបែកសាច់។
- “មូរសំឡី” គឺគេយកអំបោះដែលថ្លេចរួចមកមូរស្តើងៗជាបន្ទះសំប៉ែតៗ ទំហំប៉ុនបាតដៃទុកសម្រាប់រវៃ។ ក្រោយពេល មូរសំឡីបានហើយ គេយកសំឡីនោះទៅរវៃហួតជាសរសៃអំបោះ។
- “រហាត់រវៃ” ដែលធ្វើពីឈើ និងឫស្សី ជាប្រដាប់សម្រាប់រវៃហួតកប្បាស ឲ្យកើតជាសរសៃអំបោះ។ ការរវៃអំបោះនេះ មានភាពស្មុគស្មាញបន្តិចទម្រាំច្នៃបានពីភាពជាសំឡីទៅជាសរសៃអំបោះ។
- ពេលបានជា សរសៃអំបោះរួចហើយ គេត្រូវយកអំបោះនោះទៅ “កុង” ឬហៅម្យ៉ាងទៀតថា “រង្វឹង” ជាដុំៗ ដោយ ដាក់រហាត់កុង ដើម្បីធ្វើអំបោះឲ្យចេញជាចង្វាយៗ សម្រាប់យកទៅកួតទឹក និងជ្រលក់ល័ក្ខយក ពណ៌នៅដំណាក់កាលបន្ទាប់។
- “ការជ្រលក់ល័ក្ខ” ជាដំណាក់កាលសំខាន់នៃការងារតម្បាញ ដ្បិតគេត្រូវមានចំណេះច្នៃល័ក្ខ ធ្វើពណ៌ និងត្រូវចេះ បច្ចេកទេសជ្រុលកផង។ ជាធម្មតា គេចាត់ទុកពណ៌ដែលល្អក្នុងការងារតម្បាញ គឺពណ៌បានពីល័ក្ខធម្មជាតិ ហើយពណ៌នោះជាប់បានយូរ និងស្អាតជាងពណ៌ល័ក្ខគីមី។ ល័ក្ខធម្មជាតិ អាចច្នៃបានពណ៌ផ្សេងៗ គេចែកជាពណ៌មេមាន៤គឺ ក្រហម លឿង ខៀវ និងខ្មៅ។
- “ឲ្យបាយ” ឲ្យបាយ គឺធ្វើអំបោះឆៅឲ្យ ស្វិតល្អលែងផុយ ដូចកាលនៅឆៅហើយអាចប្រើការបានច្រើនមុខ។ វិធីធ្វើ គឺ យកអំបោះត្រាំទឹកបាយ ឬទឹកដែលត្រាំសាច់បាយលាយទឹកឲ្យជ្រាយដូចបបរ ហើយ

ចំហុយទាល់តែអំបោះស្វិត។ តំណក្រោយមក ក្នុងដំណាក់កាលនេះគេអាចយកអង្ករកិនជាម្សៅ ហើយចាក់ទឹកត្រាំ និងលាយវត្ថុធាតុផ្សេងៗទៀតបើជំនួសបាយវិញ។

- "អន្ទង" ការអន្ទងនេះ គឺដើម្បីបែងចែកសរសៃអំបោះរៀបលើធ្មេញឈើតាមពណ៌ ត្រៀមសម្រាប់ត្បាញ។
- "ថ្ករ" ការថ្ករគឺថ្ករលើកី បន្ទាប់ពី លើកអំបោះដាក់កីរៀបចំរួច ដោយយកឈើដាមសំប៉ែតមកស៊កចន្លោះធ្មេញឈើ លើ និងក្រោម សរសៃអំបោះបែងឲ្យចេញជាគោមក្រឡា។ ជាធម្មតា គោមក្រឡាក្រមាខ្មែរមាន៥បែបគឺ ក្រឡាតូច ល្មមបួនជ្រុងស្មើឬហៅថាក្រឡាចត្រង្គ ក្រឡាបួនជ្រុងទ្រវែង ឬហៅថាកូឡាថ្នាំងអំពៅ ក្រឡាកាត់ឬ ហៅថាក្រឡាភ្លោះ ក្រឡាកញ្ចក់ និងក្រឡាស្រកាលេញ។
- "ត្បាញ" ការត្បាញ នេះ គឺធ្វើឡើងនៅលើកី។ តាមឯកសារ កីបុរាណមានប្រវែងប្រមាណ៤ ទៅ៥ម៉ែត្រ ហើយជាទូទៅគ មានឆ្លាក់ក្បូរក្បាច់រចនាយ៉ាងវិចិត្រលើរបស់មួយនេះ រហូតឆ្លាក់ក្បាច់ដល់ទាំងត្រល់ផង។ ដោយឡែក ទើបច្ចុប្បន្នគឺមានប្រវែង ប្រហែល២ ម៉ែត្រប៉ុណ្ណោះ។ ក្នុងដំណាក់កាលត្បាញនេះ "ត្រល់" ក៏ជារបស់សំខាន់ដែរ ដ្បិតវាប្រើ សម្រាប់បោះនាំសរសៃសូត្រម្តងមួយសរសៃៗ បង្កើតបានជាក្រមា។ ត្រល់នេះ មានរាងប្រហាក់ ប្រហែលទឹក ហើយខាត់យ៉ាងរលោង ដើម្បីងាយស្រួលបោះនាំសរសៃសូត្រក្នុងពេលត្បាញ។[10]



រូបភាពទី១ ៖ ការត្បាញក្រមាជាមួយកីបុរាណ

**២.៤.១.២. ការត្បាញតាមបែបទំនើប** (**កីស្វ័យប្រវត្តិ**)

តាមការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ កាលដំបូងឡើយប្រជាជនខ្មែរគេនៅប្រើកីបុរាណ តរាប់រយឆ្នាំមកហើយ ប៉ុន្តែដោយមានការអភិវឌ្ឍន៍ពីមួយសម័យកាលទៅមួយសម័យកាលយើងបានសង្កេតឃើញថា មកដល់បច្ចុប្បន្ននេះប្រជាជនខ្មែរភាគច្រើនឈប់ប្រើប្រាស់កីតម្បាញបែបបុរាណទៀតហើយ ភាគច្រើន គេវិវត្តន៍មកប្រើ

[10] ឆ្នាំ២០១៧ អត្ថបទស្រាវជ្រាវពីក្រមា. *ក្រមាខ្មែរ*

ប្រាស់កីពាក់កណ្តាលស្វ័យប្រវត្តនិងបន្តមកដល់ កីស្វ័យប្រវត្តិ ភាគច្រើនព្រោះចំណាយពេលតិច តែចំណេញច្រើន។

របៀបនៃការតម្បាញកីពាក់កណ្តាកស្វ័យប្រវត្តិ៖

- អំបោះ៖ គឺគេប្រើអំបោះ ដែលបានទិញចូលស្រាប់ ពុំត្រូវចំណាយពេលជ្រលក់អំបោះខ្លួនឯងទៀតទេ។គេនិយមប្រើអំបោះហុង ឬអំបោះឆៅដែលនាំចូលមកពីក្រៅប្រទេស ដែលមានពណ៌ស្រាប់ៗ និងមានច្រើនពណ៌ ច្រើនជម្រើសតាមតម្រូវការដែលចង់បាន។
- ការខារអំបោះដាក់ខ្នារ៖ គឺគេប្រើគ្រឿងម៉ាស៊ីន សម្រាប់ខារ ព្រោះវាចំណាយពេលតិច និងបានផលច្រើន ជាងខារអំបោះដោយដៃ។
- អន្ទង៖ ការអន្ទងអំបោះដាក់ជារមូលសម្រាប់យកទៅត្បាញក៏គេប្រើម៉ាស៊ីនដែរ។
- ត្បាញ៖ ក្នុងការត្បាញនេះ គេមិនចំណាយពេលឈរ ឬអង្គុយធាក់កីដូចមុនទេគឺគេប្រើម៉ូទ័រសម្រាប់ដំណើរការកី ដោយគ្រាន់តែចុចកុងតាក់បើក នោះកីដំណើរការស្វ័យប្រវត្ត ហើយយើងគ្រាន់តែចាំប្តូរត្រល់នៅពេលអស់អំបោះ និងចាំពិនិត្យអំបោះដាច់តែប៉ុណ្ណោះ។

កីបែបថ្មីនេះត្បាញបានលឿនហើយទទួលបានទន្និផលច្រើនជាងកីបុរាណ ពោលគឺក្នុង១ថ្ងៃគេអាចតម្បាញបានពី២៥ទៅ៣០ក្រមាក្នុងមួយកី ពិសេសវាពុំសូវប្រើ កម្លាំងមនុស្សប៉ុន្មានទេមនុស្សម្នាក់អាចគ្រង់គ្រងហូតទៅដល់២ទៅ៣កី ពោលគឺគ្រាន់តែភ្ជាប់ចរន្តអគ្គិសនីទៅ ម៉ាស៊ីននោះដើរភ្លាម។ ក្រមាត្បាញពីអំបោះហុង ឬអំបោះឆៅនេះ មានពណ៌ច្រើនយ៉ាងណាស់ ដែលអាចបំពេញតាមតម្រូវការដែលយើងចង់បាន ហើយបើយើងដើរសង្កេតមើលនៅក្នុងភូមិជ្រោយ ឃើញគេត្បាញ និងដាក់ ហាលក្រមានៅស្ទើរគ្រប់ផ្ទះ គឺបានន័យថាអ្នកស្រុកកៀនស្វាយនេះគេប្រកបរបរត្បាញក្រមា សឹងតែទាំងអស់គ្នា។ សព្វថ្ងៃ នៅតែមានជាងដែលចេះតម្លើងកីនៅក្នុងតំបន់នេះ ហើយនៅបន្តផលិតដាក់លក់ឲ្យអ្នកស្រុក និងអ្នកមកពីឆ្ងាយៗផងដែរ។



រូបភាពទី២ ៖ ការត្បាញក្រមាជាមួយកីស្វ័យប្រវត្តិ

## ២.៤.២. ការវិវត្តន៍នូវរបៀបប្រើប្រាស់របស់មនុស្ស

### ២.៤.២.១. ការប្រើប្រាស់របស់មនុស្សសម័យដើម

ខ្មែរគឺជាជាតិសាសន៍មួយមានបញ្ញាឆ្លាតវៃប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការត្បាញវៃផលិតជាសំពត់ ភួយ មុងសារ៉ុង ក្រមា ហូលជាមួង និងខោអាវផ្សេងៗទៀតតាំងពីសម័យបុរាណកាលមក។ ពិសេសចំពោះក្រមារបស់ខ្មែរដែលជនជាតិខ្មែរនិយមផលិត និងប្រើប្រាស់តាំងពីបុរាណ រហូតមកដល់សព្វថ្ងៃ ព្រោះតែរបស់ដែលងាយស្រួលប្រើ បានគ្រប់ទម្រង់បត់បែនបានគ្រប់ស្ថានកាល ទើបក្រមាខ្មែរជារបស់មួយដែរប្រជាជនខ្មែរពុំអាចខ្វះបាន ប្រៀបដូចជាផ្នែកមួយនៃជីវិត។

ក្រមាខ្មែរធ្វើអំពីអំបោះសំឡី កប្បាស់ សំឡី គ ឬសូត្យ។ ក្រមាផ្តល់អត្ថប្រយោជន៍ជាច្រើនណាស់សម្រាប់ជនជាតិខ្មែរក្នុងការប្រើប្រាស់នាសម័យដើមដូចជា៖

- ក្រមាត្រូវបានគេប្រើប្រាស់ជាសំពត់ប្រចាំក្នុងគ្រួសារ ដូចជាស្លៀកនៅផ្ទះ ស្លៀកមុជទឹក ចងពុង ដណ្តប់លើរាងកាយ ជូតខ្លួនប្រាណ វេចខ្ចប់សម្ភារផ្សេងៗ។ អ្នកខ្លះយកក្រមាបង់ក ក្រវាត់ចង្កេះ រុំក្បាល ធ្វើការងារដែលមើលទៅ រាងស្វាហាប់ និងក្លាហានសក្តិសមជាខ្មែរពិតៗ។ ពិសេសអ្នកស្រុកស្រែចំការនិយមប្រើជាងអ្នកនៅទីក្រុង។
- ជនអ្នកកាន់ព្រះពុទ្ធសាសនានៅកម្ពុជាយើង ប្រជាជននាសម័យនេះតែងនិយមប្រើក្រមាពាក់ពានារុំចំហៀងស្មា ដែលយកលំនាំតាម ព្រះពុទ្ធ (គ្រងលើស្មាខាងឆ្វេងទម្លាក់កន្ទុយក្រមាមកខាងស្តាំ) ក្នុងគោលបំណងបញ្ជាក់ថា ខ្លួនកំពុងតែគោរពភាវនាធម៌ ឬអ្នកកាន់សាសនាព្រះពុទ្ធ ឬជាអ្នកស្លូតត្រង់កាន់សីលទាន។
- តាមរយៈការស្រាវជ្រាវកន្លងមក យើងបានឃើញការលើកឡើងរបស់អតីតកងទ័ពមួយចំនួនបង្ហាញនូវការប្រើប្រាស់ក្រមារបស់កងទ័ព ដោយការប្រើក្រមាជាការចាំបាច់ណាស់ ព្រោះបើគិតទៅគេយល់ថាក្រមាប្រៀបដូចជាឧបករណ៍សឹកមួយយ៉ាងមានប្រយោជន៍ ដូចជា ពេលចេញទៅប្រយុទ្ធនៅសមរភូមិដើម្បីកំចាត់សត្រូវ កាលណាកាំភ្លើងមិនដំណើរការ ភាសាបារាំងហៅថា *Accedent* (អាក់.សឺ.ដង់) យុទ្ធជនត្រូវត្រដាងលាតសន្ធឹងក្រមាលើដី រួចសឹមរុះរើ ឧបករណ៍អាវុធ របស់ខ្លួនដើម្បីកុំឲ្យឧបករណ៍កាំភ្លើងនៅរាយប៉ាយ ហើយប្រសិនបើមានសត្រូវមកយាយីយុទ្ធជនរូបនោះវេចខ្ចប់ក្រសោបសម្ភារនោះរត់រកកន្លែងសុវត្ថិភាពសិនដើម្បីតម្លើងកាំភ្លើងឲ្យដំណើរការវិញ។ ក្នុងករណីត្រូវរបួស យុទ្ធជនអាចហែកក្រមានោះដើម្បីចងរុំមុខរបួសឃាត់ឈាមកុំឲ្យហូរដើម្បីរង់ចាំយុទ្ធមិត្តពេទ្យមកជួយសង្គ្រោះ។

### ២.៤.២.២. ការប្រើប្រាស់ក្រមារបស់ខ្មែរបច្ចុប្បន្ន

មកដល់សម័យបច្ចុប្បន្នទំនើប ក្រមាខ្មែរនៅតែមានការពេញនិយមក្នុងការប្រើប្រាស់របស់ប្រជាជនខ្មែរ បើទោះបីជាការប្រើប្រាស់ខ្លះវិវត្តន៍ទៅ តាមសម័យកាល ក៏ដោយ ក៏ការនិយមក្នុងការប្រើប្រាស់នៅតែមាន។ ការរស់នៅរបស់ប្រជាជននៅជនបទនៅដដែលដោយពួកគាត់នៅតែ និយមប្រើក្រមាតាមបែបបុរាណ ក៏ប៉ុន្តែបរិបទរស់នៅរបស់អ្នកទីក្រុងមានការផ្លាស់ប្តូរ ដូច្នេះការសម្ភារៈប្រើប្រាស់ មួយចំនួនក៏គេផ្លាស់ប្តូរដែរ ដូចជាក្រមាពួកគេមិននិយមយកមកប្រើប្រាស់ដូចពីមុនទៀតឡើយ តែគេមានគំនិតច្នៃប្រឌិតប្រើប្រាស់តាមនិយមបែបថ្មី។

ការផ្លាស់ប្តូរក្នុងប្រើប្រាស់ក្រមាខ្មែរតាមរយៈគំនិតច្នៃប្រឌិតរបស់ប្រជាជនខ្មែរបច្ចុប្បន្ន៖

- ប្រជាពលរដ្ឋខ្មែរនៅតាមជននៅតែបន្ត ប្រើប្រាស់ក្រមាខ្មែរតាមទំនាប់ដែលគាត់បានប្រើតាំង ពីដើមមក បើទោះបីជាអ្នកទីក្រុងបាន ប្រើប្រាស់ក្រមាតាមបែបថ្មីកែច្នៃថ្មីក្រោយ។ ប្រជាជន នៅជនបទខ្លះក៏បានយកក្រមាដែលបាន ច្នៃប្រឌិតបែបថ្មីមកប្រើដែរ តែក៏នៅតែមិនបានបោះបង់នៅទំលាប់ក្នុងការប្រើប្រាស់តាមបែបបុរាណដែរ។
- នាពេលបច្ចុប្បន្នក្រមាខ្មែរ នៅតែពេញនិយម ពីសំណាក់អ្នកប្រើប្រាស់ ពោលគឺគេបានកែឆ្នៃពីក្រមាសាមញ្ញដែលយើងប្រើប្រាស់ប្រចាំថ្ងៃទៅជាសម្លៀកបំពាក់ដែលពេញនិយម (FASHION)។ ដោយយើងតែងតែបានឃើញ តារាក្នុងវិស័យសិល្បៈមួយចំនួន និយមយកក្រមា ទៅប្រើប្រាស់ក្នុងកម្មវិធីផ្សេងៗ ដូចជាការដើរបង្ហាញម៉ូត ចូលរួមការប្រគុំតន្ត្រីនានា។ល។ តាមរយៈវិធីសាស្ត្រក្នុងការច្នៃម៉ូតរៀងៗខ្លួន។ ដែលជាកត្តាជម្រុញ អោយប្រជាជនប្តូរបរិបទក្នុងការប្រើប្រាស់ក្រមាតាមពួកគេ ពិសេសទង្វើទាំងនេះក៏បានបង្ហាញអោយជាតិសាស្ត្រដ៏ទៃបានស្គាល់ពីក្រមាខ្មែរបន្ថែមទៀត។
- មនុស្សមួយចំនួនធំនៅទៅទីក្រុងតែងប្រើយកក្រមាទោកាត់ជារបស់ ប្រើប្រាស់ប្រចាំថ្ងៃតែ មានជម្រើក្នុងការប្រើប្រាស់ច្រើនលើសពីការប្រើប្រាស់ប្រចាំថ្ងៃ និងទាន់សម័យ ដូចជា កាត់ម៉ូតកាបូបគ្រប់ប្រភេទ ខ្សែរចង់សក់ ប៉ូចូកសក់ មួក ម៉ាស់ និងជាបន្តោងសោរដែលមានរូបគ្រប់ប្រភេទ។ល។
- សព្វថ្ងៃយើងតែឃើញក្រមា ស្ទើរគ្រប់កន្លែង ក្នុងរូបរាងជាសម្លៀកបំពាក់ ពិសេសយើងតែឃើញមានប្រជាជនខ្មែរនិយមប្រើសម្លៀកបំពាក់ ដែលបានច្នៃចេញក្រមានៅក្នុងកម្មវិធីផ្សេង ដូចជាចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ពិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ។
- ក្រមាក៏ជាវត្ថុអនុសាវរីយ៍មួយដ៏ពិសេស ដែលប្រជាជនខ្មែរតែងតែនិយមប្រើប្រាស់ជាកាដូរជូនដល់ភ្ញៀវកិត្តិយសដែលបានចូលរួមក្នុងកម្មពិធីអាពាហ៍ពិពាហ៍របស់ពួកគេ ដោយការបត់ក្រមាប្រភេទតូច ជារូបរៀបប្ញរតូចល្អមសមរម្យ និងស្រស់ស្អាតសាកសមជាកាដូរក្នុងកម្មពីធីមង្គលការប្រជាជនខ្មែរ។

- នៅតំបន់ទេសចរណ៍មួយចំនួនធំនៅក្នុងប្រទេសកម្ពុជាយើង ពលរដ្ឋនៅតំបន់នោះតែងតែលក់វត្ថុអនុស្សាវរីយ៍ខ្មែរ ពិសេសស្នាដៃតម្បាញខ្មែរដែលមានក្រមាផងដែរដូចជា ក្រមាសូត្រ ក្រមាអំបោះកូតុង (Cotton)។ល។




រូបភាពទី៣ ៖ ក្រមាដែលជាកាដូរសម្រាប់ជូនដល់ភ្ញៀវកិត្តិយស ចូលរួមក្នុងកម្មពិធីអាពាហ៍ពិពាហ៍

# ជំពូកទី៣៖ ស្ថានភាពទូទៅនៃសិប្បកម្មក្រមា នៅភូមិព្រៃឈរអំពិល

# ជំពូកទី៣៖ ស្ថានភាពទូទៅនៃសិប្បកម្មក្រមានៅភូមិជ្រោយអំពិល

## ៣.១. ទីតាំងភូមិសាស្ត្រនៃសិប្បកម្មផលិតក្រមា

សម្រាប់ទីតាំងភូមិដែលប្រជាជនខ្មែរនិយមប្រកបរបរ តម្បាញក្រមានេះមានស្ទើរគ្រប់ទឹសទីនាសម័យដើម ព្រោះវាជាការងារពេញនិយមមួយសម្រាប់ស្ត្រីខ្មែរ ដូច្នេះវាមានស្ទើរគ្រប់ទឹសទីនៃប្រទេសកម្ពុជា។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ បន្ទាប់ពីការសិក្សាស្រាវជ្រាវ យើងបានសង្កេតឃើញថា មានតែតំបន់មួយចំនួនប៉ុណ្ណោះដែលនៅផលិតក្រមា ក្នុងបែបផែនជាសហគមន៍ និងមួយចំនួនធំទៀតផលិតជាឯកជន ក្នុងនោះយើងបានស្រាវជ្រាវឃើញមានខេត្តដែលនៅផលិតក្រមាដូចជា ខេត្តសៀមរាប ខេត្តកណ្ដាល ខេត្តកំពុងចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង។ ចំពោះការតម្បាញបែបជាសហគមន៍ កើតមាននៅក្នុងខេត្តសៀមរាប ស្វាយរៀង និងកំពុងចាម និងខេត្តផ្សេងៗភាគច្រើនតម្រាញជាឯកជន។

នៅក្នុងករណីការស្រាវជ្រាវនេះយើងបាន ជ្រើសរើសតំបន់មួយ ដែលមានការតម្បាញក្រមា បែបផែនជាលក្ខណៈ បែបឯកជនរៀងៗខ្លួននៅក្នុងភូមិមួយ ដែលមានប្រជាជនប្រមាណជាង ១០០គ្រួសារដែលកំពុងប្រកបរបរតម្បាញក្រមានេះ។ តំបន់សិប្បកម្មក្រមានោះស្ថិតក្នុង ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជាអតីតស្រុកគៀនស្វាយដែលគ្រប់បានស្គាល់ថាជាតំបន់ដែលមានអ្នកផលិតក្រមាច្រើនជាងគេនៃប្រទេសកម្ពុជា។

ក្រុមយើងខ្ញុំជ្រើសរើសយកតំបន់នេះមកធ្វើការសិក្សាស្រាវជ្រាវព្រោះ ពួកយើងបាន សង្កេតឃើញមានភាពផ្លាស់ប្តូរជាច្រើននៅក្នុងតំបន់នេះ ទាំងបច្ចេកទេសនៃការផលិត ការវិវត្តន៍ក្នុងការផលិត ទំហំទីផ្សារដែលមានការប្រកួតប្រជែង និងការបញ្ហាដែរធ្វើអោយសិប្បករនៅតំបន់នោះខ្លះបានបោះបង់នូវមុខរបរនេះចោល។

## ៣.២. ករណីសិក្សាស្រាវជ្រាវភូមិជ្រោយអំពិល

### ៣.២.១. ប្រវត្តិទីតាំងភូមិសាស្ត្រ

តាំងពីសម័យឆ្នាំ១៩៧៩ នៅក្នុងភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ស្រុកគៀនស្វាយ ខេត្តកណ្ដាល ជាភូមិមួយដែលសម្បូទៅដោយប្រជាជនដែលមានជីវិតពឹងផ្អែកទៅលើកវិស័យសិប្បកម្មក្រមា ក្រៅពីការងារធ្វើចំការ នេះបើតាមការអះអាងពីលោកតាមេភូមិ នឹងចាស់ៗមួយចំនួននៅក្នុងតំបន់នោះ។ ការនិយមតម្បាញក្រមានេះព្រោះវាជាការងារមួយដែលងាយស្រួល ពិសេសសម្រាប់ស្ត្រី ដោយការងារនេះជួយអោយស្ត្រីអាចរកចំណូលបានបន្ថែម និងមានពេលវាលាគ្រប់គ្រាន់សម្រាប់មើលថែទាំគ្រួសារផងដែរ។ កាលដើមឡើយនៅក្នុងភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ គេនិយមត្បាញកីកន្ត្រាក់ (កីធាក់ជើង បោះត្រល់នឹងដៃ) ជាបុរាណដែលមានរាប់រយសម័យកាលមកហើយ។ កីកន្ត្រាក់នេះអាចជួយជ្រោមជ្រែង ជីវភាពគ្រួសារប្រជាពលរដ្ឋបានមួយផ្នែកធំ

ប៉ុន្តែបុរាណមួយនេះមិនអាចអោយប្រជាសិប្បករផលិតបានច្រើននោះទេ គឺក្នុងមួយថ្ងៃសិប្បករត្បាញបានត្រឹម ០៣ ទៅ ០៤ក្រមាប៉ុណ្ណោះ។

រហូតមកដល់ឆ្នាំ១៩៩៥ វិស័យសិប្បកម្មក្រមាខ្មែរនេះមានការវិវត្តន៍ ដោយក្រមាកាន់តែមានភាពរីកល្បីល្បាញ ធ្វើអោយតម្រូវការទីផ្សារក្រមាមានការកើនឡើងខ្ពស់ទើបប្រជាជន កើតមាននៅភាពច្នៃប្រឌិតទៅលើទម្រង់ការផលិតកី ផ្ទាល់តែម្តង។ លោកតាម្នាក់ដែលមានឈ្មោះថា អ៊ុយ ផៃ ដែលជាប្រជាជនរស់ក្នុងស្រុកគៀនស្វាយនោះ មានមុខរបរជាជាងឈើ(តុ ទូ គ្រែ) ដោយលោកមានប្រពន្ធជាអ្នកត្បាញក្រមាហើយបានឃើញនូវ ឱកាសនេះ លោកបានកើតនូវគំនិតគិតកែច្នៃកី ពីកីបន្ទ្រក់ ទៅជាកីតម្បាញពាក់កណ្តាលស្វ័យប្រវត្តិ ពោលគឺជាកីដែលតម្បាញដោយធាក់ជើងដែលអាចត្បាញបានក្រមាពី ១០ ទៅ១៥ក្រមាក្នុងមួយថ្ងៃ ក្នុងនៃសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ប៉ុន្តែដោយឃើញពី ផលប្រយោជន៍នៃកីតម្បាញពាក់កណ្តាលស្វ័យប្រវត្តិនេះ ប្រជាជនជាច្រើនបានធ្វើការបញ្ជាទិញ កីពាក់កណ្តាលស្វ័យប្រវត្តិទៅតម្បាញដែរ ទើបពួកគាត់បំពេញតម្រូវការទីផ្សារបាន។

បន្ទាប់ពីនោះមកលោកតា អ៊ុយ ផៃ បានទៅរស់នៅប្រទេសវៀតណាម រយៈពេល មួយឆ្នាំ រហូតដល់ឆ្នាំ ១៩៩៨ លោកតាបានយកចំណេះចេះដឹងបន្ថែម មកពីវៀតណាមមកច្នៃកីបន្ថែម ពីកីពាក់កណ្តាលស្វ័យប្រវត្តិមកជាកីបែបទំនើបនោះគឺកីស្វ័យប្រវត្តិ សម្រាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមគ្រួសារ ព្រោះគ្រួសារលោកតាប្រកបរបរតម្បាញក្រមានេះតាំងពីដើមមក។ តែដោយកីស្វ័យប្រវត្តិនេះ ផ្តល់អត្ថប្រយោជន៍ទើបអ្នកភូមិស្នើរអោយធ្វើបន្ថែមសម្រាប់លក់ លោកតាក៏បានយកកូនជាងបន្ថែមដើម្បីជួយធ្វើកីស្វ័យប្រវត្តិនេះលក់ក្នុងភូមិ ហើយក៏បានចែកចាយទៅតាមបណ្តាលខេត្តជាច្រើនផងដែរ ពោលគឺភាគច្រើនជាកីដែលចេញពីស្នាដៃរបស់លោកតា។ កំឡុងឆ្នាំនោះលោកអាចលក់កីថ្មីបានតម្លៃគិតជាមាស ១តម្លឹង ២ជីក្នុងមួយកី វាជាតម្លៃថ្លៃគួរសម ព្រោះកំឡុងពេលនោះពុំមានជាងណាអាចធ្វើបានក្រៅពីលោកតាឡើយ។ រហូតមកដល់ឆ្នាំ២០០០ ទៅ២០០៥ លោកតាអាចលក់បានតម្លៃ ៦០០ដុល្លាក្នុងមួយកី ព្រោះមានជាងផ្សេងៗដែលធ្លាប់ជាកូនជាងលោកតា បានចេះហើយធ្វើលក់ដែរ ទើបតម្លៃទីផ្សារមានការប្រកួតប្រជែង។ រហូតដល់វ័យលោកតាជរាលោកតាក៏មិនបានបន្តធ្វើកីលក់ទៀត តែកូនជាងលោកតាគ្រប់ៗគ្នាបានរៀនចេះចំណេះជំនាញក្នុងការធ្វើកី ហើយបន្តធ្វើលក់ដោយខ្លួនឯងតៗរហូតមក។ សព្វថ្ងៃនេះតម្លៃកីថ្មី គឺ ១២៥០ដុល្លាក្នុងមួយកី និងកីចាស់គឺចាប់ពី ៧០០ដុល្លាចុះ ទៅតាមសភាពរបស់កី។

រហូតមកដល់បច្ចុប្បន្ន ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានការអភិវឌ្ឍមកប្រើប្រាស់កីដែលមានភាពជឿនលឿន គឺកីម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ ទាំងស្រុង ដោយពុំនៅមានឃើញសិប្បករម្នាក់ណានៅតម្បាញ កីកន្ត្រាក់ ឬកីបុរាណទៀតឡើយ។

### ៣.២.២. ប្រជាជន

តាមរយៈការសាកសួរព័ត៌មានពីរលោកតា **គឹម ស៊ុន** ដែលជាប្រធានភូមិក្នុងតំបន់នោះលោកបានអោយដឹងថានៅក្នុងភូមិជ្រោយអំពិលមានប្រជាជនប្រមាណ ២៨០៨នាក់ ស្រី ១៤៦៣នាក់ ដែលសរុបចំនួន ៧០០ គ្រួសារក្នុងឆ្នាំ២០២៣នេះ ក្នុងនោះមានប្រជាជន ប្រមាណជាង១០០គ្រួសារដែលនៅពឹងផ្អែកលើការប្រកបរបរសិប្បកម្មក្រមានេះ។ ទិន្នន័យនេះជាទិន្នន័យដែលធ្លាក់ចុះយ៉ាងគត់សម្គាល់មួយបើធៀមជាមួយទិន្នន័យជាង ១០ឆ្នាំ មុន។ ប្រជាជន ដែលឈប់ប្រកបរបតម្បាញក្រមានេះភាគច្រើនព្រោះខាតបង់ពីការប្រកបរបនេះទើបសម្រេចចិត្តបោះបង់ ហើយបែជាទៅបម្រើការងារ ធ្វើការរោងចក្រ ប្រកបការរកស៊ីផ្សេងៗទៅតាមសម្ថភាពរបស់ពួកគេ។




| | Year 2000 | Year 2005 | Year 2010 | Year 2015 | Year 2023 |
|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | 570 | 579 | 600 | 645 | 700 |
| ចំនួនគ្រួសារតម្បាញក្រមាសរុប | 200 | 186 | 165 | 163 | 100 |

តារាងទី៥៖ តារាងក្រាហ្វិចចំនួនគ្រួសារប្រជាជនដែលប្រកបរបរក្រមាក្នុងភូមិជ្រោយអំពិល

### ៣.២.៣. ស្ថានភាពគ្រួសារប្រកបរបរសិប្បកម្មតម្បាញក្រមា

បច្ចុប្បន្នអ្នកត្បាញក្រមាជាច្រើនគ្រួសារ បានផ្លាស់ប្តូរពីការត្បាញដោយដៃចំណាយពេលយូរ មកជាការប្រើប្រាស់ម៉ាស៊ីនអគ្គិសនីដែលធ្វើឱ្យអ្នកត្បាញចំណេញពេលវេលាតិច និងមានភាពងាយស្រួល។ ការផ្លាស់ប្តូរក្នុងនៃវិធីសាស្ត្រក្នុងការតម្បាញនេះ បានធ្វើអោយប្រជាពលរដ្ឋមានភាពងាយស្រួលនិងចំណេញច្រើន។

ប្រជាជនក្នុងភូមិជ្រោយអំពិលដែលប្រកបរបតម្បាញក្រមាសព្វថ្ងៃនេះភាគច្រើនជាមនុស្សស្រី ជាស្ត្រីមេផ្ទះ និងស្ត្រីមេមាយ ដោយការតម្បាញក្រមាជាការងារមួយដែលងាយស្រួលក្នុងការធ្វើ អាចអោយពួកគេមានពេលគ្រប់គ្រាន់ក្នុងការមើលថែគ្រួសារក្រៅពីការធ្វើការងារ។ សិប្បករតម្បាញក្រមា ទាំងនោះបានលើកឡើងថាវាជាការងារដែលងាយស្រួល បើទោះបីគេមិនបានតម្បាញជាលក្ខណៈទ្រង់ទ្រាយធំ ដោយមានត្រឹម ១ទៅ២គី ក៏

អាចរកចំណូលបន្ថែម បានក្រៅពីរធ្វើចំការ និង មើលថៃគ្រួសារ ដែលអាចជា ផ្នែកមួយជួយស្រួលបន្ទុកក្នុងការចំណាយក្នុងគ្រួសារ។

### ៣.២.៣.១. ទិន្នន័យ និងស្ថានភាពគ្រួសារសិប្បករ

ដូចដែលបានលើកឡើងនៅចំណុចខាងលើ នៅក្នុងភូមិជ្រោយអំពិលមានគ្រួសារសារប្រមាណជា ១០០ គ្រួសារដែលបានប្រកបរបតម្បាញក្រមា ក្នុងនោះមាន២០គ្រួសារដែលក្រុមយើងខ្ញុំបានចុះសាកសួរ និងស្រង់ទិន្នន័យដោយផ្ទាល់ជាមួយពួកគាត់។ ទិន្ន័យអំពីស្ថានភាពគ្រួសារ និងស្ថានភាពក្នុងការប្រកបរបរតម្បាញក្រមារបស់សិប្បករទាំង២០គ្រួសារមានបង្ហាញនៅក្នុងតារាងខាងក្រោម។

| តារាងទិន្នន័យនៃស្ថានភាពគ្រួសាទាំង២០គ្រួសារ | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះ | ភេទ | អាយុ | រយះពេល | ចំនួនកី | ចំនួនកម្មករ | ផលិតបាន/១ថ្ងៃ |
| ផៃ ផាន់នី | ស | 53 | 24ឆ្នាំ | 14 | 7 | 450-500 |
| ផៃ ចាន់ធី | ស | 50 | 30ឆ្នាំ | 10 | 3 | 200-250 |
| ជុំ ស្រស់ | ស | 35 | 10ឆ្នាំ | 3 | តម្បាញផ្ទាល់ | 60-70 |
| ណូ យឿន | ស | 60 | 30ឆ្នាំ | 2 | តម្បាញផ្ទាល់ | 50-60 |
| លី គីមសាន | ប | 50 | 20ឆ្នាំ | 21 | 8 | 600-650 |
| អ៊ុយ សុខន | ស | 60 | 35ឆ្នាំ | 7 | 2 | 150-160 |
| លឹម អាង | ស | 55 | 30ឆ្នាំ | 7 | 2 | 150-160 |
| ហ៊ី ឡាយហេង | ប | 40 | 10ឆ្នាំ | 10 | 4 | 250 |
| ហ៊ី ឡាយហៀង | ស | 45 | 20ឆ្នាំ | 11 | 4 | 400-450 |
| ឃ្លាំង សុខា | ស | 57 | 25ឆ្នាំ | 4 | 1 | 80-90 |
| រី កនីកា | ស | 35 | 17ឆ្នាំ | 15 | 7 | 500-520 |
| រុន ណារី | ស | 30 | 10ឆ្នាំ | 3 | តម្បាញផ្ទាល់ | 60-70 |
| បាន សុផល | ស | 60 | 35ឆ្នាំ | 30 | 16 | 800-900 |
| លាប ប៊ុនលី | ប | 55 | 28ឆ្នាំ | 14 | 5 | 450-500 |
| ប៊ុន ស៊ីថា | ស | 48 | 19ឆ្នាំ | 12 | 4 | 370-400 |
| ចាន់ ស៊ីមន | ស | 52 | 26ឆ្នាំ | 15 | 7 | 500-540 |
| គង់ សុវ៉ាន់ | ប | 56 | 20ឆ្នាំ | 12 | 6 | 400-450 |
| នៅ មុំ | ស | 48 | 24ឆ្នាំ | 6 | 2 | 140-150 |
| គីម សុខ | ស | 46 | 14ឆ្នាំ | 2 | តម្បាញផ្ទាល់ | 50-60 |
| សៀម ហេង | ប | 61 | 37ឆ្នាំ | 18 | 7 | 550-580 |

តារាងទី៦៖ តារាងទិន្នន័យនៃស្ថានភាពគ្រួសាទាំង២០គ្រួសារ

### ៣.២.៣.២. ស្ថានភាពគ្រួសារសិប្បករមួយចំនួន

### ក. គ្រួសារអ្នកស្រី ផៃ ផាន់នី

ចំពោះករណីគ្រួសារអ្នកស្រី ផៃ ផាន់នី អ្នកស្រីបានលើកឡើងថា អ្នកជាសិប្បករតម្បាញដែលទទួលមុខរបរនេះបន្តពីឪពុកម្តាយតាំងពីឆ្នាំ ១៩៩៩ មកដល់បច្ចុប្បន្ន។ សព្វថ្ងៃអ្នកស្រី មានកីចំនួន 14កី ក្នុងនោះមានកម្មករតម្បាញចំនួន 7នាក់ផងដែរ។ រយៈពេលជាងម្ភៃឆ្នាំនៃការប្រកបរបរតម្បាញក្រមានេះអ្នកស្រីជួបប្រទះនូវបញ្ហាជាច្រើន ពិសេសបញ្ហាទីផ្សារដែលជាកត្តាដ៏ធំមួយសម្រាប់លោកស្រីកន្លងមក។ តម្លៃក្រមាមានការឡើងចុះមិនទៀងមិនមានស្ថេរភាព ជួនលក់ដាច់អស់ ជួនលក់មិនចេញទាល់តែសោះតម្លៃទីផ្សារទាបហួសការរំពឹង ឯពេលខ្លះទៀតអ្នកផលិតក្រមាស្ទើរតែមិនទាន់សម្រាប់ទីផ្សារ។

បើទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈជាង២០ឆ្នាំនេះ របរតម្បាញក្រមានេះបានជួយអ្នកស្រីជាច្រើនក្នុងជីវភាពរស់នៅ។ អ្នកស្រីទទួលបានផលប្រយោជន៍ជាច្រើនពីការវិស័យសិប្បកម្មក្រមានេះ ដោយក្រមាបានជួយជ្រុំជ្រែងជីវិតគ្រួសារអ្នកស្រីអោយបានធូរធារ មានហូបចុកគ្រប់គ្រាន់តាមតម្រូវការ។ លោកស្រីផៃ ផាន់នី បានបន្ថែមទៀតថា ក្រមានេះបានជួយអោយកូនលោកស្រីបានរៀនបានខ្ពង់ខ្ពស់ ពោលគឺរៀនដល់មហាវិទ្យាល័យថែមទៀតផង។

លើសពីនេះអ្នកស្រី បានលើកឡើងទៀតថា របរតម្បាញក្រមាជាមុខរបរមួយដ៏ងាយស្រួលសម្រាប់ស្ត្រីគ្រប់រូបក្នុងការធ្វើការ ដោយសិប្បករអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែទាំគ្រួសារផង នឹងពេលវេលារកប្រាក់បន្ថែមបានទៀតផង។



រូបភាពទី៤៖ ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ផាន់នី

### ខ. គ្រួសារអ្នកស្រី ផៃ ចាន់ធី

បន្តដល់ករណីគ្រួសារលោកស្រី ផៃ ចាន់ធី អ្នកស្រីគឺជា ស្ត្រីមេមាយ ដែលមានជីវិតពឹងផ្អែកលើការប្រកបរបរតម្បាញក្រមាចិញ្ចឹមគ្រួសារ។ អ្នកស្រី បានទទួលចេះនូវចំណេះដឹងក្នុងការតម្បាញពីរឪពុកម្ដាយបានតាំងពីតូច រហូតអ្នកស្រីមានគ្រួសារ និងមានកូនពីរនាក់ បន្ទាប់ពីស្វាមីអ្នកស្រីបានចែកឋានអ្នកស្រីបានពឹងផ្អែកលើតែរបរតម្បាញក្រមាមួយមុខគត់ សម្រាប់ចិញ្ចឹមជីវិតនិងផ្គត់ផ្គង់គ្រួសារ។

អ្នកស្រីផៃ ចាន់ធី ផ្ដើមការងារតម្បាញនេះ តាំងពីរឆ្នា ១៩៩៣ មកម្លេះ។ សព្វថ្ងៃអ្នកស្រីមានកីចំនួន ១១ និង កម្មករចំនួន ៣នាក់ នៅក្នុងកម្មការម្នាក់អាចត្រួតពិនិត្យកីបានបី និងពេលខ្លះអ្នកស្រីចូលទៅតម្បាញផ្ទាល់ដោយខ្លួនឯង។

សិប្បកម្មក្រមានេះពិតជាបានធ្វើអោយគ្រួសារអ្នកស្រីរស់បានធូរជារ និងអាចអោយកូនបានរៀនដល់បញ្ចប់ថ្នាក់សកលវិទ្យាល័យ និងម្នាក់ទៀតកំពុងបន្តថ្នាក់ សកលវិទ្យសល័យផងដែរ។ ដូចសិប្បករតម្បាញដ៏ទៃដែរអ្នកស្រី ជ្រើសរើសយកការតម្បាញក្រមានេះព្រោះវាជាការងារដែលងាយស្រួលសម្រាប់ស្ត្រីគ្រប់មានឱកាសក្នុងការមើលថែគ្រួសារនិង អាចរកចំណូលបន្ថែមបាន។



រូបភាពទី៥៖ ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ចាន់ធី

### គ. អ្នកស្រី បាន សុផល

ចំពោះអ្នកស្រី បាន សុផល អ្នកស្រីជាសិប្បករម្នាក់ដែលប្រកបអាជីវកម្មតម្បាញក្រមាខ្មែរនេះជាលក្ខណៈខ្នាតធំមួយនៅក្នុងចំណោមគ្រួសារសិប្បករទាំងអស់ ហើយក៏មានរយៈពេលយូរផងដែរ។ អ្នកស្រី បានប្រកបរបរតម្បាញក្រមានេះតាំងពីអ្នកស្រីមិនទាន់ពេញវ័យ ពោលគឺតាំងពីជំនាន់ឪពុកម្ដាយអ្នកស្រីមកម្លេះ។ អ្នកស្រីបាន

រៀនចំណេះដឹងអំពីការតម្បាញនេះ បានយ៉ាងច្បាស់លាស់ ដោយអ្នកស្រីបានយល់ឃើញពីគុណប្រយោជន៍និងគុណសម្បត្តិរបរតម្បាញក្រមានេះថាអាចនឹងជួយជ្រោមជ្រែងជីវភាពគ្រួសារអ្នកស្រីនៅថ្ងៃមុខនបានប្រសើរ ទើបអ្នកស្រីបន្តធ្វើមុខរបររហូតមកដល់សព្វថ្ងៃ។ សព្វថ្ងៃអ្នកស្រីមានរោងតម្បាញក្រមាដ៏ធំមួយក្បែរផ្ទះ ដែលក្នុងនោះអ្នកស្រីមានកីចំនួន៣០កី រហាត់អន្ទង់ចំនួន០១ ម៉ាស៊ីនខាអំបោះចំនួន០៣ កម្មករតម្បាញក្រមា និងកម្មករផ្នែកផ្សេងៗប្រមាណជា ២៥នាក់។

អ្នកស្រីបានបន្តទៀតថា មុខរបរតម្បាញក្រមានេះពិតជាបានផ្តល់ផលប្រយោជន៍ច្រើនណាស់មកដល់អ្នកស្រី និងគ្រួសារ។ ក្រមាបានធ្វើអោយជីវភាពអ្នកស្រីកាន់តែធូរជាជាងមុន និងមានលទ្ធិភាពអោយកូនរៀនបានចប់គ្រប់ៗគ្នា កូនបានរៀនដល់វិជ្ជៈបណ្ឌិតថែមទៀតផង។ បន្ថែមពីនេះ បើទោះបីជាវិស័យសិប្បកម្មក្រមានេះពេលខ្លះមានបញ្ហាប្រឈមមួយចំនួនក៏ដោយ ក៏វានៅតែអាចផ្តល់ប្រយោជន៍ដល់អ្នកស្រី ដោយអ្នកផ្ទាល់មានវិធីសាស្ត្រផ្ទាល់ខ្លួនសម្រាប់ដោះស្រាយនូវវិបត្តិទាំងនោះ។

នាពេលអនាគតអ្នកស្រីនឹងនៅតែបន្តប្រកបរបរសិប្បកម្មក្រមានេះ ដោយអ្នកស្រីបានបង្រៀនកូនច្បងរបស់អ្នកស្រីបានចេះដឹងអំពីវិស័យក្រមានេះ និងអោយគាត់ធ្វើបន្តពឹងផ្អែកលើវិស័យនេះបន្ទាប់ពី អ្នកស្រីទៅថ្ងៃមុខទៀត។

គុណសម្បត្តិដែលក្រមាបានផ្តល់អោយអ្នកស្រី បាន សុផលះ

- មានជីវភាពធូរជារ
- មានលទ្ធិភាពអោយកូនៗបានរៀនគ្រប់ៗគ្នា
- មានលទ្ធិភាពសាងសងផ្ទះធំស្កឹមស្កៃ
- អាចជួយដល់អ្នកក្រីក្រក្នុងភូមិ (ផ្តល់ជាការងារ)
- មានមុខមាត់ក្នុងសង្គម

**ឃ. លោក សៀម ហេង**

លោកសៀម ហេង ជាសិប្បករមួយក្នុងចំណោមប្រជាជនក្នុងភូមិដែលបានមានជីវិតពឹងផ្អែកលើវិស័យសិប្បកម្មកក្រមាខ្មែរនេះ ដែលលោកមានសិប្បកម្មក្រមាខ្នាតកណ្តាល។ លោកបានលើកឡើងថាដើមឡើយលោកមិនមែនអ្នកមានស្រុកកំណើតនៅទីនេះទេ ពោលគឺលោកជាអ្នកខេត្តតាកែវ ប៉ុន្តែលោកបានការប្រពន្ធមករស់នៅក្នុងភូមិជ្រោយអំពិលនេះ ដែលគ្រួសារខាងប្រពន្ធ ជាអ្នកប្រកបរបរតម្បាញក្រមានេះ តាំងពីដើមមក។ ដោយលោកហេង បានឃើញពីគុណសម្បត្តិនៃវិស័យសិប្បកម្មក្រមានេះ លោកក៏បានសិក្សាស្វែងយល់ អំពីដំណើរការផលិតរបស់ក្រមា ហើយក៏បានបើកតំណើរការតម្បាញតែម្តង។

លោកបានបន្ថែមទៀតថា ក្នុងកំឡុងពេលចាប់ផ្តើមដំបូងលោកមានត្រឹម២ គីប៉ុណ្ណោះពោលគឺលោកតម្បាញ១កី និងភរិយាលោកត្បាញ១កី ហើយជំជាន់នោះគឺមានត្រឹមតែកីកន្ត្រាក់តែប៉ុណ្ណោះ។ ដោយការវិវត្តន៍ពីមួយឆ្នាំទៅមួយឆ្នាំ កាន់តែមានភាពរីកចម្រើន ការតម្បាញក៏មានការផ្លាស់ប្តូរ ដោយគាត់ចាប់ផ្តើមមានកីតម្បាញស្វ័យប្រវត្តិមានអាចតម្បាញ បានក្រមាច្រើនក្នុងរយៈពេលខ្លី ច្រើនជាងពេលប្រើជាកីកន្ត្រាក់ ព្រោះផលិតបានទាន់តម្រូវការទីផ្សារ។ នៅក្នុងពេល ដែលផ្ទះសិប្បកម្មក្រមាមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើអោយមានកំណើនចំនួនកី និងមានកម្មករតម្បាញបន្ថែមទៀតផង។ សព្វថ្ងៃលោកសៀមហេងមានកីតម្បាញចំនួន១៨កី និងអ្នកតម្បាញចំនួន០៧នាក់ ដោយក្នុងមួយនាក់ត្បាញបាន២ទៅ៣កី។

ចំពោះសិប្បកម្មក្រមានេះពិតជាបានជួយលោកជាច្រើនដូចជាសិប្បករដ៏ទៃទៀតដែរ។ ចាប់តាំងពីលោកផ្តើមមុខរបរនេះមក គ្រួសារមានជីវភាពកាន់តែល្អប្រសើរដោយលោកមានភាពឆ្លាតវៃក្នុងការស្វែងរកទីផ្សារ និងរកដំណោះស្រាយពេលមានវិបត្តិសេចក្តីកិច្ចផ្សេងៗ ក្នុងរយៈពេលណាមួយ។

សមិទ្ធផលដែលលោកទទួលបាន គឺលោកបានរស់នៅក្នុងជីវភាពធូរធារ ល្អប្រសើរ មានសមត្ថភាពសាងសង់ផ្ទះធំ និងអាចបញ្ជូនកូនទៅរៀនបានខ្ពង់ខ្ពស់។ នាពេលអនាគត លោកមិនប្រាកដចិត្តថាលោកនឹងមានកូនស្នងមុខរបរត្បាញនេះឡើយព្រោះកូនៗរបស់លោកសុទ្ធតែបានរៀនចប់ នឹងមានការងារធ្វើរៀងៗខ្លួន។ ប៉ុន្តែជាយ៉ាងណាលោកបានអះអាងថាលោកនៅតែបន្តមុខរបរមួយនេះរហូតដល់លោកអស់លទ្ធិភាពក្នុងការគ្រប់គ្រង។



រូបភាពទី៦ ៖ ការចុះសម្ភាសន៍ជាមួយលោក សៀម ហេង

### ៣.២.៤. ប្រភេទ និងទំហំ ក្រមាក្នុងភូមិជ្រោយអំពិល

ក្រមាមានច្រើនសណ្ឋាន ច្រើនទំហំផ្សេងៗគ្នាទៅតាមចំណង់ចំណូលចិត្តនិយមរបស់សិប្បករ និងតម្រូវការទីផ្សារ។ តាមស្រុកភូមិខ្លះគេធ្វើក្រមាប្រភេទខ្នាតធំ និងភូមិស្រុកខ្លះទៀតធ្វើក្រមាប្រភេទខ្នាតតូច ដែលមានប្រវែងបណ្តោយ និងទទឹងខុសៗគ្នា។

ចំពោះភូមិជ្រោយអំពិលផ្ទាល់សិប្បករទាំងអស់ នៅក្នុងតំបន់នេះ និយមធ្វើក្រមាក្នុងខ្នាតនិងប្រភេទតែមួយ ព្រោះតែទីផ្សារតម្រូវ នេះបើការលើកឡើងរបស់សិប្បករផ្ទាល់។

ប្រភេទ និងខ្នាតរបស់ក្រមា ដែលប្រជាពលរដ្ឋនៅក្នុងភូមិជ្រោយអំពិលនិយមធ្វើមានដូចជា៖

#### ៣.២.៤.១. ក្រមាវិញជាយខ្នាតតូច

ក្រមាវិញជាយខ្នាតតូច វាជាប្រភេទក្រមាអំបោះឆៅដែលមានខ្នាតតូច ហើយមានវិញជាយនៅខាងចុងទើប គេហើយថាក្រមាវិញជាយតូច។ មានបណ្ដោយប្រវែង ១.៦០ម៉ែត្រ និងមានទទឹងប្រវែង ០.៤០ម៉ែត្រ។ ប្រភេទ ក្រមានេះគេនិយមយកប្រើប្រាស់វាទៅ បត់ជាកាដូដូចតូចសម្រាប់ជូន ក្នុងកម្មពិធីផ្សេងៗ ហើយគេក៏អាចប្រើ ប្រាស់ក្រមាប្រភេទនេះសម្រាប់បង់កធ្វើជាស្កាយ ឬសម្រាប់ជូតញើសផងដែរ។ល។



រូបភាពទី៧៖ ក្រមាវិញជាយខ្នាតតូច។ មានទំហំ បណ្ដោប្រវែង ១.៦០ម៉ែត្រ និងទទឹងប្រវែង ០.៤០ម៉ែត្រ។

#### ៣.២.៤.២. ក្រមាវិញជាយខ្នាតធំ

ក្រមាវិញជាយខ្នាតធំ វាជាប្រភេទក្រមាអំបោះឆៅដែលមានខ្នាតធំ ហើយមានវិញជាយនៅខាងចុងទើបគេ ហើយថាក្រមាវិញជាយធំ។ ក្រមានេះមានបណ្ដោយប្រវែង ១.៨០ម៉ែត្រ និងមានទទឹងប្រវែង ០.៧០ម៉ែត្រ។ ក្រមា ប្រភេទនេះគេប្រើប្រាស់ជាដូចបានច្រើនបែបបទ ពិសេសគេតែងឃើញប្រជាជនខ្មែរប្រើជាទៅបង់ក ឬទទូរហើយ ក៏ប្រើប្រាស់ជាកាដូក្នុងពិធីផ្សេងៗផងដែរ។ល។



រូបភាពទី៨ ៖ ក្រមាវិញជាយខ្នាតធំ។ មានទំហំ បណ្ដោយ ប្រវែង ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៧០ម៉ែត្រ។

#### ៣.២.៤.៣. ក្រមាអំបោះឆៅ

ក្រមាអំបោះឆៅ មានបណ្តោយប្រវែង ១.៨០ម៉ែត្រ និងមានទទឹងប្រវែង ០.៨៥ម៉ែត្រ។ ក្រមាអំបោះឆៅប្រភេទនេះគេអាចប្រើបានគ្រប់បែបសណ្ឋានដូចជា អាចចងជាអង្រឹងអោយក្មេង, កម្រាល, ស្លៀក, ដណ្តប់, បិទបាំង, ជូតក្បាល, ទទូរ, ជូតញើសឬខ្លួនប្រាណ, ចោមពុំ, ផ្លាស់ងូតទឹក, រហូតដល់ធ្វើជាចំណង, ថ្នក់ ឬចង់ដាក់របស់របរផ្សេងៗតាមសេចក្តីត្រូវការ។ល។ អ្វីដែលពិសេសនេះគឺក្រមាប្រភេទនេះទន់ជក់ទឹកបានល្អ។



រូបភាពទី៩ ៖ ក្រមាអំបោះឆៅ។ មានទំហំ បណ្តោយប្រវែង ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៨៥ម៉ែត្រ។

#### ៣.២.៤.៤. ក្រមាអំបោះហុង

ក្រមាអំបោះហុង មានបណ្តោយប្រវែង ១.៧ម៉ែត្រ និងមានទទឹងប្រវែង ០.៨ម៉ែត្រ។ ក្រមាអំបោះហុងនេះគេអាចប្រើវាបានគ្រប់សណ្ឋានដូចក្រមាអំបោះឆៅដែរ គ្រាន់ក្រមាប្រភេទនេះមិនទន់ មិនជក់ទឹកដូចក្រមាអំបោះឆៅឡើយ។



រូបភាពទី១០ ៖ ក្រមាអំបោះហុង។ មានទំហំ បណ្តោយប្រវែង ១.៧០ម៉ែត្រ និងទទឹងប្រវែង ០.៨០ម៉ែត្រ។

### ៣.២.៥. ស្ថានភាពទីផ្សារ

ក្រមាខ្មែរជាសម្ភារៈមួយជួយជម្រុញការរស់នៅ របស់ប្រជាពលរដ្ឋអោយកាន់តែមានភាពងាយស្រួលក្នុងការរស់នៅ។ ដោយភាពងាយស្រួលបត់បែនរបស់ក្រមាទើបក្រមាមានការពេញនិយមក្នុងការប្រើប្រាស់មករាប់

រយឆ្នាំ ទីផ្សារក្រមាក៏មានភាពលូតលាស់បានល្អប្រសើរ។ រហូតមកដល់ការរស់នៅរបស់មនុស្សមានការវិវត្តន៍ទៅ ការប្រើប្រាស់ក្រមាក៏មានការអន់ថយ ជាហេតុធ្វើអោយលំនឹងទីផ្សារគ្មានភាពស្ថិតស្ថេរ។

ដោយភាពច្នៃប្រឌិតរបស់មនុស្សដើម្បីអភិរក្សថែរក្សា ផលិតផលខ្មែរអោយបានគង់វង្ស និងពង្រឹងទីផ្សារឡើងវិញ ប្រជាពលរដ្ឋខ្មែរផ្តើមគំនិតច្នៃប្រឌិតក្រមាទៅជាសម្លៀកបំពាក់ និងជាសម្ភារៈនិយមបែបថ្មីដើម្បីទាក់ទាញចំណាប់របស់អតិថិជនអោយត្រឡប់មកប្រើប្រាស់ក្រមាឡើងវិញ។

ក្រមាក៏ត្រូវបានយកមកប្រើជាវត្ថុធាតុដើមមួយយ៉ាងសំខាន់ក្នុងការកែច្នៃឲ្យចេញជាវត្ថុសម្រេចផ្សេងៗ ដែលត្រូវបានមើលឃើញថាចាប់ផ្តើមទទួលការពេញនិយមនិងទទួលស្គាល់ពីសំណាក់ប្រជាជនខ្មែរជាបណ្តើរៗ។ ការកែច្នៃផលិតផលក្រមាឲ្យទៅជាវត្ថុប្រើប្រាស់ផ្សេងៗ ប្រហែលជារឿងមួយថ្មីសម្រាប់កម្ពុជា ដោយហាក់ទើបតែផុសផុលនូវភាពល្បីល្បាញនាប៉ុន្មានរយៈចុងក្រោយនេះ ខណៈដែលការពិតទៅ ក្រមាខ្មែរ ត្រូវបានបង្កើតនិងប្រើប្រាស់តាំងពីយូរណាស់មកហើយ។

### ៣.២.៦. ករណីទីផ្សារក្រមាក្នុងភូមិជ្រោយអំពិល

តាមការសិក្សាស្រាវជ្រាវ និងកិច្ចសម្ភាសន៍ពីសិប្បករតម្បាញក្រមាផ្ទាល់បានអោយរបស់ក្រុមយើងខ្ញុំបានអោយដឹងថា តម្លៃក្រមាក្នុងមួយឆ្នាំទៅមួយឆ្នាំមិនមានស្ថេរភាពទេ វាឡើងចុះទៅតាមរដូវរបស់វា។ ឆ្នាំខ្លះលក់បានថ្លៃ ឆ្នាំខ្លះលក់បានថោករហូត ឆ្នាំខ្លះតម្លៃទីផ្សារទាបហួសកម្រិតរហូតដល់ធ្វើអោយ ពួកគាត់បង្ខំចិត្តស្តុកទុកក្រមាទុកចោលមិនលក់តែម្តង ដែលជាការខាតបង់យ៉ាងខ្លាំងចំពោះពួកគាត់។

ចាប់ពីខែ១ដល់ខែ៥ ជាខែល្អដែលអាចលក់ដាច់ ព្រោះគេច្រូតផង គេការផង បុណ្យផង។ រដូវច្រូតកាត់ជារដូវកាលមួយដែលក្រមាលក់ដាច់ក្នុងតម្លៃល្អសមរម្យ ព្រោះជារដូវកាលសម្បូរសប្បាយ រដូវកាលមនុស្សធ្វើបុណ្យទាន ដោយគេនិយមទិញក្រមាទៅធ្វើបុណ្យផង និងទុកសម្រាប់ប្រើប្រាស់ក្នុងរដូវកាលថ្មីផង។ ក្នុងចន្លោះខែនេះដែរ ប្រជាជនខ្មែរភាគច្រើននិយមរៀបពិធីអាពាហ៍ពិពាហ៍ រយៈពេលនោះក្រមាក៏លក់ដាច់ ព្រោះពលរដ្ឋខ្មែរតែងប្រើប្រាស់ក្រមាប្រភេទបង់ករតូចៗ ធ្វើជាការជូរជូនដល់ភ្ញៀវកិត្តិយសដែលមកចូលរួមពិធីរបស់ពួកគេ។ ដូច្នេះក្នុងរយៈខែទាំងនេះសិប្បករតម្បាញក្រមាខ្មែរនៅក្នុងភូមិជ្រោយអំពិល មានភាពរីករាយក្នុងការផលិតក្រមាសម្រាប់លក់ណាស់ព្រោះទីផ្សារល្អ និងតម្លៃក៏ល្អដែរ។

ចំណែកឯរដូវកាល ដែលលំបាកលក់បំផុតសម្រាប់ពួកគាត់ គឺ ចាប់ពីខែ៧ដល់ខែ១ ជាខែដែលការលក់ធ្លាក់ចុះ លក់លែងដាច់ ពិសេសខែភ្លៀង លក់មិនចេញ ពោលគឺគ្មានទីផ្សារទាល់តែសោះ ។ សម្រាប់ម្ចាស់សិប្បកម្មទទួលរងនូវផល លំបាកណាស់កំឡុងពេលនោះ ត្រូវចំណាយដើមទន់ច្រើន ព្រោះបើលក់មិនដាច់ក៏នៅតែត្បាញដែរមិនអាចឈប់បានទេ ព្រោះបើមិនធ្វើអាចនឹងបាត់កម្មករអស់ ដូចនេះត្រូវចំណាយបើទោះបីមិនមានចំណូលក៏ដោយ។

## ៣.២.៧. តម្លៃទីផ្សារក្រមា




| | Year 2000 | Year 2010 | Year 2015 | Year 2020 | Year 2021 | Year 2022 | Year 2023 |
|---|---|---|---|---|---|---|---|
| ក្រមាវិញជាយធំ | - ៛ | 3,000៛ | 3,600៛ | 2,600៛ | 2,600៛ | 3,600៛ | 4,000៛ |
| ក្រមាវិញជាយតូច | - ៛ | 2,000៛ | 2,500៛ | 1,600៛ | 1,600៛ | 2,500៛ | 3,000៛ |
| ក្រមាបត់អំបោះឆៅ | 7,000៛ | 5,000៛ | 6,000៛ | 4,000៛ | 4,000៛ | 6,000៛ | 6,000៛ |
| ក្រមាបត់អំបោះហុង | 2,000៛ | 2,500៛ | 3,200៛ | 3,200៛ | 3,200៛ | 3,200៛ | 3,000៛ |

តារាងទី៧៖ តារាងទិន្នន័យតម្លៃក្រមាក្នុងភូមិជ្រោយអំពិល

## ៣.២.៨. ទីផ្សារក្នុងសម័យកាល COVID-19

នៅក្នុងរដូវកាល COVID-19 សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះជាខ្លាំង គ្រប់វិស័យទាំងអស់បានធ្លាក់ចុះ ប្រជាពលរដ្ឋជួបប្រទះការលំបាកគ្រប់ៗគ្នា។ ក្នុងនោះវិស័យសិប្បកម្មក្រមាខ្មែរក៏មានការធ្លាក់ចុះជាខ្លាំង គ្មានទីផ្សារលក់ដូរ ម្ចាស់សិប្បកម្មទទួលរងការខាតបង់គ្រប់គ្រប់គ្នា អ្នកខ្លះនៅបន្តធ្វើទាំងការខាតបង់ ព្រោះគេមានប្រាក់តម្កល់ សម្រាប់ចំណាយ ក៏ប៉ុន្តែម្ចាស់សិប្បកម្មខ្លះ សម្រេចចិត្តបិទបណ្តោះអាសន្ន និងខ្លះទៀតបោះបង់បោលទៅរកការងារថ្មីតែម្តង។

តាមរយៈកិច្ចសម្ភាសន៍ជាមួយលោក **លី គំសាន្ត** ដែលមានអាយុ ៥០ឆ្នាំ ដែលជាសិប្បករមួយរូបក្នុងចំណោមសិប្បករទាំងអស់ក្នុងភូមិជ្រោយអំពិល និងមានបទពិសោធន៍ក្នុងវិស័យសិប្បកម្មក្រមានេះមករយៈពេល ២០ឆ្នាំមកហើយ និងសព្វថ្ងៃលោកមានសិប្បកម្មក្រមាដែលមានកីចំនួន ២១កី និងកម្មករចំនួន ៨នាក់។ លោកបានលើកឡើងថាតម្លៃនៃក្រមា មិនសូវជាមានភាពស្ថិតស្ថេរទេ វាឡើងចុះតាមរដូវការ ចំពោះតម្លៃក្រមាលក់ចេញរបស់លោកក៏ដូចជាសិប្បករផ្សេងៗទៀតដែរ។ លោកបានបន្ថែមទៀតថាក្រមានៅប៉ុន្មានឆ្នាំមុននេះមានការធ្លាក់ចុះខ្លាំង ពិសេសកំឡុងពេល COVID-១៩ វាពិតជាពិបាកខ្លាំងសម្រាប់លោកព្រោះក្រមានៅពេល

នោះ គ្មានទីផ្សារទាល់តែសោះក្នុងឆ្នាំ២០២០ និង២០២១ ហើយបើតោះបីជាអ្នកទីផ្សារតែតម្លៃទាបខ្លាំង ដែលជាតម្លៃមួយដែលធ្វើអោយលោកខាតទាំងស្រុងប្រសិនបើលោកលក់ក្រមានោះ។

ដូចន្នេះកំឡុងពេលនោះលោកសម្រេចចិត្តស្តុកទុកក្រមា មិនលក់ហូតទៅដល់រាបម៉ឺនក្រមា ដំណើរការតម្បាញចេះតែទៅមុខមានតែចំណាយ គ្មានចំណូល បានធ្វើអោយលោកខាតបង់អស់រាប់ពាន់ដុល្លា ដោយពុំអាចទប់ទល់រួចលោកក៏បានសម្រេចចិត្តផ្អាកមួយរយៈពេល រហូតដល់មានទីផ្សារឡើងវិញទើបលោក កម្សាន្តបន្តធ្វើឡើងវិញ។ លោកក៏បានអំពាវនាវឱ្យមានការគាំទ្រផលិតផលក្រមាខ្មែរ ដើម្បីឱ្យការត្បាញក្រមាដែលជាកេរ្តិ៍តំណែលដូនតាមួយនេះ រីកចម្រើនបន្តទៀត។



រូបភាពទី១១៖ ការចុះសម្ភាសន៍ជាមួយ លោក លី កំសាន្ត

# ជំពូកទី៤៖ ការពិភាក្សាលើលទ្ធផល ស្រាវជ្រាវ

# ជំពូកទី៤៖ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៤.១. គុណសម្បត្តិលើវិស័យសិប្បកម្មក្រមាខ្មែរ

ខ្មែរជាជាតិសាសន៍មួយមានប្រាជ្ញាឆ្លាតវៃប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការត្បាញវៃផលិតជាសំពត់ ភួយ មុងសារ៉ុង ក្រមា ហូលផាមួង និងខោអាវផ្សេងៗទៀតតាំងពីសម័យបុរាណកាលមក។ ពិសេសក្រមាខ្មែរនេះតែម្តង ក្រមាជារបស់ដែលជនជាតិខ្មែរនិយមផលិតនិងប្រើប្រាស់តាំងពីបុរាណរហូតមកដល់សព្វថ្ងៃ។ ក្រមាមិនត្រឹមតែបានផ្តល់ជាប្រយោជន៍នៃការប្រើប្រាស់ជាច្រើនដល់ប្រជាជនខ្មែរនោះទេ វាក៏បានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋក្នុងស្រុកអោយមានជីវភាពរស់នៅសមរម្យមួយ។ លើសពីនេះ វាក៏បានកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេស ដែលជាផ្នែកមួយអាចជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៤.១.១. ផ្តល់ឱកាសការងារដល់ប្រជាជន (ករណីភូមិជ្រោយអំពិល)

យោងតាមយៈសម្តីរបស់លោក **គឹម ស៊ុន** ដែលជាប្រធានភូមិជ្រោយអំពិល បានអោយដឹងថាប្រជាជនដែលមានរស់នៅក្នុងភូមិនេះមិនមានការធ្វើចំណាកស្រុកឡើយ ព្រោះតែវិស័យសិប្បកម្មក្រមានេះ បានផ្តល់ការងារដែលមានចំណូលគ្រប់គ្រាន់ដល់ពួកគេ ដោយមិនចាំបាច់បែកឆ្ងាយពីគ្រួសារ ក៏ពួកគេអាចរកចំណូលចិញ្ចឹមគ្រួសារបានដែរ។



រូបភាពទី១២៖ ការចុះសម្ភាសន៍ជាមួយ លោកមេភូមិ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ

ប្រជាពលរដ្ឋទាំងចាស់ក្មេង ប្រុសស្រី ប្រមាណជា៣០០នាក់ អាចទទួលបានការងារនិងប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារពីការសិប្បកម្មតម្បាញក្រមានេះ ហើយនៅក្នុងចំនួននេះមានកម្មករមួយចំនួនជាអ្នកក្រៅតំបន់ ពោលគឺអ្នកខ្លះមកពីរខេត្តស្វាយរៀង និងខ្លះទៀតមកពីខេត្តព្រៃវែង។

ឱកាសការងារដែលប្រជាពលរដ្ឋដែលទទួលបានដូចជា៖

- កម្មករតម្បាញ៖ ប្រជាពលរដ្ឋនៅក្នុងភូមិជ្រោយអំពិល ដែលមានវ័យពេញកម្លាំង ទាំងប្រុសស្រីអាចធ្វើការជាកម្មករតម្បាញក្រមាអោយម្ចាស់សិប្បកម្មផ្សេងៗដែលនៅជិតផ្ទះ ប្រសិនបើពួកគេគ្មានលិទ្ធភាពក្នុងការបង្កើតផ្ទះសិប្បកម្មដោយខ្លួនឯង។ ដោយការធ្វើជាកម្មករនេះក៏អាចរកចំណូលបានច្រើនគួរសមដែរ ដោយត្បាញគិតជាចំនួនក្រមា តម្លៃគិតតាមប្រភេទក្រមាផងដែរ។ ហើយទាំងនោះមិនត្រូវចំណាយលើការហូបចុក និងស្នាក់នៅ ដោយម្ចាស់សិប្បកម្មជាអ្នកផ្គត់ផ្គង់ទាំងអស់។
- រកប្រាក់បន្ថែមពីការវិញក្រមា៖ កម្មករ កម្មការនី ទាំងនេះត្បាញពីម៉ោង ៦ព្រឹក ដល់ ៦យប់ ហើយក្នុងកំឡុងពេកសំរាកពេលយប់ពួកគេក៏អាចយកប្រាក់បន្ថែពីលើប្រាក់តម្បាញតាមរយៈ ការវិញជាយក្រមា ឬការបត់បូរដែលគេប្រើជាកាដូអនុសាវរីយ៍ផងដែរ។ ការងារនេះពូកគាត់អាចទទួលបាន ៣០០រៀលក្នុងមួយក្រមា។
- ជាងកី៖ ចំពោះបុរសៗដែលមាន វ័យកំពុងពេញកម្លាំងអាចរៀនជា ជាងកី ដែលអាចតម្លើងគ្រឿងម៉ាស៊ីន ឬធ្វើកីសម្រាប់លក់ចេញទៀតផង។ លើសពីនេះពួកគេក៏អាច ជួសជុលកីដែលមានបញ្ហា ឬខូចអោយម្ចាស់សិប្បកម្មផ្សេងៗបានជារៀងរាល់ថ្ងៃ ដោយអាចជួយអោយពួកគេរអាចរកចំណូលក្រៅបន្ថែមបាន។
- អ្នកខាអំបោះ៖ ស្រីៗដែលមិនមានចំណេះក្នុងការតម្បាញក្រមា ពួកគេអាចរកប្រាក់ចំណូលបន្ថែមបានដោយការធ្វើជាអ្នកខាអំបោះដាក់ខ្នាសម្រាបដាក់ក្នុងត្រល់។ ការងារមួយនេះពុំសូវជាលំបាកអ្វីឡើងព្រោះបច្ចុប្បន្ននេះគេពុំមាន ខាអំបោះដោយដៃទៀតឡើយគឺគេខាអំបោះដោយប្រើប្រាស់ម៉ាស៊ីនសម្រាប់ដំណើរការដូចជាកីតម្បាញដែរ។
- វិញជាយ៖ ចំពោះមនុស្សចាស់នៅក្នុងភូមិដែលមិនអាចចេញទៅរកការងារនៅខាងក្រៅបាន ពួកគាត់ក៏អាចជ្រើសរើសយក ការងារនៅក្នុងវិស័យសិប្បកម្មក្រមានេះបានផងដែរ ដោយចាស់អាចជាអ្នកវិញជាយក្រមាដោយគ្រាន់តែអង្គុយវិញក្រមានឹងជើង ពួកគាត់ក៏អាចរកចំណូលបានផងដែរ។ ដោយតម្លៃក្នុងការវិញក្រមានេះពួកគាត់អាចទទួលបាន ៣០០០រៀល នៅក្នុង១០ក្រមា។
- អ្នកដើរថ្ពរ៖ ប្រជាជនខ្លះ បើទោះបីជាពួកគាត់មិនមានកីសម្រាប់តម្បាញក្រមា ក៏ប៉ុន្តែពួកគាត់អាចរកប្រាក់ចំណូលបានបន្ថែមរយៈការដើរថ្ពរក្រមាអោយម្ចាស់សិប្បកម្មផ្សេរៗបាន (ថ្ពរ ក្រមាជាការ ត សសៃ

អំបោះពី រមូលភ្ជាប់ទៅកីសម្រាប់តម្បាញ) ការតក្រមាននេះពួកគាត់អាចទទយលបាន ១០០០០រៀល ក្នុងមួយកី និងចំណាយពេលត្រឹមតែមួយព្រឹក ឬយ៉ាងយូរមួយថ្ងៃ។

- អ្នកអន្ទង៖ ពលរដ្ឋមួយចំនួនក្នុងភូមិជ្រោយអំពិល អាចរកប្រាក់ផ្គត់ផ្គង់គ្រួសារបានតាមរយៈការអន្ទង ("អន្ទង" ការអន្ទងនេះ គឺដើម្បីបែងចែកសរសៃអំបោះរៀបលើធ្មេញឈើតាមពណ៌ ដាល់រមូល ត្រៀមសម្រាប់ត្បាញ)។ សិប្បករចំណាយពេលត្រឹមតែ៤ ទៅ ៥ម៉ោងសម្រាប់ការសន្ទងអោយបានមួយរមូល ហើយមួយរមូលនៅទៀតសោត ពួកគាត់អាចទទួលបានពីចន្លោះ ៦០០០០រៀល ទៅ ១០០០០០រៀល តាមរមូលតូច ឬធំ។ វិធីសាស្ត្រក្នុងការអន្ទងនេះផងដែលមិនចំណាយពេលយូរព្រោះគេអន្ទងដោយប្រើប្រាស់ម៉ាស៊ីនដូចជាកីតម្បាញដែរ។
- ឈ្មួញកណ្ដាល៖ ឈ្មួញកណ្ដាល ក៏ជាមុខរបរមួយរបស់អ្នករស់នៅក្នុងភូមិជ្រោយអំពិល ពួកគាត់មិនមានកីសម្រាប់តម្បាញ ក៏ប៉ុន្តែពួកគាត់រកចំណូលតាមរយៈការទិញលក់ក្រមា។ ពួកគាត់ទិញក្រមាពីម្ចាស់សិប្បកម្មក្នុងភូមិ រួចលក់បោះដុំបន្តទៅអោយអ្នកផ្សារ ដូចជាផ្សារអូរឡាំពេជ្រ ឬផ្សារអូឬស្សី។
- អ្នកលក់រាយ៖ ប្រជាជនខ្លះមានលក់ក្រមាជាប្រភេទរាយនៅខាងមុខផ្ទះផ្ទាល់ នឹងមានលក់ក្រមាក្នុងរូបរាងជាក្រមាអនុសាវរីយ៍ សម្រាប់ជូនភ្ញៀវក្នុងពិធីអាពាហ៍ពិពាហ៍ផងដែរ។

### ៤.១.២. អភិវឌ្ឍន៍ក្នុងតំបន់ (ករណីភូមិជ្រោយអំពិល)

ភូមិជ្រោយអំពិលមានការអភិវឌ្ឍគួរអោយកត់សម្គាល់ ដោយប្រជាជនភាគច្រើននៅក្នុងតំបន់នោះមានភាពរីកចម្រើន។ ប្រជាពលរដ្ឋភាគច្រើមានជីវភាពធូរជាជាងមុន មានផ្ទះធំទូទំខ្ពស់ស្មើរគ្រប់ៗគ្នា។ តំបន់នេះការរីកចម្រើននៃជីវភាពរបស់ប្រជាជននាភូមិជ្រោយអំពិល មួយចំណែកធំគឺបានមកពីការប្រកបរបរតម្បាញក្រមាខ្មែរនេះឯង។

#### ៤.១.២.១. កាត់បន្ថយភាពក្រីក្រ

- ក្រមាខ្មែរបានជួយយោង ជីវភាពគ្រួសារ ប្រជាពលរដ្ឋជាច្រើន ដែលជាម្ចាស់សិប្បកម្មនៅក្នុងភូមិជ្រោយអំពិល អោយមានការរស់នៅស្រួល ហូបចុកគ្រប់គ្រាន់ រស់នៅមានជីវភាពសមរម្យ។ បើទោះបីជាសិប្បកម្មតម្បាញក្រមានេះមិនអាចអោយប្រជាពលរដ្ឋសល់ទ្រព្យធនច្រើនដូចអាជីវកម្មផ្សេងៗ តែក្រមាអាចជួយអោយអ្នកភូមិរួចផុតពីភាពក្រលំបាក។
- សិប្បកម្មតម្បាញក្រមានេះ បានជួយអោយសិប្បករអាចមាន លិទ្ធិភាពគ្រប់គ្រាន់ក្នុងការបញ្ជូនកូនទៅរៀនបានគ្រប់ៗគ្នា ពិសេសភាគច្រើនបានចប់បរិញ្ញាបត្រស្មើរគ្រប់ៗគ្នាទៀតផង។
- ក្រមាក៏ជាស្ពានមួយ ចម្លងមនុស្សទៅកាន់ភាពជាអ្នកយល់ដឹង ហើយតំបន់ដែលសំបូរទៅដោយមនុស្សដែលមានចំណេះដឹងគ្រប់គ្រាន់ ការរស់នៅរបស់ភូមិនោះក៏កាន់តែរីកចម្រើន ការអភិវឌ្ឍន៍។

- ប្រជាជនមានលទ្ធិភាពគ្រប់គ្រាន់ក្នុងការសង់គេហដ្ឋានល្អសមរម្យ បង្កើនសោភណ្ឌភាពក្នុងភូមិស្រុក ពិសេសកាន់តែមានសុវត្ថិភាពដោយប្រជាជនគ្រប់ៗគ្រួសារមានសម្ថភាពធ្វើរបង ឬដាក់កាំមេរាសុវត្ថិភាពផងដែរ។

**៤.១.២.២. ការអភិវឌ្ឍមូលដ្ឋាន**

ក្រមាជាផ្នែកមួយដែលជួយអោយជីវភាពប្រជាជនដែលរស់នៅក្នុងតំបន់ភូមិជ្រោយអំពិលនេះមានភាពល្អប្រសើរ ដែលជាកត្តានាំអោយទិដ្ឋភាពក្នុងភូមិនេះកាន់តែមានស្រស់បំព្រង ដោយប្រជាពលរដ្ឋមានសម្ថភាពក្នុងការចូលរួមជួយអភិវឌ្ឍភូមិស្រុកអោយកាន់តែមានភាពរីកចម្រើន។

ប្រជាជនបានចូលរួមចំណែកក្នុងការរៀបចំភូមិស្រុកដូចជាៈ

- ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ
- ពង្រីកប្រព័ន្ធលូបង្ហូរទឹក
- ប្រពន្ធ័ទឹកស្អាត
- ប្រព័ន្ធភ្លើងកាន់តែប្រសើរជាងមុន
- ចូលរួមឧបត្ថមក្នុងការការពារភូមិ
- រួមចំណែកអភិវឌ្ឍន៍វត្តអារាម
- អភិវឌ្ឍសាលារៀន
- អភិវឌ្ឍមន្ទីរពេទ្យបង្អែក។

**៤.២. បញ្ហាប្រឈមនៃវិស័យសិប្បកម្មក្រមា**

វិស័យសិប្បកម្មក្រមាខ្មែរក៏ត្រូវបានគេចាត់ទុកថាជាកត្តា មួយរួមចំណែកដ៏សំខាន់ដែលអាចជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែដោយនៅសម័យបច្ចុប្បន្ននេះប្រទេសជាតិមានកការអភិវឌ្ឍជឿនលឿន និងកាន់តែទំនើប ដែលធ្វើអោយវប្បធម៌ក្នុងការរស់នៅខ្លះរបស់ប្រជាជនមានការផ្លាស់ប្តូរ ដែលជាកត្តាដ៏ធំមួយនាំឲវិស័យក្រមាទទួលរងផលប៉ះពាល់ជាច្រើន។

បញ្ហាប្រឈមដ៏ធំនោះគឺគ្មានទីផ្សារ ដោយប្រជាជននាសម័យទំនើបភាគច្រើន បានបោះបង់ក្នុងការប្រើប្រាស់ក្រមា ប្តូរមកប្រើជាកន្សែងពោះគោ និងសម្ភារៈផ្សេងមកជំនួសវិញពិសេសអ្នករស់នៅទីក្រុង នាំឲទីផ្សារក្រមាមានការធ្លាក់ចុះប្រជាជនបាត់បង់សំណួលគ្រួសារ និងឳកាសការងារ។

**៤.២.១. កត្តាបញ្ហាគ្មានទីផ្សារ**

នៅគ្រប់វិស័យការងារទាំងអស់ទីផ្សារជារឿងមួយដែរសំខាន់បំផុត ក្នុងការជម្រុញអោយការងារទាំងនោះលូតលាស់ និងរីកដុះដាលទៅមុខ។ ចំពោះវិស័យសិប្បកម្មក្រមាខ្មែរនេះផងដែរ ជាវិស័យមួយដែលពឹងផ្អែកទៅ

លើទីផ្សារសុទ្ធសាធ បើមានទីផ្សារលក់ដូរសិប្បករតម្បាញក្រមាមិនមានបញ្ហាប្រឈមអ្វីទាំងអស់ ខណៈដែលវត្ថុធាតុដើមជារបស់ដែលស្រួលរកបំផុតសម្រាប់ពួកគាត់។ ក្រមាមានទីផ្សារ ឬអត់អាស្រ័យទៅលើសម័យកាលនិយម ដូចជាក្នុងពេលវេលាដែលប្រជាជនខ្មែរចាប់ផ្តើមចាប់អារម្មណ៍មកមើលក្រមា ក្នុងរូបភាពជាការកែច្នៃដូចការច្នៃក្រមាទៅជាសម្លៀកបំពាក់ កាបូប មួក ខ្សែរចងសក់។ល។ ពេលនោះក្រមាមានទីផ្សារកើនឡើងការលក់ដូររបស់សិប្បករក៏មានការរីកចម្រើនបានមួយបែល។ ដូចគ្នានេះដែរ នៅក្នុងរដូវការ ឬបុណ្យទានប្រជាជនក៏ងាយស្រួលរកទីផ្សារ។

ក៏ប៉ុន្តែក្រមា ក៏អាចជួបបញ្ហាទីផ្សារធ្លាក់ចុះនៅក្នុងរដូវវស្សាផងដែរ។ ព្រោះតែភាពធ្លាក់ចុះនៃប្រជាប្រិយភាពរបស់ក្រមា ធ្វើអោយពិបាករកទីផ្សារសម្រាប់លក់ ប្រជាជនមិននិយមយកក្រមាមកប្រើប្រាស់ជាប្រចាំថ្ងៃដូចមុនឡើង គេពុំប្រើប្រាស់ក្រមាក្នុងរស់នៅជាប្រចាំដូចជាប្រើសម្រាប់ងូតទឹក យកតាមខ្លួន ប្រើប្រាស់អន្រើង ទៀតឡើយ។

ទីផ្សារអាចនឹងពិបាកខ្លាំងដោយពេលខ្លះក្រមាលក់បានតម្លៃទាបពេក ឬមិនចេញទាល់តែសោះនេះបើតាមការលើកឡើងពីប្រជាសិប្បករតម្បាញក្រមានៅក្នុងភូមិជ្រោយអំពិល។ សិប្បករគ្រប់រូបបានលើកឡើងនៅពាក្យពេចន៍ដូចគ្នាថា (ឆ្នាំខ្លះគ្មានទីផ្សារទាល់តែសោះឈ្មួញកណ្តាលនិងអ្នកលក់រាយនៅឈប់ទទួលទិញ ដោយសារគ្មានទីផ្សារលក់ចេញគ្មានអ្នកប្រើប្រាស់ ហើយឈ្មួញខ្លះទៀត នៅទទួលទិញតែនៅក្នុងតម្លៃថោកខ្លាំងជាងតម្លៃទីផ្សារធម្មតា ព្រោះពួកគេពិបាកលក់ត ហើយលក់បានតិច ទាល់តែមានកម្មវិធីចាំចាប់ទើបមានអតិថិជនត្រូវការទិញ)។កត្តាទាំងទើបធ្វើអោយសិប្បករតម្បាញក្រមាខ្មែរគ្រប់ៗរូបមានការព្រួយបានរម្ភជារាងរាល់ឆ្នាំ។

### ៤.២.១.១. កំឡុងឆ្នាំដែលទីផ្សារធ្លាក់ចុះខ្លាំង

### ក. ឆ្នាំ២០១០ និង២០១១

ចំពោះភូមិជ្រោយអំពិល បើតាមប្រសាសន៍របស់លោក គឹម ស៊ុន ដែលជាប្រធានភូមិលោកបានលើកឡើងថា នាកំឡុងឆ្នាំ២០១០ និង២០១១ មាន១៦៥គ្រួសារក្នុងចំណោមជាង ៦០០គ្រួសារ ដែលពឹងផ្អែកទៅលើរបរធ្វើក្រមាលក់ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃនេះ តែដោយសារតែពិបាករកទីផ្សារ បានធ្វើអោយប្រជាជនប្រមាណ ៣០ភាគរយ នៃប្រជាជនដែលធ្វើក្រមា បានផ្អាក និង ខ្លះឈប់តែម្តង។ ទោះជាយ៉ាងណាក៏ដោយប្រជាពលរដ្ឋខ្លះបានលើកឡើងថា ពួកគាត់ពិតជាមិនមានភស្តុតាងជាក់លាក់ណាមួយមកអំណាសអំណាងអំពីមូលហេតុដែរធ្វើអោយទីផ្សារធ្លាក់ចុះខ្លាំងរហូត ដល់មានគ្រួសារប្រមាណជាង៥០ គ្រួសារបានបោះបង់ចោលដោយពួកគាត់ដឹងត្រឹមថាកាលនោះគ្មានទីផ្សារទាល់តែសោះបើទោះបីជាពួកកាត់ចង់លក់ក្នុងតម្លៃទាបណាមួយក៏ដោយ។

សិប្បករម្នាក់ក្នុងចំណោមសិប្បករដែលមានបំណងបោះបង់មុខរបរនោះបានលើកឡើងថា ឆ្នាំនោះក្រមាមួយអាចលក់ចេញតម្លៃ ១៧០០រៀល បើបៀបធៀបពីឆ្នាំទៅលក់ចេញតម្លៃត្រឹមតែ ១៤៥០រៀល ប៉ុន្តែតម្លៃអំបោះក្នុងឆ្នាំនេះក៏មានការកើនឡើងទ្វេដងផងដែរ ដោយក្នុងមួយគីមាន តម្លៃដល់ ១៤ ០០០រៀល បើប្រៀបធៀបឆ្នាំទៅមានតម្លៃប្រមាណ ៨០០០រៀល ប៉ុណ្ណោះ។[11]

**ខ. ឆ្នាំ២០២០ ដល់២០២២**

ការផ្ទុះឡើងដំបូងនៃជំងឺកូវីដ-១៩ ត្រូវបានគោរយការណ៍ថា បានកើតឡើងនៅក្នុងប្រទេសចិននៅចុងឆ្នាំ ២០១៩ ហើយនៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ អង្គការសុខភាពពិភពលោក (WHO) បានប្រកាសថា វាជាការព្រួយបារម្ភជាអន្តរជាតិនូវភាពអាសន្នទៅលើផ្នែកសុខភាពសាធារណៈ។ ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោក ហើយការកើនឡើងនៃវិបត្តិនេះកំពុងប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍មិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លាញដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដល់ប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរផងដែរ។

ដូចគ្នានេះដែរ បណ្ដាប្រទេសសមាជិកអាស៊ានទាំងអស់កំពុងរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីជំងឺកូវីដ-១៩។ ខណៈការផ្ទុះឡើងនៃជំងឺនេះជាសកល បាននាំឱ្យមានការរំខានដល់ខ្សែរចង្វាក់ផ្គត់ផ្គង់ និងបង្ករជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរនៃការធ្វើដំណើរ ពាណិជ្ជកម្ម និងការវិនិយោគ ដែលជាហេតុបាននាំមកនូវការរំខាន ទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ច នៅក្នុងបណ្ដាប្រទេសអាស៊ាន ក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ។

ប្រទេសកម្ពុជាបានជួបបញ្ហាលើគ្រប់វិញវិស័យទាំងអស់ ព្រោះតែការបិទខ្ទប់ប្រទេស ក្នុងនោះវិស័យសិប្បកម្មក៏មានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរផងដែរ។ ពិសេសវិស័យសិប្បកម្មក្រមាយើងនេះឯងពិតជាជួបប្រទះនូវបញ្ហាទីផ្សារយ៉ាងខ្លាំងផងដែរ។ ក្រមាគ្មានតម្រូវការទីផ្សារ សិប្បករតម្បាញគ្រប់គ្រួសារជួបនូវវិបត្តិហិរញ្ញវត្ថុ។ ព្រោះតែតម្លៃក្រមាធ្លាក់ចុះខ្លាំង លក់ចេញបានតម្លៃថោកពីមួយថ្ងៃទីមួយថ្ងៃ ពេលខ្លះមិនមានការទទួលទិញឡើយ បើទោះបីជាលក់ក្នុងតម្លៃទាបណាមួយក៏ដោយ។

វិបត្តិនេះបានធ្វើអោយសិប្បករគ្រប់រូបសម្រេចចិត្តផ្អាកបណ្ដោះអាសន្ន កម្មករតម្បាញត្រូវត្រឡប់ទៅស្រុកវិញដែលជាផលប៉ះដល់ជីវភាពគ្រួសារជាខ្លាំង និង បានធ្វើអោយសិប្បករប្រមាណជា៣០ភាគរយបានសម្រេចចិត្តផ្អាក ឬឈប់ធ្វើតែម្ដង ពិសេសសិប្បករដែលធ្វើក្រមាជាលក្ខណៈគ្រួសារខ្នាតតូច(២ទៅ៣គី) ហើយចំពោះ

[11] សរសេរដោយៈ សហការី. Sat,13 June 2020. *អ្នកប្រកបមុខរបរតម្បាញក្រមាខ្មែរនៅស្រុកស្វាយជ្រំត្អូញត្អែរពីការធ្លាក់ថ្លៃដោយសារកូវីដ-១៩.* គេហទំព័រ កោះសុវណ្ណភូមិ

គ្រួសារដែលជាម្ចាស់សិប្បកម្មលក្ខណៈគ្រួសារខ្នាតធំ(១០ទៅ២០កី) ក៏មានប៉ះពាល់ដែរប៉ុន្តែមិនអាចឈានទៅដល់ការបិទនោះទេព្រោះពួកគាត់មានធនធានគ្រប់គ្រាប់សម្រាប់ទប់ទល់ បន្ទាប់ពីផុតរដូវកាល COVID-19 ពួកគាត់ចាប់ផ្តើមបើដំណើរផលិតធម្មតា។

មកដល់បច្ចុប្បន្ន តម្លៃទីផ្សារក្រមាមានការកើនឡើងខ្លះៗដែរ ធ្វើអោយប្រជាជនដែលប្រកបរបរសិប្បកម្មតម្បាញក្រមានេះ ទទួលបាននេះចំណូលគួរគ្រាន់សម្រាប់ជីវភាពនៅ។ ប៉ុន្តែការកើតឡើងនេះមិនមែន ជាកម្រិតដែលអាច អោយប្រជាជនចំណិញច្រើននោះទេ បើធៀបនឹងតម្លៃវត្ថុធាតុដើម និងតម្លៃកម្មករ ពិសេសតម្រូវការទីផ្សារក៏នៅតែមានកម្រិត។

**៤.២.២. កត្តាវត្ថុធាតុដើម**

វត្ថុធាតុដើម ជាតួអង្គមួយដ៏សំខាន់ក្នុងរាល់ការដំណើរការផលិត ផលិតផលទាំងអស់។ ចំពោះផលិតផលក្រមានេះដែរ វត្ថុធាតុដើមគឺជាតួអង្គដ៏សំខាន់បំផុត ក្នុងការតម្បាញ ព្រោះក្រមាជកើតចេញពីការត្បាញសសៃអំបោះចូលគ្នាអោយទៅជាក្រណាត់មួយដែលមានក្រមាខ្វាត់ខ្វែង និងមានពណ៌ចំរុះស្រស់ស្អាត់ផងដែរ។

**៤.២.២.១. បញ្ហាអំបោះ**

សសៃអំបោះជាវត្ថុធាតុដើមមួយ ដែលសិប្បករតម្បាញក្រមានាសម័យបច្ចុប្បន្នមិនពិបាកក្នុងការទិញនោះឡើង។ ពិសេសអំបោះនាពេលឥឡូវមិនចាំបាច់ចំណាយពេលក្នុងការផលិតតាមដំណាក់ការដូចមុខដោយខ្លួនឯងទៀតឡើយ ព្រោះប្រជាសិប្បករនិយមប្រើអំបោះដែលនាំចូលពីរប្រទេសក្រៅដូចជា ចិន និងវៀតណាមជាដើម។

អំបោះអាចមានគ្រប់ប្រទេសទៅតាមតម្រូវការរបស់សិប្បករដូចជា អំបោះឆៅ អំបោះហុង និងអំបោះសូត្រខ្មែរផងដែរ អ្វីដែលកាន់តែពិសេសនោះ អំបោះអាចមានគ្រប់ពណ៌ទៅតាម តម្រូវរបស់យើងទៀតផង។ បញ្ហាប្រឈមអំពីអំបោះ ដែលសិប្បករនៅភូមិជ្រោយអំពិលនាសម័យបច្ចុប្បន្នកំពុងជួបប្រទះនោះគឺ តម្លៃនៃអំបោះទាំងនោះ។ តម្លៃអំបោះឡើងចុះមិនទៀងទាត់ ឆ្នាំខ្លះសិប្បករទិញបានអំបោះបានក្នុងតម្លៃធូរថ្លៃ ដែលធ្វើអោយមានភាពងាយស្រួលក្នុងការលក់ក្រមាចេញវិញ។ ប៉ុន្តែឆ្នាំខ្លះតម្លៃអំបោះឡើងខ្ពស់ហួសប្រមាណ ដែលនាំអោយសិប្បករពិបាកក្នុងការលក់ក្រមា ព្រោះតម្លៃក្រមាមិនអាចនឹងឡើងថ្លៃបានច្រើនឡើយ។

តាមរយៈបទសម្ភាសជាមួយអ្នកស្រី ជុំ ស្រស់ ដែលជាសិប្បករតម្បាញក្រមាមួយរូបនៅក្នុងភូមិជ្រោយអំពិល បានលើកឡើងអំបីបញ្ហាតម្លៃអំបោះនេះថា អ្នកស្រីជាសិប្បករមួយរូបមានមិនមានកីច្រើនដូចម្ចាស់សិប្បកម្មក្រមាធំៗដែលមានកីតម្បាញច្រើននោះទេ ពោលគឺអ្នកស្រីមានត្រឹមចំនួន ៣កីប៉ុណ្ណោះ។ ចំពោះអំបោះអ្នកស្រីមិនពិបាករកទិញទេ ពោលគឺទីណាក៏មាន ប៉ុន្តែឆ្នាំខ្លះអំបោះឡើងថ្លៃហួសប្រមាណ ហើយអ្នកស្រីមិនអាច

ទិញអំបោះស្តុកច្រើនតោនដូចម្ចាស់សិប្បកម្មធំៗឡើង ទើបមិនអាចទទួលបានតម្លៃពិសេសនៅក្នុងរដូវកាលអំបោះឡើងថ្លៃបានឡើយ ដែលជាបញ្ហាធ្វើអោយអ្នកស្រីពិបាកផលិតក្រមាលក់។

អ្នកស្រីបានបន្ថែមទៀតថា កំឡុងពេលដែលអំបោះកំពុងឡើងថ្លៃ តម្លៃក្រមាមិនបានឡើងតាមបាននោះទេ ពោលតម្លៃក្រមាដែលធ្លាប់លក់ក្នុងតម្លៃណា គឺនៅតែលក់ក្នុងតម្លៃនោះដដែល ដែលជាហេតុនាំអោយអ្នកស្រីពិបាកក្នុងរយៈពេលនោះ។ លើសពីនេះទៅទៀតឆ្នាំខ្លះក្រមាធ្លាក់ថ្លៃខ្លាំង កំឡុងពេលដែលអំបោះកំពុងឡើងថ្លៃ ដែលនាំអោយអ្នកស្រីសម្រេចចិត្តផ្អាកមួយរយៈ តែមិនឈប់រហូតឡើយ រហូតដល់តម្លៃទីផ្សារអំបោះ និងក្រមាត្រឡប់មកដូចដើមវិញ។ អ្នកស្រីក៏បន្តទៀតថា សិប្បករតម្បាញក្រមាគ្រប់រូបសុទ្ធសឹងតែទទួលរងនៅវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរនេះ រហូតដល់ម្ចាស់សិប្បកម្មតូចៗមួយចំនួនសម្រេចចិត្តឈប់ធ្វើតែម្តង។

## ៤.៣. ដំណោះស្រាយ

សព្វថ្ងៃនេះ តាមរយៈការស្រាវជ្រាវយើងបានសង្កេតឃើញថា រដ្ឋាភិបាលបាននឹងកំពុងព្យាយាមស្វែងរកដំណោះស្រាយជាច្រើន ហើយក៏បានអនុវត្តន៍បានច្រើនដែរ ដើម្បីអោយផលិតផលក្រមាខ្មែរមានប្រជាប្រិយភាពទីផ្សារមានដំណើរការល្អ និងការពារវិស័យតម្បាញក្រមាខ្មែរកុំឲមានការអន់ថយ ដែលអាចនឹងប្រឈមនូវការបាត់បង់ក្រមាខ្មែរ ។

### ៤.៣.១. ដំណោះស្រាយមួយចំនួនរបស់រដ្ឋាភិបាល

ការបង្កើតកម្មវិធីផ្សព្វផ្សាយទៅលើសកលលោកៈ រដ្ឋាភិបានការធ្វើកម្មវិធីផ្សព្វផ្សាយដែលទាក់ទងទៅនិងអត្ថប្រយោជន៍នៃការប្រើប្រាស់ក្រមាខ្មែរក្នុងគោលគំនិត គាំទ្រ និងលើកតម្លើងផលិតផលក្រមាអោយមនុស្សទាំងក្នុងនិងក្រៅប្រទេសបានយល់និងត្រឡប់មកប្រើប្រាស់វិញ ដើម្បីអោយទីផ្សារមានកំណើនឡើងវិញផងដែរ។ ឧទាហរណ៍ ដូចជាយុទ្ធនាការក្រមាៈ «បំបែក ឯកទគ្គកម្ម ក្រមាវែងជាងគេលើពិភពលោក» នៅក្នុងថ្ងៃទី ១៨ មិថុនា ឆ្នាំ២០១៨ ដែលជាគំនិតផ្តួចផ្តើមរៀបចំឡើងដោយសហភាពសហព័ន្ធយុវជនកម្ពុជា ដែលមាន ឯកឧត្តម ហ៊ុន ម៉ានី ជាប្រធាន។ នៅក្នុងកម្មវិធីនោះមានបំណងបង្ហាញក្រមាខ្មែរដែលវែងជាងគេនៅលើពិភពលោក ដែលមានប្រវែងរហូតដល់ ១ពាន់ម៉ែត្រ។ គេក៏បានដាក់អោយមានកីតម្បាញក្រមានៅចំកណ្តាលទីក្រុងដើម្បីបើកឱកាសឲ្យសាធារណៈជន ទូទៅអាចចូលរួមត្បាញក្រមា វែងជាងគេនេះ ដើម្បីទទួលបាន ឯកទគ្គកម្មកំណត់ត្រាពិភពលោក។ ការបើកបង្ហាញនេះបានជះឥទ្ធិពលវិជ្ជមានមួយជំនួនធំដល់វិស័យសិប្បកម្មក្រមានេះ ដោយបានង្ហាញអោយពិភពលោកបានស្គាល់នឹងចង់ប្រើប្រាស់ក្រមាខ្មែរ ដែលធ្វើអោយទីផ្សារក្រមាពេលនោះមានកំណើនគួរអោយកត់សម្គាល់។

ការលើកទឹកចិត្តអោយប្រើប្រាស់៖ នៅក្នុងកំឡុងឆ្នាំ២០២១ ដែលជារយៈពេលមួយដែលប្រទេសកម្ពុជាជួបប្រទះវិបត្តិលើគ្រប់វិស័យ ដោយសារ COVID-19 ប្រជានជនគ្រប់ត្រូវ ការប្រើប្រាស់ម៉ាសជាចាំបាច់ដើម្បីការពារ

មេរោគ។ ចំពោះវិស័យសិប្បកម្មក្រមាក៏មានការធ្លាក់ចុះ ក៏ប៉ុន្តែដោយភាពវៃឆ្លាតរបស់សិប្បករខ្មែរ គេបានឆ្នៃក្រម៉ាទៅជាម៉ាសដែលអាចប្រើប្រាស់បានច្រើនដង និងសុវត្ថិភាពខ្ពស់។ ដូន្នេះរដ្ឋាភិបាលក៏បានលើកទឹកចិត្ត និងអំពាវនាវអោយប្រជាជនគ្រប់រូបប្រើប្រាស់ម៉ាស ដែលឆ្នៃឡើងពីក្រមានេះ ជាជាងប្រើប្រាស់ម៉ាសដែលនាំចូល។ ទង្វើនេះបានដោះស្រាយវិបត្តិដល់សិប្បករ អោយមានទីផ្សារឡើងវិញបើទោះបីជាតិចតួចក៏ដោយ ក៏ប្រជាជនអាចទទួលបានចំណូលខ្លះក្នុងគ្រាមានវិបត្តិនេះដែរ។

**៤.៣.២. គំនិតឆ្នៃប្រឌិតរបស់ប្រជាពលរដ្ឋផ្ទាល់**

ការកែឆ្នៃក្រមាជាសម្ភារៈទាន់សម័យៈ ក្រមាធម្មតាអាចមិនមែនជាតម្រូវការរបស់មនុស្សសម័យថ្មីទើបការលក់មិនកើនឡើងព្រោះពុំសូវ មានការចាប់អារម្មណ៍ ដូច្នេះប្រជាជនមួយចំនួន មានគំនិតឆ្នៃប្រឌិត ដោយយកក្រមាមកឆ្នៃជារបស់សម្ភារៈប្រើប្រាស់ថ្មីដូចជា សម្លៀកបំពាក់ ការបូប បូរឬកៅស៊ូចង់សក់ ម៉ាស់ មួក និងជាវត្ថុអនុស្សាវរីយ៍សម្រាប់ជូនក្នុងកម្មវិធីផ្សេងៗ។ ជាក់ស្តែងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះយើងបានសង្កេតឃើញថាសន្ទុះនៃការគាំទ្រក្រមាខ្មែរមានការកើនឡើងច្រើន ដោយមានវត្តមានបុគ្គលល្បីៗមួយចំនួនដូចជា តារាសម្តែងកញ្ញា មានសូនីតា បានចាប់ផ្តើមចលនាម៉ូតក្រមាជាសម្លៀកចំពាក់ ព្រមទាំងបានធ្វើការផ្សព្វផ្សាយជាវីដេអូឃ្លី របស់ខ្លួននៅក្នុង យូធ្យូប ដែលមានការពិពណ៌នាលម្អិត អំពីវិធីកែច្នៃក្រមាខ្មែរទៅជារបស់ប្រើប្រាស់ប្រចាំថ្ងៃ ដូចជា អាវ ឬ គ្រឿងលម្អ ខ្លួនផ្សេងៗជាដើមរហូតដល់ កញ្ញា បើកហាងដែលមានលក់សម្លៀកបំពាក់ និងរបស់ប្រើប្រាស់ផ្សេងៗពីក្រមា រហូតដល់ប្រជាជនខ្មែរបានដាក់ឈ្មោះនាងជា រាជនីក្រមា។ កត្តាទាំងនេះគឺជាដំណោះស្រាយដ៏ល្អមួយក្នុងការជួយជម្រុញដល់កំណើនទីផ្សារក្រមាខ្មែរអោយមានអោយមានភាពប្រសើរឡើង ដែលអាចជាផលវិជ្ជមានដល់សិប្បករតម្បាញក្រមាអោយមានជីវភាពគ្រប់គ្រាន់ និងមានទឹកចិត្តក្នុងការបន្តថែរក្សាវិស័យមួយនេះអោយនៅគង់វង្សដល់មនុស្សជំនាន់ក្រោយ។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ក្រមាគឺជាវត្ថុដែលជាតម្រូវការប្រើប្រាស់ចាំបាច់មួយផ្នែកក្នុងការរស់នៅរបស់ប្រជាជនខ្មែរ ដែលយើងតែងតែឃើញពួកគេមានដាក់ជាប់ខ្លួន និងយកជាប់ជាមួយស្ទើរគ្រប់ទីកន្លែង។ ការងារនេះ ពិតជាត្រូវការមនុស្សហ្មត់ចត់ អត់ធ្មត់ និងមានចំណេះយល់ ពីធម្មជាតិផង ទើបអាចធ្វើការការជាមួយសរសៃអំបោះដ៏តូចឆ្មារ ឲ្យកើតបានជាផ្ទាំងក្រមាដ៏ធំសម្រាប់ បើ រំលេចដោយក្រឡាតាម និងពណ៌យ៉ាងល្អវិសេស។ ហើយឥរិយាបទបែបនេះមានតាំងពីសម័យដើមរហូតមកដល់បច្ចុប្បន្ននេះ និងក្រមាជារបស់មួយដែលប្រជាជនខ្មែរមិនអាចខ្វះបានផងដែរ ពោលគឺក្រមាមានមុខងារសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃបានច្រើនទម្រង់ ច្រើនបែបច្រើនយ៉ាង ច្រើនរាប់មិនអស់ដូចជា រាប់តាំងពីស្លៀក ដណ្តប់ ផេចខ្ចប់ ទទូរ ក្រាល ស្លៀកពាក់ ។ល។

ម្យ៉ាងវិញទៀត ក្រមាក៏មានខ្លឹមសារដោយឡែកមួយទៀតក្នុងបរិបទវប្បធម៌ និងប្រពៃណីផងដែរ ហើយរហូតវាបានក្លាយជានិមិត្តរូប និងអត្តសញ្ញាណជាតិយ៉ាងសំខាន់។ ប៉ុន្តែយ៉ាងណាក៏ដោយ មកដល់បច្ចុប្បន្នការងារតម្បាញក្រមាហាក់ប្រឈមនឹងការបាត់បង់គួរឲ្យបារម្ភ ជាពិសេសការត្បាញ តាមបែបប្រពៃណី ។ សហគមន៍ខ្លះ បានបោះបង់ការត្បាញក្រមាចោលទាំងស្រុង ស្របពេលក្មេង ជំនាន់ក្រោយហាក់មិនចាប់អារម្មណ៍នឹងក្រមា ហើយផលិតផលបរទេសដែលអាចប្រើជំនួសកមា ជាច្រើនបាននាំចូលមក។ ចំណែកសហគមន៍ខ្លះ នៅបន្តត្បាញក្រមាតិចតួច តែពួកគេលែងរចះផលិត សម្ភារៈ និងវត្ថុធាតុសម្រាប់ត្បាញទៀតហើយ ដ្បិតរបស់ទាំងនេះមានស្រាប់ៗនាំចូលមកលក់លើ ទីផ្សារ។ ទាំងអស់នេះ ជាការប្រឈមដែលយើងមើលឃើញជាក់ស្តែងសព្វថ្ងៃ ហើយដែលគួរតមាន ការសិក្សានិងថែរក្សា ដ្បិតវាជាអត្តសញ្ញាណដ៏សំខាន់របស់ជាតិ និងវប្បធម៌។

ដូច្នេះក្នុងនាមយើងទាំងអស់គ្នាដែលជាពលរដ្ឋខ្មែរ ជាពិសេសក្មេងជំនាន់ក្រោយគួរគប្បីស្វែងយល់បន្ថែមអោយកាន់តែច្បាស់ អំពីរបស់ដែលជាអត្តសញ្ញាណដ៏សំខាន់របស់ជាតិ និងវប្បធម៌។ យកមកអភិវឌ្ឍ ថែរក្សារ និងកែច្នៃធ្វើយ៉ាងណាដើម្បីលើកមុខមាត់ប្រទេសជាតិ ធ្វើអោយពិភពលោកបានស្គាល់ក្រមាខ្មែរដែលជាវត្ថុសល់តំណពីដូនតាមក។

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះពិតជាបានឲពួកយើងដែលជានិសិត្ស និងជាក្មេងខ្មែរជំនាន់ក្រោយបានយល់បានកាន់តែច្បាស់អំពីអត្ថប្រយោជន៍នៃក្រមាខ្មែរដែលមិនធ្លាប់បានដឹងពីមុនមក។ ពិសេសប្រធានបទនេះបានអោយយើងយល់ដឹងពីមុខវិជ្ជានេះកាន់តែស៊ីជម្រៅ។

## ៥.២. ការផ្តល់អនុសាសន៍

ដើម្បីជាយុទ្ធសាស្ត្រ ក្នុងការដោះស្រាយបញ្ហាទីផ្សារ និងអភិវឌ្ឍវិស័យសិប្បកម្មក្រមានៅក្នុងភូមិជ្រោយអំពិលទាំងមូល ប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាព ក្រុមយើងខ្ញុំសូមធ្វើការបញ្ចេញមតិយោបល់នៅក្នុងការចូលរួមកែលំអនូវចំណុច ខ្វះខាតទាំងឡាយ ដើម្បីជួយសម្រួលទីផ្សារ និងពង្រឹងការអភិវឌ្ឍវិស័យសិប្បកម្មក្រមាខ្មែរនៅក្នុងភូមិជ្រោយអំពិល អោយកាន់តែប្រើសើរឡើងបានមួយកម្រិតបន្ថែមទៀត។

ជាអនុសាសន៍របស់ក្រុមយើងខ្ញុំ យើងខ្ញុំបានយល់ថាវិស័យសិប្បកម្មក្រមាខ្មែរគួរត្រូវយកចិត្តទុកដាក់បន្ថែមលើចំណុចដូចជា៖

១. រាជរដ្ឋាភិបាលគួរពន្យល់ណែនាំ និងជំរុញលើកទឹកចិត្តដល់សិប្បករ អោយបន្តនូវការផលិតបន្ថែម និងមិនបោះបង់ចោលការតម្បាញក្រមានេះ។

២. រាជរដ្ឋាភិបាល គួរមានវិធានការបន្ថែមលើ ការផ្សព្វផ្សាយ អំពីអត្ថប្រយោជន៍ នៃក្រមាខ្មែរ ដើម្បីបង្កើតប្រជាប្រិយភាពបន្ថែមដល់ក្រមាខ្មែរ ដែលជាផលវិជ្ជមានដល់ទីផ្សារក្រមាផងដែរ។

៣. គួរការបង្កើតកម្មពិធីពិពណ៌នានា នៅក្នុងសហគមន៍តម្បាញ ឬក្នុងភូមិស្រុកដែលសម្បូរដោយសិប្បកម្មក្រមា ដើម្បីបង្កើនទីផ្សារ និងអោយប្រជាជនបានស្គាល់ពីតំបន់នោះ។

៤. សិប្បករតម្បាញគួរមានភាពច្នៃប្រឌិតបន្ថែមលើការបង្កើតវិធីសាស្ត្រក្នុងការប្រើប្រាស់ក្រមា ដូចជាការច្នៃក្រមាទៅជាសម្ភារៈប្រើប្រាស់ផ្សេងៗដែលមិនធ្លាប់មាន។

# ឯកសារយោង

# ឯកសារយោង

សរសេរដោយៈ កញ្ញា កែម សុនីន. *កីតម្បាញក្រមារបស់អ្នកកៀនស្វាយ.* Retrieved from http://www.yosothor.org/publications/khmer-renaissance/chapter-one/terk-dam-banh-kro-ma-rbos-neak-kean-svay.html

សរសេរដោយៈ Sokhom Khon. ថ្ងៃសុក្រ ទី ១៤ មីនា ២០២២. *មុខរបរត្បាញក្រមា ក៏អាចរកចំណូលជួយដល់ជីវភាព គ្រួសារឲ្យបានប្រសើរដែរ.* កម្ពុជាថ្មី ប្រចាំថ្ងៃ. Retrieved from https://www.kampucheathmey.com/local-news/286322

*Story of Krama*. Retrieved from https://www.kramakrama.com/en/story-of-krama#:~:text=Originally%2C%20the%20krama%20was%20a,red%20before%20starting%20the%20weaving

*Krama (Khmer Scarf)*. Retrieved from https://intocambodia.org/content/krama-khmer-scarf

សរសេរដោយៈ សហការី. (Sat,13 June 2020). *អ្នកប្រកបមុខរបរតម្បាញក្រមាខ្មែរនៅស្រុកស្វាយជ្រុំត្អូញត្អែរពីការធ្លាក់ថ្លៃដោយសារកូវីដ-១៩.* គេហទំព័រ កោះសុវណ្ណភូមិ Retrieved from http://www.ksvpnews.com/Detail/202061314243399

សរសេរដោយៈ សុខ សាន្ត. (ថ្ងៃទី 23 March, ឆ្នាំ 2022). *កីតម្បាញពាក់កណ្តាលស្វ័យប្រវត្តិ អាចរក ប្រាក់ចំណូលជួយគ្រួសារបានយ៉ាងប្រសើរ.* Retrieved from https://dr-daily.com/archives/18724

(August 19, 2018). *កីតម្បាញរចនាបទបុរាណ និងក្រមាវែងជាងគេលើពិភពលោកត្រូវបានដាក់តម្កល់តាំងជាសាធារណៈ.* Retrieved from https://cen.com.kh/archives/77923.html

សរសេរដោយៈ ជា ពិសី. (១៩៩៤). *តម្បាញក្រមាខ្មែរ.* សារណាបញ្ចប់បរិញ្ញាបត្រ. មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

ឆ្នាំ២០១៧ អត្ថបទស្រាវជ្រាវពីក្រមា. *ក្រមាខ្មែរ.* Retrieved from http://www.gogocambodia.asia/wp-content/uploads/2018/01/%E1%9E%A2%E1%9F%86%E1%9E%96%E1%9E%B8%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%98%E1%9E%B6.pdf

From Wikipedia, the free encyclopedia. *Krama*. Retrieved from https://en.wikipedia.org/wiki/Krama

David & Sue Richardson. (2022, February 21). *Cambodian Krama*. Retrieved from http://www.asiantextilestudies.com/krama.html#x

Lifestyle & More, Magazine. (2020, November 18). *THE KRAMA – WORLD´S MOST VERSATILE GARMENT*. Retrieved from https://heritage-line.com/magazine/krama-the-worlds-most-versatile-garment/

August 19, 2018. *កីតម្បាញរចនាបទបុរាណ និងក្រមាវែងជាងគេលើពិភពលោកត្រូវបានដាក់តម្កល់តាំងជាសាធារណៈ*. Retrieved from https://cen.com.kh/archives/77923.html

*The Cambodian Krama Scarf, The Story Behind This Iconic Scarf*. Retrieved from https://abusonadustyroad.com/the-cambodian-krama-scarf-the-story-behind-this-iconic-scarf/?expand_article=1

សរសេរដោយៈ ទី សម្ផស្សវិច្ឆិកា & ស៊ីម វីរីនា. (2011, August 29). *បញ្ហាប្រឈមនៃសិប្បកម្មក្រមានៅកៀនស្វាយ*. Retrieved from https://www.postkhmer.com/%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85/%E1%9E%94%E1%9E%89%E1%9F%92%E1%9E%A0%E1%9E%B6%E2%80%8B%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%88%E1%9E%98%E2%80%8B%E1%9E%93%E1%9F%83%E2%80%8B%E1%9E%9F%E1%9E%B7%E1%9E%94%E1%9F%92%E1%9E%94%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E2%80%8B%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%98%E1%9E%B6%E2%80%8B%E1%9E%93%E1%9F%85%E2%80%8B%E1%9E%80%E1%9F%80%E1%9E%93%E2%80%8B%E1%9E%9F%E1%9F%92%E1%9E%9C%E1%9E%B6%E1%9E%99

សរសេរដោយ: បណ្ឌិត ព្រុំ ទេវី. (ខែមករា ឆ្នាំ២០១៩). *ទស្សនទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម នៅប្រទេសកម្ពុជា*. Retrieved from http://rac.gov.kh/royal-academy/research/attachments/original/21.pdf?1546423309

Susan Ward. *និន្នាការសហគ្រាសធុនតូចនិងមធ្យម (សហគ្រាសធុនតូចនិងមធ្យម)*. Retrieved from https://km.unitinal.com/%E1%9E%93%E1%9E%B7%E1%9E%93%E1%9F%92%E1%9E%93%E1%9E%B6%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%9F%E1%9E%A0%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F

%E1%9E%92%E1%9E%BB%E1%9E%93%E1%9E%8F%E1%9E%BC%E1%9E%85/

*អ្វីទៅជាសហគ្រាសធុនតូច និងមធ្យម? តើសហគ្រាសធុនតូច និងមធ្យមមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះ?* Retrieved from https://cambodia4point0.org/kh/tech-for-sme.html

គេហទំព័រ KhmerSME. *សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យឧស្សាហកម្ម*. Retrieved from khmersme.gov.kh/sme-in-industry/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ តារាងក្រាហ្វិចចំនួនគ្រួសារប្រជាជនដែលប្រកបរបរក្រមាក្នុងភូមិជ្រោយអំពិល




ឧបសម្ព័ន្ធទី២៖ តារាងទិន្នន័យតម្លៃក្រមាក្នុងភូមិជ្រោយអំពិល



ឧបសម្ព័ន្ធទី៣៖ តារាងទិន្នន័យនៃស្ថានភាពគ្រួសារទាំង២០គ្រួសារ

| តារាងទិន្នន័យនៃស្ថានភាពគ្រួសារទាំង២០គ្រួសារ | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះ | ភេទ | អាយុ | រយៈពេល | ចំនួនគី | ចំនួនកម្មករ | ផលិតបាន/1ថ្ងៃ |
| ផៃ ផាន់នី | ស | 53 | 24ឆ្នាំ | 14 | 7 | 450-500 |
| ផៃ ចាន់ធី | ស | 50 | 30ឆ្នាំ | 10 | 3 | 200-250 |
| ជុំ ស្រស់ | ស | 35 | 10ឆ្នាំ | 3 | តម្បាញផ្ទាល់ | 60-70 |
| ណូ យឿន | ស | 60 | 30ឆ្នាំ | 2 | តម្បាញផ្ទាល់ | 50-60 |
| លី គឹមសាន | ប | 50 | 20ឆ្នាំ | 21 | 8 | 600-650 |
| អ៊ុយ សុខន | ស | 60 | 35ឆ្នាំ | 7 | 2 | 150-160 |
| លឹម អាង | ស | 55 | 30ឆ្នាំ | 7 | 2 | 150-160 |
| ហឺ ឡាយហោង | ប | 40 | 10ឆ្នាំ | 10 | 4 | 250 |
| ហឺ ឡាយហៀង | ស | 45 | 20ឆ្នាំ | 11 | 4 | 400-450 |
| ឃ្លាំង សុខា | ស | 57 | 25ឆ្នាំ | 4 | 1 | 80-90 |
| រី កនីកា | ស | 35 | 17ឆ្នាំ | 15 | 7 | 500-520 |
| រុន ណារី | ស | 30 | 10ឆ្នាំ | 3 | តម្បាញផ្ទាល់ | 60-70 |
| បាន សុផល | ស | 60 | 40ឆ្នាំ | 30 | 16 | 800-900 |
| លាប ប៊ុនលី | ប | 55 | 28ឆ្នាំ | 14 | 5 | 450-500 |
| ប៊ុន ស៊ីថា | ស | 48 | 19ឆ្នាំ | 12 | 4 | 370-400 |
| ចាន់ ស៊ីមន | ស | 52 | 26ឆ្នាំ | 15 | 7 | 500-540 |
| គង់ សុវ៉ាន់ | ប | 56 | 20ឆ្នាំ | 12 | 6 | 400-450 |
| នៅ មុំ | ស | 48 | 24ឆ្នាំ | 6 | 2 | 140-150 |
| គីម សុខ | ស | 46 | 14ឆ្នាំ | 2 | តម្បាញផ្ទាល់ | 50-60 |
| សៀម ហេង | ប | 61 | 37ឆ្នាំ | 18 | 7 | 550-580 |

ឧបសម្ព័ន្ធទី៩៖ ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ផាន់នី





ឧបសម្ព័ន្ធទី៥៖ គំនរក្រមានៅផ្ទះអ្នកស្រី ផៃ ផាន់នី



ឧបសម្ព័ន្ធទី៦៖ការចុះសម្ភាសន៍ជាមួយ អ្នកស្រី ផៃ ចាន់ធី



ឧបសម្ព័ន្ធទី៧៖ ការចុះសម្ភាសន៍ជាមួយ លោក លី កំសាន្ត



ឧបសម្ព័ន្ធទី៨៖ រោងតម្បាញរបស់ លោក លី កំសាន្ត



ឧបសម្ព័ន្ធទី៩៖ ការចុះសម្ភាសន៍ជាមួយ លោកមេភូមិ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ



ឧបសម្ព័ន្ធទី១០៖ ការចុះសម្ភាសន៍ជាមួយលោក សៀម



ឧបសម្ព័ន្ធទី១១៖ ក្រមាវិញជាយខ្នាតតូច។ មានទំហំ បណ្ដោប្រវែង ១.៦០ម៉ែត្រ និងទទឹងប្រវែង ០.៤០ម៉ែត្រ។



ឧបសម្ព័ន្ធទី១២៖ ក្រមាវិញជាយខ្នាតធំ។ មានទំហំ បណ្ដោយប្រវែង ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៧០ម៉ែត្រ។



ឧបសម្ព័ន្ធទី១៣៖ ក្រមាអំបោះឆៅ។ មានទំហំ បណ្ដោយប្រវែង ១.៨០ម៉ែត្រ និងទទឹងប្រវែង ០.៨៥ម៉ែ



ឧបសម្ព័ន្ធទី១៤៖ ក្រមាអំបោះហុង។ មានទំហំ បណ្ដោយ ប្រវែង ១.៧០ម៉ែត្រ និងទទឹងប្រវែង ០.៨០ម៉ែត្រ។

